00829468

E1/98.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 31-Jul-2012, 14:34

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៨៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ណាតាចា វិស៊ែល រីស៊ឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាកទួរ វ៉េកគែន | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក អៀង សារី | ខ្មែរ |
| លោក វ៉ាថាម តុន (TCW-564) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក រ៉ៃចាម តុន ហៅ តី តួន** (TWC-564)

សួរបន្តដោយលោក ឌេល លីសាក់ ផ្ដើមពី៖.................................................................ទំព័រ ៤

សួរដោយលោក ឡោ ជុនធី ផ្ដើមពី៖.........................................................................ទំព័រ ៤៨

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី៖...............................................ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះបន្តកិច្ចដំណើរការនីតិវិធីការសវនាការ។ នៅព្រឹកនេះកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្ម រ៉ូចាម តុន ដែលនឹងបន្តការតាំងសំណួរដេញដោលដោយតំណាង សហព្រះរាជអាជ្ញា ហើយមុននឹងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ក្រឡាបញ្ជីសវនាការ លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន ភាគីនិងបុគ្គល ដែលអង្គជំនុំជម្រះ អញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ នៅក្នុងសវនាការ សម្រាប់ថ្ងៃនេះ មិនមាននូវសាក្សីបម្រុងនោះទេ។

[០៩:០៤:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ នៅព្រឹកនេះ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ គាត់សុំលះបង់សិទ្ធិចូលរួម នៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយទៅតាមដានកិច្ចដំណើរការ សវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការថ្ងៃនេះ។ ហើយលោកវេជ្ជបណ្ឌិតដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យឃើញថា នៅព្រឹកនេះលោក អៀង សារី មានអាការៈហត់ខ្លាំងនៅពេលធ្វើចលនា ហើយគាត់ឈឺចង្កេះពិបាកអង្គុយ បត់ជើងតូចញឹកញាប់។ ហើយគ្រូពេទ្យបានផ្ដល់អនុសាសន៍ថា លោក អៀង សារី នៅព្រឹកនេះអាចចូលរួមនៅក្នុងកិច្ចដំណើរការ -- ក្នុងបន្ទប់សវនាការដោយផ្ទាល់មិនលើស ពី៣០នាទីទេ ហើយផ្ដល់អនុសាសន៍ថា គប្បីអង្គជំនុំជម្រះគួរតែអនុញ្ញាតឲ្យគាត់ទៅតាមដានកិច្ចដំណើរ ការសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៥:៤៣]

ហើយនៅពេលនេះ ជនជាប់ចោទ អៀង សារី ដែលលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ហើយឲ្យលោក អៀង សារី ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:២៣]

ហើយឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវានាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំលោក អៀង សារី ចុះទៅក្រោម ទៅបន្ទប់ឃុំខ្លួនមួយដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

លោក អៀង សារី ចង់មានយោបល់ ប្រសាសន៍អី?

សូមអញ្ជើញ!

**លោក អៀង សារី៖**

*(ឮមិនច្បាស់)* ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

[០៩:០៧:៣០]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រី -- អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ។ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលោក អៀង សារី មិនមានអ្វីត្រូវលើកឡើង ឬក៏ចង់ធ្វើសេចក្តីថ្លែងការណ៍នោះទេ គឺលើកលែងតែករណីដែលថា គាត់មិនអាចចូលរួមសវនាការនៅទីនេះដោយផ្ទាល់នោះ

ទេ។ ទាក់ទងទៅនឹងសេចក្ដីសម្រេចរបស់លោក លោកស្រីចៅក្រមនោះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

នាំគាត់ទៅក្រោមចុះ!

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី រ៉ចាម តុន ហើយមុននឹងតាំងសំណួរ លោកព្រះរាជអាជ្ញាអាច ជម្រាបដល់អង្គសវនាការបានទេ ថាតើលោកប្រើប្រាស់ពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដល់សាក្សីរូបនេះ ហើយការបែងចែកពេលវេលាជាមួយនឹងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយ៉ាងម៉េចដែរ?

[០៩:០៨:៥៩]

**លោក គេល លីសាក់៖**

អរុណសួស្ដី លោកប្រធានជាទីគោរព សូមអរគុណច្រើន។ យើងបានពិភាក្សាករណីនេះជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បញ្ជាក់ថា គាត់ត្រូវការរយៈពេលមួយម៉ោងកន្លះ ទៅពីរម៉ោង។ យើងខ្ញុំខាងសហព្រះរាជអាជ្ញានោះ គឺថានិងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយព្រឹកនេះតែម្ដង ហើយយើងខ្ញុំនឹងបញ្ចប់ការតាំងសំណួររបស់យើងខ្ញុំនេះ នៅព្រឹកនេះ។ ហើយយើងទុករយៈពេលដែលនៅសល់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី។

[០៩:០៩:៣៤]

យើងខ្ញុំបានទទួលរយៈពេលពីរថ្ងៃកន្លះ សម្រាប់ខាងសហព្រះរាជអាជ្ញា ដូច្នេះហើយយើងខ្ញុំនៅសល់កន្លះថ្ងៃទៀតសម្រាប់ថ្ងៃនេះ ដែលយើងត្រូវបញ្ចប់ការដេញដោលរបស់យើងខ្ញុំ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ខាងសហមេធាវីនាំមុខមានបញ្ហាអីទេ?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ សូមអរគុណលោកប្រធាន ខ្ញុំគ្រាន់តែចង់បញ្ជាក់ពីអ្វីដែលសហព្រះរាជអាជ្ញាប្រាប់អម្បាញ់មិញនេះ គឺ

យើងត្រូវការពេលសម្រាប់រសៀលនេះ។ អ៊ីចឹង យើងត្រូវការប្រហែលពេលវេលា ប្រហែលជាមួយម៉ោង លោកប្រធានសម្រាប់រសៀលនេះ។

[០៩:១០:២២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** សួស្តីលោកសាក្សី។ នៅពេលដែលយើងឈប់កាលពីថ្ងៃសុក្រ យើងបាននិយាយអំពីតួនាទីរបស់ ខៀវ សំផន នៅមន្ទីរ៨៧០។ លោកបានជម្រាប យើងខ្ញុំរួចមកហើយថា អៀង សារី បានប្រាប់លោកថា ខៀវ សំផន គឺត្រូវជំនួសតួនាទីរបស់ ឌឿន។ ហើយបន្ទាប់មក លោកត្រូវធ្វើការជូនលោក ខៀវ សំផន លើបញ្ហាផ្សេងៗ។ លោកក៏បានជម្រាបយើងខ្ញុំផងដែរថា បញ្ហាមួយដែលលោកទាក់ទងជាមួយនឹងលោក ខៀវ សំផន នោះ គឺថានៅពេលដែលមាន -- យកសំបុត្រទៅភូមិភាគនោះ គឺលោកនឹងយកសំបុត្រពីភូមិភាគមកឲ្យលោក ខៀវ សំផន ផងដែរ។ ខ្ញុំបន្តសួរទៅលើលោក ទៅលើចំណុចនេះ។ នៅពេលដែលលោកបញ្ជូនសំបុត្រពី ខៀវ សំផន បញ្ជូនពី ខៀវ សំផន ទៅភូមិភាគនោះ ថា តើលោកត្រូវជូនដំណឹង ពាំនាំដំណឹងអ្វីខ្លះពាក់ព័ន្ធទៅនឹងការងារមន្ទីរ៨៧០ នោះ?

[០៩:១១:៥៨]

**លោក រ៉ចាម គុន៖**

**ឆ៖** ថ្ងៃមុន ខ្ញុំបានជម្រាបថា ខ្ញុំនាំសារពីលោកអ៊ំ អៀង សារី ទៅគាត់ ប្រាប់គាត់អ៊ីចឹង។ ហើយខ្ញុំអត់មាននាំសារពីគាត់ទៅភូមិភាគទេ គ្រាន់តែគាត់ប្រាប់ថា គាត់បានរៀបចំទៅតាមភូមិភាគ ហើយតែប៉ុណ្ណឹងទេ។ ហើយបើយើងទៅ នាំគ្នាទៅទស្សនកិច្ចហ្នឹង គាត់ថាយើងទៅបានហើយអត់មានបញ្ហាអីទេ អ៊ីចឹងទេ។ អត់មាននាំសារទៅភូមិភាគ គឺអត់ទេ។

**ស៖** នៅពេលដែលយកឯកសារទៅជូនលោក ខៀវ សំផន តើលោកបាននិយាយពិភាក្សាជាមួយនឹងគាត់ដែរឬទេ? តើលោកបានពិភាក្សា ជជែកជាមួយគាត់អំពីតួនាទីរបស់លោក ខៀវ សំផន

នៅមន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** អត់ទេ គឺថាអត់បានជជែកជាមួយគាត់រឿងតួនាទីរបស់គាត់ទេ អត់បានជជែកទេ គ្រាន់តែថា នាំបុត្រទៅឲ្យគាត់ ហើយក្នុងខ្លឹមសារសំបុត្រហ្នឹង ពាក់ព័ន្ធរឿងទទួលភ្ញៀវ។ ទទួលភ្ញៀវនោះ គឺថាទាក់ទងទៅគាត់ គាត់ដើម្បីគាត់ជម្រាបទៅខាងភូមិភាគនុ៎ង។ ឧបមាថា ២០៣ គាត់ជម្រាបទៅភូមិភាគ ២០៣ អ៊ីចឹង។ ឧបមាថា ទៅ៣០៤ ក៏ជម្រាបទៅខាងភូមិភាគ៣០៤ តែប៉ុណ្ណឹងទេ។ អត់មានពិភាក្សាជាមួយគាត់ទេ គ្រាន់តែគាត់ប្រាប់ ទៅដល់ហ្នឹងគាត់ប្រាប់ថា គាត់បានរៀបចំរួចអស់ហើយ ទៅធ្វើការទៅ អ៊ីចឹង។

[០៩:១៥:០១]

**ស៖** សូមអរគុណ។ យើងបាននិយាយអំពីករណីដែលលោកយកលិខិត សំបុត្រទៅមន្ទីរ៨៧០។ នៅពេលដែលលោកទៅដល់នៅទីនោះ ពេលខ្លះទៅ តើលោកមានយកសំបុត្រពីមន្ទីរ៨៧០ ដើម្បីយកទៅឲ្យលោក អៀង សារី វិញដែរឬទេ?

**ឆ៖** មានខ្លះ។

**ស៖** តើឯកសារអ្វីខ្លះដែលលោកយកមកពីមន្ទីរ៨៧០ ជូនទៅលោក អៀង សារី នោះ?

**ឆ៖** ឧទាហរណ៍ ឯកសារពាក់ព័ន្ធរឿងទទួលភ្ញៀវ ពាក់ព័ន្ធរឿងទទួលភ្ញៀវគឺថាឯកសារល្អិតក្រៅពីហ្នឹងខ្ញុំមិនដឹងដែរ ប៉ុន្តែគាត់ថា ឥឡូវហ្នឹងខាងមន្ទីរហ្នឹងគេឆ្លើយតបហើយ ថាយើងរៀបចំដណើរហ្នឹងទៅបាន គាត់ប្រាប់តែប៉ុណ្ណឹង។

**ស៖** នៅពេលភូមិភាគបញ្ជូនសំបុត្រមកមេដឹកនាំបក្សនៅក្នុងទីក្រុងភ្នំពេញ តើលោកដឹងទេ គេបញ្ជូនសំបុត្រពីភូមិភាគមកភ្នំពេញដោយរបៀបណា? ហើយថាតើបញ្ជូនទៅថ្នាក់លើទៀតដោយរបៀបណា?

**ឆ៖** ពីភូមិភាគនោះ គេបញ្ជូនសារ ឬគេបញ្ជូនសំបុត្រ ខ្ញុំអត់ដឹងទេអាហ្នឹង ខ្ញុំជម្រាបដោយស្មោះ ខ្ញុំអត់ដឹងទេ។ មិនគេបញ្ជូនរបៀបណា ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកស្គាល់មន្ទីរក-៧ ដែរឬទេ? ហើយប្រសិនបើលោកស្គាល់នោះ ថាតើក-៧ គឺជាមន្ទីរអ្វីដែរ?

**ឆ៖** មន្ទីរក-៧ ហ្នឹង ខ្ញុំស្គាល់ ហើយគេថាមន្ទីរនេះ គេថាក្រោមមន្ទីររបស់៨៧០ នោះ គឺថាសាខារបស់៨៧០ នោះឯង។

[០៩:១៧:០០]

**ស៖** តើមន្ទីរក-៧ នេះមានតួនាទីមុខងារធ្វើអ្វីដែរ?

**ឆ៖** មន្ទីរក-៧ គឺថា គឺពាក់ព័ន្ធគឺថា គ្រប់ភូមិភាគ។ គ្រប់ភូមិភាគហ្នឹងគេមានការអីគេមកទាក់ទងកន្លែងហ្នឹង ហើយកន្លែងហ្នឹងហើយបានបន្តទៅទៀត បន្តទៅ៨៧០ គឺថាតាមធម្មតាហ្នឹងគឺអ៊ីចឹង។

**ស៖** តើលោកដឹងដែរឬទេ របាយការណ៍ពីភូមិភាគនោះបានទទួលដោយមន្ទីរក-៧ ឬក៏មន្ទីរ៨៧០ ឬក៏បន្ទាប់មកបញ្ជូនរបាយការណ៍នោះទៅ អៀង សារី ដែរឬទេ?

**ឆ៖** ចំណុចនេះខ្ញុំអត់ដឹងទេ អត់ដឹងដែរ។

**ស៖** នៅពេលដែលលោកធ្វើការងារនៅក្រសួងការបរទេស តើលោកដឹងនិងស្គាល់ ដែលគណៈកម្មាធិការមួយដែលហៅគណៈកម្មាធិការអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ គណៈអចិន្ត្រៃយ៍នោះ គឺថា បើខ្ញុំស្គាល់ ខ្ញុំស្គាល់តាមវិទ្យុផ្សាយទេ។ អាហ្នឹងខ្ញុំស្គាល់ ខ្ញុំក្តាប់បានប៉ុណ្ណោះដែរ បុគ្គលណាៗ អចិន្ត្រៃយ៍ខ្ញុំក្តាប់អត់បានទេ។

[០៩:១៩:៣៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន នៅពេលនេះ ខ្ញុំសូមអនុញ្ញាតអានអត្ថបទដកស្រង់ចេញពីការសម្ភាសរបស់គាត់ជាមួយនឹងសហចៅក្រមស៊ើបអង្កេត បន្ទាប់មកខ្ញុំនឹងសួរសំណួរបន្តទៀត។ ឯកសារលេខ E3/24។ ខ្មែរ 00204072, ERN ជាភាសាអង់គ្លេស គឺ00223584 រហូតទៅដល់ 223585, បារាំង ERN 00503925។

ខ្ញុំគិតថា យើងបាន -- ខ្ញុំបានផ្តល់ឯកសារនេះរួចមកហើយ។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតដាក់លើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:២០:៥២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីចំណុចដែលខ្ញុំចង់សួរលោកនោះ គឺទាក់ទងសម្តីរបស់លោក ដែលខ្ញុំចង់សួរលោក។ “បញ្ហានេះ គឺមកពីប៉ុល ពត និង នួន ជា គឺមកពីមន្ទីរ៨៧០ ដែលបញ្ជូនព័ត៌មាន និងបញ្ហាទាំង

នោះមកពីសមាជិកគណៈអចិន្ត្រៃយ៍មជ្ឈិមដែលប្រចាំការងារនៅភ្នំពេញ មានដូចជា ប៉ុល ពត, នួន ជា, វន វ៉េត, អៀង សារី និង សុន សេន។ ខៀវ សំផន នៅជិតគណៈនេះដែរ តែខៀវ សំផន គាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ"។ បញ្ចប់ការដកស្រង់សម្តីរបស់លោក។ តើនៅពេលដែលខ្ញុំអាននេះ! លោកនឹកឃើញដែរឬទេ? ហើយលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាតើមានអ្នកណាខ្លះដែលជាសមាជិកគណៈអចិន្ត្រៃយ៍នោះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ក្នុងនេះ គឺថាបាន១ ខ្ញុំបានបញ្ជាក់ហើយថា មានលោកអ៊ំ ប៉ុល ពត, លោកអ៊ំ នួន ជា, វន វ៉េត, លោកអ៊ំ អៀង សារី និង សុន សេន។

[០៩:២២:១៦]

ខៀវ សំផន នៅជិតនោះដែរ តែខៀវ សំផន មិនមែនជាគណៈអចិន្ត្រៃយ៍ទេ។ ត្រង់ចំណុចនេះ ខ្ញុំដឹងថា លោកអ៊ំ អៀង សារី ទេគាត់ប្រាប់ គាត់ថា លោកអ៊ំ ខៀវ សំផន មិនទាន់ចូលជាអចិន្ត្រៃយ៍ទេ។ គាត់ប្រាប់ខ្ញុំអ៊ីចឹង ខ្ញុំក៏ដឹងតាមកម្រិតប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកលើប្រធានបទមួយផ្សេងទៀត។ ខ្ញុំចង់សួរសំណួរពីរបីសំណួរពាក់ព័ន្ធទៅនឹងរយៈកាលដែល អៀង សារី នោះមិននៅក្នុងប្រទេស។ នៅពេលដែលគាត់នៅក្រៅប្រទេសនោះ នៅពេលដែលគាត់ធ្វើដំណើរទៅបរទេសនោះ តើគាត់នៅតែក្តាប់ ក្តោបក្តាប់ក្រសួងការបរទេសទៀតដែរឬទេ?

**ឆ៖** ពេលលោកអ៊ំ អៀង សារី មិននៅក្នុងប្រទេស គឺថាមានអ្នក -- គឺថាទីមួយ គឺខាងប្រាំបី -- កិច្ចការធំ១ហ្នឹង ខាង៨៧០ហ្នឹងហើយអ្នកគ្រប់គ្រង។ ឯនៅផ្ទាល់ នៅក្រសួងការបរទេសហ្នឹងមានបង សួរ ហុង ហ្នឹងហើយ មានបង សួរ ហុង តែប៉ុណ្ណឹងទេ។

**ស៖** តើ អៀង សារី នេះអាចធ្វើការទាក់ទងជាមួយនឹងក្រសួងការបរទេសនៅពេលដែលគាត់នៅឯបរទេសដែរឬទេ?

**ឆ៖** ចំណុចនេះ គឺថាបើគាត់ទៅទស្សនកិច្ចនៅខាងក្រៅប្រទេសហើយ គឺថាអ្វី១ គឺគាត់ឆ្លងតាម៨៧០ទាំងអស់ អត់មានទាក់ទងមកត្រង់មក ប-១ ទេ អត់ទេ។

[០៩:២៥:០០]

**ស៖** តើនរណាគេដែរ ដែលនៅមន្ទីរ៨៧០នោះ ដែលជាអ្នកទទួលបន្ទុក ទទួលការណែនាំពី

អៀង សារី បន្ទាប់មកបញ្ជូនការណែនាំនេះទៅក្រសួងការបរទេសនោះ?

**ឆ៖** ខាង៨៧០ បើថាអ៊ំ ប៉ុល ពត នៅគាត់ចាត់ចែង។ បើគាតមិននៅទេ អ៊ំ នួន ជា។ បើអ៊ំ នួន ជា មិននៅទេ គឺថាមានអ៊ំ ខៀវ សំផន។ មានបីនាក់ហ្នឹង។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ នៅពេលដែល អៀង សារី នៅឯក្រៅបរទេសនោះ តើក្រសួងការបរទេសមានបញ្ជូនព័ត៌មានត្រឡប់ទៅឲ្យ អៀង សារី វិញដែរឬទេ នូវរឿងការងារដែលកំពុងធ្វើនៅក្នុងក្រសួងតាមរយៈមន្ទីរ៨៧០នោះ?

**ឆ៖** ចំណុចនេះគឺថា អាហ្នឹងគឺអាស្រ័យលើបង សួរ ហុង ទេ។ បើថាគាត់មានការពាក់ព័ន្ធរឿងនយោបាយ ក៏ទាក់ទងទៅត្រង់ទៅខាង៨៧០។ ខ្ញុំអត់ដឹងដែរ ល្អិតខ្ញុំអត់ដឹងទេ។ លើបង សួរ ហុង ដែរអាហ្នឹង។

[០៩:២៦:៥៩]

**ស៖** ខ្ញុំសូមសួរលោកដកស្រង់សម្ដីរបស់លោកមួយទៀត នៅក្នុងកិច្ចសម្ភាសន៍របស់លោក គឺឯកសារ E3/24 ដដែល អត្ថបទនេះ ខ្មែរERN គឺ 00204071, អង់គ្លេស ERN គឺ 00223584, បារាំងលេខERN គឺ 00503924។

**លោក ឌេល លីសាក់៖**

យើងខ្ញុំអនុញ្ញាតសូមដាក់នៅលើអេក្រង់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចំណុចដែលខ្ញុំចង់ឲ្យលោកមើលនោះគឺ ត្រង់ចំណុចដូចតទៅ៖ “នៅពេល អៀង សារី នៅក្រៅប្រទេស ហុង ជំនួស។ ប៉ុន្តែ ហុង មិនអាចធ្វើសេចក្ដីសម្រេចនោះទេ។ នៅពេលនៅក្រៅប្រទេសខាងលោក អៀង សារី ទាក់ទងជាមួយនឹងមន្ទីរ៨៧០ បន្ទាប់មកមន្ទីរ៨៧០ ទាក់ទងជាមួយនឹងមន្ទីរ ប-១។ ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចដែលធ្វើឡើងនៅពេលដែល អៀង សារី នៅខាងក្រៅនោះ ការធ្វើសេចក្ដីសម្រេចដូច្នេះគឺត្រូវឲ្យខាងប-១ដែលមាន សួរ ហុង នោះទាក់ទងទៅ អៀង សារី តាមរយៈមន្ទីរ៨៧០។” តើអ៊ីចឹងដែរឬទេ?

[០៩:២៨:៥៣]

ឆ៖ ហ្នឹងហើយ អ៊ីចឹងហើយមែនអ៊ីចឹងហើយ។

ស៖ តើលោកធ្លាប់ទៅទស្សនកិច្ចក្រៅប្រទេសជាមួយនឹងលោក អៀង សារី ដែរឬទេ?

ឆ៖ ខ្ញុំបានទស្សនកិច្ចជាមួយគាត់ម្តងកាលឆ្នាំ៧៦។

ស៖ តើលោកទៅទស្សនកិច្ចនៅប្រទេសណាដែរនៅក្នុងឆ្នាំ៧៦នោះ?

ឆ៖ នៅប្រទេសចិន។

ស៖ តើនៅប្រទេសចិននោះ រយៈពេលទស្សនកិច្ចនោះរយៈពេលប៉ុន្មានដែរ យូរប៉ុនណាដែរ?

[០៩:៣០:១៥]

ឆ៖ ប្រហែលជាង១ កន្លះខែ។

ស៖ តើគណៈប្រតិភូអមជាមួយនឹងលោកនោះ មាននរណាគេខ្លះដែរ ធ្វើដំណើរទៅប្រទេសចិន នោះ?

ឆ៖ ខ្ញុំចាំអត់អស់ទេ ប៉ុន្តែខ្ញុំអាចរៀបរាប់បានខ្លះ។ ក្នុងនុំងទីមួយ អ៊ំ ប៉ុល ពត, ទីពីរ អ៊ំ អៀង សារី ក្រៅពីហ្នឹង ខៀន ដែរ ខៀន ទៅដែរ ខៀន, រស់ ញឹម ដែរ។

ស៖ សូមអរគុណ។ ឥឡូវនេះត្រឡប់ទៅចំណុចមួយ អំពីការតែងតាំង ការចាត់តាំងលោកឲ្យធ្វើការនៅក្រសួងការបរទេស។ អ្នកណាជាអ្នកតែងតាំងចាត់តាំងលោកឲ្យធ្វើការក្នុងមុខតំណែងមួយនៅក្រសួងការបរទេសនោះ?

[០៩:៣១:៥៩]

ឆ៖ តែងតាំងមានតែលោកអ៊ំ អៀង សារី ហ្នឹងហើយ។

ស៖ នៅពេលដែលលោកធ្វើការនៅក្រសួងនោះ តើលោកអាចរៀបរាប់ជម្រាបតុលាការបានទេ ថាតើលោករាយការណ៍ទៅលោក អៀង សារី ដោយរបៀបណា បាទ?

ឆ៖ ជាអចិន្ត្រៃយ៍គឺថា ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រជួបគ្នារហូតក្នុងក្រសួងហ្នឹង អត់មានអី ជួបគ្នាក្នុងក្រសួង។ ហើយបើករណីដែលខ្ញុំជូនភ្ញៀវទៅតាមខេត្ត អាហ្នឹងខ្ញុំមកវិញ ខ្ញុំទៅរាយការណ៍ជូនគាត់នៅ១ផ្ទះ -- នៅកន្លែងបន្ទប់សំណាក់ៗរបស់គាត់។

ស៖ តើការជួបរាយការណ៍ប្រចាំថ្ងៃដែលលោកនិយាយហ្នឹង គឺត្រូវប្រើពេលប៉ុនណាដែរជាមួយលោក អៀង សារី បាទ?

ឆ៖ ការងារខ្លះ ១៥នាទី ការងារខ្លះកន្លះម៉ោងអីអស់ហើយ ប៉ុនហ្នឹងឯង អត់មានច្រើនទេ។

[០៩:៣៣:៥០]

**ស៖** តើការប្រជុំនេះមានតែលោក និងលោក អៀង សារី តើឬៗ មានអ្នកផ្សេងទៀតនៅស្ដាប់ដែរ ប្រជុំដែរនោះដែរ?

**ឆ៖** ពេលខ្លះបីនាក់ មានអ៊ំ អៀង សារី មានបង សួរ ហុង មានខ្ញុំ។ ពេលខ្លះទៀត មានបងៗបញ្ញាជនមួយចំនួននៅក្នុងដែរ ក៏ចូលរួមដែរ។

**ស៖** តើលោករៀបចំរបាយការណ៍លាយលក្ខណ៍អក្សរជូនលោក អៀង សារី ទេ? ឬក៏លោកគ្រាន់តែរាយការណ៍ផ្ទាល់មាត់តាមការជួបប្រចាំថ្ងៃបែបនោះ?

[០៩:៣៥:០០]

**ឆ៖** រាយការណ៍ គឺថាពេលៗដែលមានការងារដែលៗត្រូវធ្វើ គឺមិនមានប្រតិភូទៅមើលទស្សនកិច្ច អាហ្នឹងពិភាក្សាគ្នាមួយភ្លែតៗ អត់សួរច្បាស់ទេ។

**ស៖** លោកសាក្សី ខ្ញុំសូមសួរសំណួរឡើងវិញ។ ក្រៅពីការរាយការណ៍ប្រចាំថ្ងៃជូនទៅលោក អៀង សារី តើលោកជូនរបាយការណ៍លាយលក្ខណ៍អក្សរ បានន័យថាជាក្រដាសទៅគាត់ទេ របាយ-ការណ៍?

**ឆ៖** ពេលខ្លះ គឺថា ពេលដែលជួបគ្នាផ្ទាល់ គឺរាយការណ៍ដោយមាត់។ ពេលខ្លះទៀតគឺមានរបាយការណ៍ដែលជាលាយលក្ខណ៍អក្សរៗអ៊ីចឹង។

**ស៖** ក្រៅពីការជួបគាត់ប្រចាំថ្ងៃ ជួបលោក អៀង សារី ប្រចាំថ្ងៃនោះ តើលោក អៀង សារី បានរៀបចំការប្រជុំណាទៀងទាត់ទេ ជាមួយបុគ្គលិកក្រសួងការបរទេសនោះ?

[០៩:៣៧:២១]

**ឆ៖** ធម្មតា គឺថាមួយខែជួបជុំក្នុងកម្មាភិបាលទទួលខុសត្រូវតាមផ្នែកមួយៗហ្នឹង មួយខែគាត់រៀនសូត្រ ហើយនិងប្រជុំដកពិសោធអីហ្នឹង គេមានអ៊ីចឹង។

**ស៖** ការប្រជុំប្រចាំខែនេះ ថាតើៗលោក អៀង សារី ជាអ្នករៀបចំ ហើយគាត់ធ្វើអធិបតី ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** ពេលខ្លះ លោកអ៊ំ អៀង សារី គាត់ធ្វើ បានពេលខ្លះទៀតបង សួរ ហុង គាត់ធ្វើអ៊ីចឹង។

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យមើលផ្នែកមួយទៀត នៅក្នុងការសម្ភាសលើកទីមួយ ជាមួយសហចៅក្រមស៊ើបអង្កេត និងនៅក្នុងឯកសារ E3/24 ផ្នែកមួយដែលខ្ញុំចង់សួរលោកនោះ គឺនៅខ្មែរ ERN

00204072, អង់គ្លេស ERN 00223584 រហូត 223585, ហើយបារាំង ERN 00503925។

**លោក ខេល លីសាក់៖**

ហើយខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញឯកសារលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[០៩:៣៩:៤២]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ផ្នែកមួយនៃបទសម្ភាសន៍ដែលលោកបានឆ្លើយនោះ មានខ្លឹមសារដូចតទៅ៖ "សំណួរ៖ នៅពេលដែលមានបញ្ហាមកពីថ្នាក់លើ ថាតើលោក អៀង សារី ចែកផ្សាយនៅក្នុងក្រសួងដូចម្ដេច? ឆ្លើយ៖ គាត់បានរៀបចំប្រជុំ។ ខ្ញុំនៅទីនោះ និយាយអំពីនយោបាយ ហើយអំពីបញ្ញវន្តនៅទូទាំងប្រទេស ឬក៏នៅក្នុងភូមិភាគមួយ"។ ចប់សេចក្ដីដកស្រង់។ សំណួរទីមួយ របស់ខ្ញុំចំពោះលោកនោះ ថាតើបញ្ហាដែលលោក អៀង សារី យកមកប្រកាសនៅក្នុងប្រជុំហ្នឹង តើជាបទបញ្ជា ឬក៏បញ្ហាបែបណា?

[០៩:៤០:៤៣]

**លោក រ៉ូចាម តុន៖**

**ឆ៖** ចំណុចនេះ គឺថាធ្លាប់ធ្វើការកន្លងមកនេះ គឺថាយើងមានគោលនយោបាយ គឺថាប្រមូលបញ្ញាជន។ បញ្ញាជនតាមភូមិភាគ បញ្ញាជនដែលមកពីក្រៅ អាហ្នឹងគេថា យើងមានគោលការណ៍ប្រមូល។ ប្រមូលដើម្បីបម្រើការងារនៅក្រសួងការបរទេស អ៊ីចឹង។ ឃើញគាត់បញ្ជាក់ថា យើងត្រូវតែប្រមូលកម្លាំងបញ្ញាជន។ អង្កាល់ហ្នឹង គេនិយាយតែបញ្ញាជនទេ គេអត់សូវមានទេបញ្ញវន្តឯណោះ បញ្ញាជន។ ប្រមូលកម្លាំងបញ្ញាជនជួយធ្វើការងារនៅក្នុងក្រសួងរបស់យើង។ យើងត្រូវមានទស្សនៈច្បាស់លាស់ យើងមិនត្រូវចង្អៀតចង្អល់ចំពោះបងប្អូនបញ្ញាជនទេ អ៊ីចឹង។ ដូច្នេះ អប់រំ។ ក្នុងក្រសួងអប់រំជាទូទៅ គឺថាឲ្យយល់ ឲ្យ ក្នុងបុគ្គលិកក្នុងក្រសួងហ្នឹង ឲ្យយល់ ដើម្បីបម្រើ ព្រោះការងារ បងៗបញ្ញាជនខ្លះ គាត់មានពិសោធខាងការងារទូត។ ការងារទូតទៅធ្វើទូតប្រទេសនេះ ប្រទេសនោះ អ៊ីចឹង។ ដូច្នេះ គេត្រូវប្រមូលគាត់ បានយើងដំណើរការទៅ វាបានលទ្ធផលល្អ។ នេះ ខ្ញុំសូមបញ្ជាក់ដោយខ្លីប៉ុណ្ណឹង។

[០៩:៤២:២៧]

**ស៖** ថាតើមានមន្ទីរ ឬផ្នែកណាមួយ ក្រសួងដែលបញ្ញាជនធ្វើការនៅកន្លែងហ្នឹងដែរឬទេ?

**ឆ៖** បងៗបញ្ញាជនច្រើនតើ នៅនឹងក្រសួងការបរទេសនេះច្រើន។ អត់តិចទេ ច្រើន។

**ស៖** ការប្រជុំប្រចាំខែនៅក្នុងក្រសួង ដែលលោកបានពិភាក្សាកន្លងមកនេះ តើមានអ្នកកត់ត្រាកំណត់ហេតុអង្គប្រជុំប្រចាំខែហ្នឹង ឬទេ?

**ឆ៖** កំណត់ហេតុ គឺថាមាន បង សូ ហុង គាត់ជាកំណត់ហេតុ។

**ស៖** តើមានការប្រជុំធ្វើទិតៀន ស្វ័យទិតៀនដែរឬទេ នៅក្រសួងនោះ?

**ឆ៖** ជាធម្មតា គឺមាន។ ប្រចាំខែ ឬមួយប្រចាំបីខែអី មាន។

**ស៖** តើអ្នកណាខ្លះ ដែលចូលរួមនៅក្នុងការប្រជុំធ្វើទិតៀន និងស្វ័យទិតៀន ដែលលោកបានចូលរួមដែរនោះ?

**ឆ៖** មួយផ្នែក គឺថាក្នុងដឹកនាំរួមក្នុងហ្នឹង គឺថាមាន ដូចថា មានអ៊ំ អៀង សារី, មានបង សូ ហុង អ៊ីចឹង មានបងៗបញ្ញាជន នៅខាង កាន់ខាងនយោបាយហ្នឹងក៏ចូលរួមដែរ។ ហើយនិងផ្នែកៗឧបមាថា រៀបចំផ្ទះ រៀបផ្ទះបាយ បម្រើភ្ញៀវអីទាំងអស់ហ្នឹង មានកម្មាភិបាលមួយចំនួនក៏ចូលរួមដែរធ្វើជាមួយគ្នាហ្នឹង។

[០៩:៤៥:៣៣]

**ស៖** តើលោកចូលរួមការប្រជុំទិតៀននេះជាមួយលោក អៀង សារី ហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បីខែម្តង ហ្នឹងជាមួយគាត់បីខែម្តង។

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយទៀត។

**លោក អាកទួរ វែកគែន៖**

លោកប្រធានខ្ញុំសូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ លោកសាក្សីគាត់អានឯកសារ ខ្ញុំចង់ដឹងថាតើគាត់អានឯកសារអីដែរលោកប្រធាន?

[០៩:៤៦:៤៥]

**ប្រធានអង្គជំនុំ៖**

ឯកសារហ្នឹងយើងបានផ្តល់ឲ្យគាត់ អនុញ្ញាតតាមសំណើសុំរបស់សហព្រះរាជអាជ្ញា ជាកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ E3/24។

សាក្សីមិនចាំបាច់អានទូវឯកសារនុ៎ងទេ នៅពេលណាដែលមានការសួរបញ្ជាក់ដើម្បីឲ្យមានការផ្ទៀងផ្ទាត់ឡើងវិញនូវភាពខុសគ្នារវាងចម្លើយរបស់លោកដែលលោកឆ្លើយ នៅចំពោះមុខអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយផ្ទៀបជាមួយនិងអ្វីដែលលោកបានផ្តល់ចម្លើយនៅទីនេះ ដើម្បីបញ្ជាក់ថា តើចម្លើយណាមួយណាត្រឹមត្រូវ ប៉ុណ្ណោះទេ មិនមែនអាចអានចម្លើយយកមកឆ្លើយទេ។ ហើយទំនងអានមិនទាន់ទេ សំណួរនេះរកមិនឃើញផង។ ប៉ុន្តែមិនគប្បីធ្វើអ៊ីចឹងទេ ដើម្បីឲ្យវាត្រឹមត្រូវគឺលោកទុកឯកសារហ្នឹងសិនទៅ លើកលែងតែពេលណាដែលសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងតម្រូវឲ្យលោកពិនិត្យឡើងវិញនូវខ្លឹមសារនៃចម្លើយណាមួយដែលមានបញ្ហាខុសគ្នា។ ហើយតាមធម្មតាពេលនោះ នឹងមានការបង្ហាញឯកសារនោះ ដល់ផ្នែកដែលពាក់ព័ន្ធនៅលើអេក្រង់កុំព្យូទ័រ ដោយមានគំនូសរង្វង់ពណ៌ក្រហមជុំវិញ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

[០៩:៤៨:៣២]

**លោក ដេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមសួរសាក្សី ហើយនិងបង្ហាញជូនគាត់ផងដែរ នូវឯកសារមួយដែលត្រូវបានអនុញ្ញាតហើយ គឺE3/522។ យើងខ្ញុំមានឯកសារលើក្រដាស ហើយផ្នែកដែលខ្ញុំចង់យោងទៅរកឲ្យសាក្សីពិនិត្យមើលនោះគឺ ចាប់នៅខ្មែរទំព័រ 00427907 រហូតទៅដល់ខ្មែរ ERN ដដែលហ្នឹង គឺ 00427922។ នៅក្នុងអត្ថបទភាសាអង់គ្លេស បកប្រែមកពីខ្មែរគឺទំព័រដែលមានខ្លឹមសារនេះ គឺនិយាយពី គឺ 00003304 ហើយបន្តរហូតទៅដល់ 0003316។ ខ្ញុំមានឯកសារលើកក្រដាស ហើយសូមជូនឯកសារភាសាខ្មែរជូនលោកសាក្សី ដើម្បីលោកពិនិត្យ ដើម្បីនឹងខ្ញុំសួរលោកប្រធាន។

[០៩:៤៩:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[០៩:៥០:០៦]

**លោក ម៉ៃខល កាណាវាស៖**

សូមអនុញ្ញាតលោកប្រធាន ខ្ញុំសូមជំទាស់ទាក់ទងនឹងចំណុចនេះ។ មកដល់ពេលនេះ យើងមិនទាន់បានឮថាមានទំនាក់ទំនង ហើយនិងសាក្សីនេះទេ ឯកសារនេះ។ គឺថាមិនមានមូលដ្ឋានអ្វី ហើយគាត់មិនបានរៀបចំមុនហើយៗ ប្រសិនបើព្រះរាជអាជ្ញាយកឯកសារនេះ គឺថាត្រូវអនុវត្តតាមនីតិវិធីឱ្យបានត្រឹមត្រូវ មុននឹងសួរគាត់នូវសំណួរនោះ។ ខ្ញុំជឿថាយ៉ាងហោចណាស់គឺថា ការបង្ហាញឯកសារជាភស្តុតាងហ្នឹងគឺថា បើចង់បង្ហាញសាក្សី ថាតើឯកសារនេះយកមកពីណា? តើមានចំណងជើងទេ? តើភាគី ឬសហព្រះរាជអាជ្ញាបានបញ្ជាក់ហើយឬនៅ? គឺមិនមានន័យថា ដើម្បីឱ្យសាក្សីបញ្ជាក់អំពីយថាភាពនៃឯកសារនោះទេ ប៉ុន្តែថា តើគោលបំណងនៃការបង្ហាញឯកសារនេះ ដើម្បីរំឭកការចងចាំ ឬជំរុញការចងចាំរបស់សាក្សីនោះបាទ?

[០៩:៥១:១៣]

**លោក ឌេល លីសាក់៖**

ខ្ញុំរីករាយនឹងឆ្លើយតបទៅនឹងមេធាវីការពារ។ មូលដ្ឋានហ្នឹងគឺថា នឹងស្ថិតនៅក្នុងសំណួររបស់ខ្ញុំ ហើយៗ មេធាវីអាចនឹងមើលផ្នែកមួយនៅក្នុងកំណត់ត្រា ដែលខ្ញុំនឹងសួរទៅសាក្សី។ ហើយខ្ញុំមានកំណត់ដែជាច្រើននិយាយអំពីការប្រជុំទិតៀន ដែលមានចំណងជើងថា “គំនិតស្ថាបនាមកពីសមូហភាពនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦” ហើយនិងមានកំណត់ហេតុអង្គប្រជុំជាច្រើនដោយមានការចូលរួមដែលមានឈ្មោះ ជាម, ឈ្មោះ នូ, ឌី, មួន, រឿន, ធី,ហុង ហើយនិង វ៉ាន់ ផងដែរ។ ដូច្នេះសាក្សី គឺនៅក្នុងអ្នកវត្តមានហ្នឹងសាក្សីរូបនេះមានឈ្មោះនៅក្នុងហ្នឹង។ ហើយ ជាម ជាឈ្មោះហៅក្រៅរបស់គាត់។ ដូច្នេះហើយបានជាខ្ញុំស្នើតុលាការដើម្បីឱ្យគាត់ពិនិត្យ ហើយឱ្យគាត់ប្រាប់យើងថាតើនេះជាកំណត់ហេតុអង្គប្រជុំនិយាយពីការប្រជុំទិតៀនដែលគាត់និយាយហ្នឹងដែរឬទេអត់? ប្រសិនបើបែបនោះមែន គឺថាជាចំណុចសមស្របឱ្យគាត់ឆ្លើយសំណួររបស់ខ្ញុំ ផ្អែកលើកំណត់ហេតុអង្គប្រជុំទិតៀនទាំងអស់នេះដែលគាត់បានចូលរួមនោះ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់មេធាវី ម៉ែខល កាណាវាស គ្មានប្រសិទ្ធភាព។ សាក្សីពិនិត្យមើលឯកសារត្រង់ចំណុចពាក់ព័ន្ធជាមុនសិន ហើយដើម្បីបញ្ជាក់ថា តើសាក្សីធ្លាប់ស្គាល់ ឬក៏ធ្លាប់បានដឹងអំពីហេតុការណ៍ដែលពាក់ព័ន្ធនឹងសំណួរដែលប៉ុនប៉ងសួរហ្នឹងដែរឬទេ?

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកប្រធាន នៅក្នុងកំណត់ហេតុទាំងអស់នេះ លោកសាក្សី ទំព័រ ERN 00427920 រហូត 427922 ហើយទាក់ទងទៅនឹងសមមិត្ត ជាម។ ដូច្នេះសូមលោកសាក្សីពិនិត្យមើលផ្នែកមួយនេះ ដើម្បីឲ្យលោកពិនិត្យមើលកំណត់ហេតុអង្គប្រជុំដែលខ្ញុំបង្ហាញជូននេះបាទ។

**លោក វ៉ាចាម គុន៖**

**ឆ៖** កំណត់ហេតុនេះពិតប្រាកដហើយ។ អ៊ីចឹងមែន។

**ស៖** លោកបានបញ្ជាក់ពីខាងដើមនៃការធ្វើសក្ខីកម្មថាៗ ឈ្មោះហៅក្រៅរបស់លោកគឺ ឈ្មោះ វីជាម។ តើគេហៅលោកថា ជាម ផងដែរទេ កាលសម័យនោះបាទ?

[០៩:៥៥:៣៤]

**ឆ៖** ហៅសមមិត្តជាម អ៊ីចឹងហើយ។ អាហ្នឹងហៅកាត់ខ្លី អត់មាន វីជាម អីទេ។ ហៅសមមិត្តជាមៗ ប៉ុណ្ណឹង។

**ស៖** ក្រុមអ្នកចូលរួមក្នុងការប្រជុំទិតៀននេះ ដែលលោកក៏បានចូលរួមដែរ ហើយគេបានថាមនុស្សម្នាក់ឈ្មោះ នូ, ឌីន, នួន, រឿន, ធី, ហុង ហើយនិង វ៉ាន់។ តើលោកនៅចាំថាលោកបានចូលរួមកិច្ចប្រជុំទិតៀន ដែលមានឈ្មោះមនុស្សទាំងប៉ុន្មាននាក់ហ្នឹងដែរឬទេបាទ?

**ឆ៖** កំណត់ហេតុហ្នឹង ពិតមែនហើយ។

**ស៖** លោកបាននិយាយអំពី ហុង រួចហើយ។ មនុស្សម្នាក់ដែលឈ្មោះ វ៉ាន់ នៅក្នុងហេតុនេះ តើ វ៉ាន់ នេះអ្នកណា?

**ឆ៖** អ៊ំ អៀង សារី ហើយ ពេលនោះគេហៅគាត់ឈ្មោះ បងវ៉ាន់ៗ។

**ស៖** មនុស្សផ្សេងទៀតដែលបានចូលរួមនៅក្នុងការប្រជុំនោះដែរ គឺសមមិត្តខ្ញូ, នាន, មួន, រឿន ហើយនិង ធី។ តើលោកអាចប្រាប់តុលាការទេ តើឈ្មោះអ្នកទាំងអស់នោះឈ្មោះពេញអ្វី ហើយមុខងារគាត់ធ្វើអ្វីដែរ?

[០៩:៥៦:៣០]

**ឆ៖** ឈ្មោះទាំងអស់នោះគឺ នៅហ្នឹង បម្រើការងារនៅក្រសួងហ្នឹងហើយ។ គឺការងារខ្លះ ដូចខ្ញុំបានបញ្ជាក់អំមិញហ្នឹង គឺថា ខ្លះខាងរៀបចំផ្ទះ ខ្លះទៀតខាងទទួលភ្ញៀវ ខ្លះទៀតខាងផ្ទះបាយ ខ្លះទៀតខាងជូនភ្ញៀវអីចឹង វាមានហូរហែអីចឹង។

**ស៖** ចាតើអ្នកណាជាអ្នកកត់កំណត់ហេតុនៅការប្រជុំទិតៀននេះ លោកចាំទេ?

**ឆ៖** ខ្ញុំអត់ចាំទេច្រើនពេក។ អត់ទេ យូរឆ្នាំដែរហើយ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលផ្នែកមួយដែលនិយាយពីការធ្វើស្វ័យទិតៀន ចំពោះលោក ខ្មែរ ERN 00427920។ ការបកប្រែទៅជាអង់គ្លេសនោះ គឺ 00003315, បារាំង បកប្រែទៅជាភាសាបារាំង 00657885។

**លោក ឌេល លីសាក់៖**

ដើម្បីខ្ញុំអាចនឹងសួរបានសូមអនុញ្ញាតលោកប្រធាន គឺថា យើងមានការបកប្រែបារាំងនោះមានបញ្ហា។ ខ្ញុំសូមជម្រាបដល់តុលាការ និងភាគីថា គឺថាខាងបកប្រែគឺថាៗវាមានបាត់ទំព័រខ្លះគឺៗមិនបានរៀបរយល្អទេ។ ខ្ញុំមិនបានឃើញតាមលំដាប់លំដោយទេនៅក្នុងការបកប្រែជាភាសាបារាំងនេះ។ ដូច្នេះខ្ញុំសូមជម្រាបជូនតុលាការ និងភាគីថា សូមឲ្យធ្វើបច្ចុប្បន្នភាព ការបកប្រែភាសាបារាំងវិញ។

[០៩:៥៩:៤៩]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ផ្នែកមួយនៃកំណត់ហេតុអង្គប្រជុំនេះ លោកសាក្សី -- ផ្នែកមួយនៃកំណត់ហេតុដែលខ្ញុំឲ្យលោកពិនិត្យមើលនេះ គឺផ្នែកមួយដែលមានចំណងថា "ជីវទស្សនៈបដិវត្តន៍សមមិត្ត ជាម" ហើយនៅក្នុងផ្នែកនេះ គឺមានការទិតៀន ថាមិនគឺមិនបានខ្វះខាតទស្សនៈ មិនទាន់ត្រឹមត្រូវ ទស្សនៈធាតុ វណ្ណៈអធនភារកិច្ចដែលបក្សប្រគល់ឲ្យ។ តើលោកនៅចាំទេ លោកបានលើកធ្វើការស្វ័យទិតៀនមួយបែបនេះ នៅក្នុងការប្រជុំមួយនោះនុះ?

**ឆ៖** បើមានក្នុងកំណត់ហេតុអីចឹង វាចេញអីចឹង គឺអីចឹងហើយ។ ស្វ័យទិតៀនអីចឹងហើយពេលនោះ។ គេថាគ្រប់ៗគ្នា គេធ្វើតែអីចឹង។

**ស៖** នៅក្នុងផ្នែកមួយនៃកំណត់ហេតុនេះ មានផ្នែកមួយដែលខ្ញុំទើបតែបានបញ្ជាក់ហ្នឹង មានចំណងជើងថា "ជីវទស្សនៈបដិវត្តន៍សមមិត្ត ជាម" នៅបន្ទាប់ពីផ្នែកនេះទៅ គឺមានផ្នែកមួយទៀតដែល

មានចំណាងជើងថា "យោបល់របស់ វ៉ាន់។ សមមិត្តវ៉ាន់ អំពី សមមិត្ត ជាម"។ តើនេះបែបបទគំរូសម្រាប់ធ្វើការស្វ័យទិតៀន ហើយបន្ទាប់មកគឺដើម្បីឲ្យថ្នាក់លើ គឺលោក អៀង សារី ដើម្បីបញ្ចេញយោបល់ទៅលើការស្វ័យទិតៀនហ្នឹងឬទេ?

**ឆ៖** អឺ! ពិតប្រាកដអ៊ីចឹងហើយ។ កាលណាយើងសាមីខ្លួនយើង ស្វ័យទិតៀន គឺគាត់មកពីលើយើង គាត់ជួយយោបល់ហើយអាហ្នឹង ជួយយោបល់ ជួយមតិ ជួយអ៊ីចឹងហើយ។

[១០:០២:៣០]

**ស៖** នៅក្នុងមតិរបស់បង វ៉ាន់ ដែលឈ្មោះ អៀង សារី -- អៀង សារី ហៅ វ៉ាន់ នេះពាក់ព័ន្ធទៅនឹងលោក។ កំណត់ហេតុនេះ គឺបាននិយាយអំពីគុណសម្បត្តិដែលថា លោកស្មោះត្រង់ និងលាក់ការណ៍សម្ងាត់។ នៅក្នុងចំណុចលេខបួន និងលេខប្រាំពីរ គឺគេនិយាយថា លោកហ្នឹងឯករាជ្យមានគំនិតឯករាជ្យ សេរីក្នុងការនិយាយស្តី។ តើលោកនឹកឃើញទេ នៅពេលដែលគេផ្តល់មតិដូច្នេះ។ អៀង សារី បានធ្វើមតិដូច្នេះចំពោះលោកនៅក្នុងវគ្គ ជីវបដិវត្តន៍នោះ?

**ឆ៖** ពិតប្រាកដអ៊ីចឹងហើយ។

**ស៖** តើលោកអាចជម្រាបជូនតុលាការដែរឬទេ? ហេតុអ្វីបានជាគេចាត់ទុកថា ជាកំហុសមួយនោះ ប្រសិនបើយើងសេរីក្នុងការនិយាយស្តីនោះ?

**ឆ៖** ចំណុចនេះគេចង់និយាយថា មនុស្សយើងម្នាក់ៗ វាមានចំណុចខ្លាំង វាមានចំណុចខ្សោយ។ ចំណុចខ្លាំងដូចការដែលយើងយល់ឃើញ ការដែលយើងទទួលខុសត្រូវដល់កម្រិត។ ឧបមាថា អ៊ីចឹង។ ឯការខ្វះខាត ពេលខ្លះវាចន្លោះដែរ វា យើងខ្លួនយើងរកដល់នឹកមិនឃើញទេ។ ទាល់តែមតិពីក្រៅនេះគេជួយមកដើម្បីឲ្យយើងយកទៅពិចារណាសម្រាប់បំពេញភារកិច្ចតទៅទៀត។ វាមានន័យអ៊ីចឹង។

[១០:០៥:០៦]

**ស៖** ប្រសិនបើលោកមើលត្រង់ខ្មែរ ERN ៗនោះគឺ 00427927, អង់គ្លេសគឺ 00003320។ ចំណុចត្រង់ទំព័រនោះ គឺទំនងជាបង្ហាញនូវទំព័រចុងក្រោយនៃកំណត់ហេតុជីវទស្សនៈបដិវត្តន៍ ដែលថាត្រង់ផ្នែកដែលខ្ញុំចង់ឲ្យលោកមើលនោះគឺ៖ "មតិនៅក្នុងវគ្គបិទចុងក្រោយខែធ្នូ ឆ្នាំ១៩៧៦"។ អ្វីដែលខ្ញុំចង់សួរឡើង -- សួរលោកនោះគឺថា តើវគ្គស្វ័យទិតៀននេះគេរៀបចំញឹកញាប់ប៉ុនណាដែរ? តើវគ្គរៀនសូត្រនេះ គេរៀបចំញឹកញាប់ប៉ុនណាដែរ?

**ឆ៖** សម័យបីឆ្នាំហ្នឹងគឺថា ខ្ញុំរៀនបានតែវគ្គធំអ៊ីចឹង រៀនបានតែម្តងទេ ម្តងក្នុងឆ្នាំ៧៦ ហ្នឹងឯង។

វគ្គហ្នឹងគេហៅជាវគ្គ -- វគ្គនេះជិតមួយខែឯណោះ។ ហ្នឹងកម្លាំងដែលមករៀនទូទាំងប្រទេសហ្នឹងជាង ១.០០០នាក់ ឯណោះ។

[១០:០៦:៤៥]

**ស៖** វគ្គនេះគេរៀបចំតែសម្រាប់កម្មាភិបាលមកពីក្រសួងការបរទេសតែប៉ុណ្ណោះ ឬក៏សម្រាប់កម្មាភិបាលមកពីតាមក្រសួង និងមន្ទីរផ្សេងទៀត?

**ឆ៖** ទូទាំងៗកម្ពុជាទាំងមូលហ្នឹង ហើយនិងនៅឯទីក្រុងភ្នំពេញ គឺថាមន្ទីរដែលពាក់ព័ន្ធ ក្រសួងពាក់ព័ន្ធអីចូលរួមទាំងអស់។ អត់មានមន្ទីរនៅចន្លោះទេ ឲ្យតែៗមន្ទីរ ឲ្យតែក្រសួង គឺចូលរួមទាំងអស់។

**ស៖** តើនរណាជាអ្នកធ្វើបទខឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រ ដែលលោកបានចូលរួមក្នុងខែធ្នូ ឆ្នាំ៧៦ នោះ?

**ឆ៖** ទីមួយ អ៊ំ ប៉ុល ពត, ទីពីរ អ៊ំនួន ជា។

**ស៖** តើលោកចាំទេ មានប្រធានបទអ្វីខ្លះ ដែលគេយកទៅពិភាក្សានៅក្នុងវគ្គរៀនសូត្រខែធ្នូ ឆ្នាំ ១៩៧៦ នោះ?

**ឆ៖** ខ្ញុំចាំមិនបានល្អិតទាំងអស់ទេ គឺថារួចដូចខ្ញុំបញ្ជាក់អ៊ីចឹង គឺថាទីមួយ ទស្សនៈសភាពការណ៍ទាំងក្នុង -- ក្រៅប្រទេស ក្នុងប្រទេស ហើយទីពីរ ការកសាងៗបក្ស។ ទាំងអស់ តាំងពីលើដល់ក្រោមហ្នឹងគឺថា ឯកសារគឺតែមួយហ្នឹងហើយ។ ដល់ហ្នឹងពិគ្រោះពិភាក្សាចំណុចខ្លាំង ហើយចំណុចខ្សោយក្នុងការអនុវត្តចលនាហ្នឹង ចំណុចខ្លាំងអី ចំណុចខ្សោយអី ហើយដកស្រង់ពិសោធន៍ទៅហើយ ហើយកែលម្អអ៊ីចឹង។ ដល់អ៊ីចឹងហើយ គឺថាម្នាក់ៗត្រូវធ្វើៗស្វ័យទិតៀនខ្លួនឯង ហើយស្វ័យទិតៀនខ្លួនឯង ហើយមានសមាជិកនេះហ្នឹង គឺថាគេជួយយោបល់។ ជួយៗជាមតិ ហើយនិងប្រធានអង្គប្រជុំសរុប។

[១០:០៩:៣១]

សរុបចំណុចខ្លាំងអី ចំណុចខ្សោយអី ហើយកែលម្អ -- តទៅមុខទៀតត្រូវកែលម្អបែបណា គឺអ៊ីចឹង ធ្វើៗអ៊ីចឹង។

**ស៖** នៅពេលនេះ គឺខ្ញុំសូមចូលទៅផ្នែកមួយទៀត នៅក្នុងឯកសារនេះដើម្បីសួរលោក។ ផ្នែកដែលលោក -- ផ្នែកដែលខ្ញុំចង់បង្ហាញជូនលោកនៅពេលនេះ គឺចាប់ផ្តើមដោយលេខខ្មែរ ERN 00427932 តទៅដល់លេខ 4227949។ លេខ ERN ជាភាសាអង់គ្លេសគឺ 00003324 ទៅដល់ 3337។ ប្រសិនបើលោកមើលត្រង់ទំព័រទី១ ត្រង់លេខ 427932 មានចំណងជើងថា "កំណត់ហេតុ

ចេញមកពីថ្ងៃទី១៨ ខែមករា ឆ្នាំ៧៧" គឺសន្និបាតថ្ងៃទី១៨ ខែមករា ឆ្នាំ៧៧។ ប្រសិនបើលោកមើលត្រង់ទំព័រទី១ ហើយត្រង់ទំព័រចុងក្រោយ គឺខ្មែរ ERN 00427949, អង់គ្លេសគឺ 00003336។ នៅក្នុងនេះ គឺមានបញ្ជីចាត់តាំងដែលក្នុងនោះមាន៖ "បងវ៉ាន់ ជាលេខា, លេខ២ សមមិត្ត ហុង អនុលេខា, លេខ៣ សមមិត្ត រឿន សមាជិក, លេខ៤ សមមិត្ត វ៉ែន សមាជិក, លេខ៥ សមមិត្ត ជាម សមាជិក"។ សំណួរទីមួយរបស់ខ្ញុំនោះគឺ តើលោកអាចជម្រាបបានដែរឬទេ គណៈសាខាក្រសួងនោះគឺជាអ្វីដែរ?

[១០:១២:១៥]

**ឆ៖** គណៈសាខាក្រសួងនេះ គឺថាសាខាហ្នឹង គឺឧបមាថាក្នុងក្រសួងការបរទេសហ្នឹង គឺវាមានសាខាៗផ្ទៃក្នុងអាហ្នឹង សាខាផ្ទៃក្នុង គ្រប់គ្រងផ្ទៃក្នុង ផ្ទៃក្នុងបក្សហ្នឹង គឺអ្នកណាដែលបក្ខជនហ្នឹង គឺថា គឺត្រូវគ្រប់គ្រងរបៀបហ្នឹងហើយ។

**ស៖** ចំណងជើងនៅក្នុងកំណត់ហេតុនេះគឺ "សន្និបាតថ្ងៃទី១៨ ខែមករា ឆ្នាំ៧៧"។ តើលោកអាចជម្រាបទេ សន្និបាតសាខាបក្ស -- សាខាក្រសួងនេះ គឺជាអ្វីដែរ ហើយគេរៀបចំឡើងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ក្នុងរយៈបីឆ្នាំតែម្តងទេ ប្រជុំបានតែម្តងទេ។ ធម្មតាបួនឆ្នាំម្តង។

**ស៖** តើអ្នកដែលចូលរួមនៅក្នុងសន្និបាតសាខានេះ គឺជាសមាជិកនៅក្នុងសាខាក្រសួងហ្នឹងដែលជាអ្នកចូលរួម ឬក៏មានសមាជិកណាផ្សេងមកពីសាខាក្រសួងផ្សេងទៀតចូលរួម?

[១០:១៤:២៣]

**ឆ៖** សាខាហ្នឹង គេមានតែក្នុងសាខាក្រសួងការបរទេសទេ។ នែ៎ក្រសួងអីផ្សេង គេធ្វើរបៀបក្រសួងការបរទេសហ្នឹង គេធ្វើបែបរបស់គេហ្នឹង របស់ក្រសួងមួយគេម្ចាស់ការខ្លួនគេដែរ។ អានេះវាសម្រាប់តែក្រសួងការបរទេសទេ សន្និបាតហ្នឹង។ នេះគេដាក់ហើយតើ ដាក់ថា សន្និបាតសាខា។

**ស៖** តើលោកចាំទេ មានមនុស្សប្រហែលជាប៉ុន្មាននាក់ដែរ ដែលចូលរួមក្នុងសន្និបាតសាខានេះ?

**ឆ៖** មនុស្សប្រហែល៣០នាក់ ក្នុងក្រសួងហ្នឹង។

**ស៖** តើសន្និបាតសាខានេះ រៀបចំរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** ពីរថ្ងៃទៅបីថ្ងៃអស់ហើយ។

**ស៖** តើនរណាគេជាប្រធាន ឬជាអធិបតីនៅក្នុងសន្និបាតសាខានោះ ហើយជាអ្នកធ្វើបទឧទ្ទេសនាមចាប់ផ្តើមនៅក្នុងសន្និបាតសាខានេះ?

**ឆ៖** គឺមានតែលោកអ៊ំ អៀង សារី ហើយនិងបង សួរ ហុង។

[១០:១៦:២៨]

**ស៖** នៅទីនេះ គឺថាកំណត់ហេតុដែលក្នុងនេះនិយាយអំពីសកម្មភាពរបស់សាខានៅក្នុងឆ្នាំ១៩៧៦ ចំណងជើងនៅក្នុងឯកសារនេះ គឺក៏បាននិយាយថា "ទស្សនៈស្ដីអំពីបដិវត្តន៍កម្ពុជា" ផ្នែកបន្ទាប់ គឺនិយាយអំពី "ផែនការរបស់សាខាក្រសួងឆ្នាំ៧៧"។ ខ្ញុំចង់ឲ្យលោកផ្ដោតទៅលើទស្សនៈស្ដីអំពីបដិវត្តន៍កម្ពុជា។ ខ្មែរ ERN គឺ 00427940 ទៅដល់ 427941, អង់គ្លេស ERN គឺ 00003330 រហូតទៅដល់លេខ3332។ ប្រសិនបើលោកមើលត្រង់ទំព័រក្នុងកំណត់ហេតុសៀវភៅនេះ ចាប់ផ្ដើមដោយខ្មែរ ERN 00427940 មានចំណុចមួយ មានផ្នែកមួយនោះដែលថា និយាយអំពីសភាពការណ៍ខ្មាំងនៅក្នុងប្រទេសកម្ពុជា។

**លោក ខេល លីសាក់៖**

ខ្ញុំសូមអានត្រង់ចំណុចនោះ លោកប្រធាន ដើម្បីឲ្យមានការបកប្រែត្រឹមត្រូវនោះ ខ្ញុំសូមឲ្យខាងផ្នែកជាតិនេះ ខាងឲ្យខាងសហព្រះរាជអាជ្ញាជាតិនេះ អានជាភាសាខ្មែរឲ្យបានត្រឹមត្រូវ បន្ទាប់មកខ្ញុំនឹងសួរសំណួរទៅតាមអ្វីដែលបានអាន។ សូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! សូមអញ្ជើញ!

[១០:១៨:២៦]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមដកស្រង់ខ្លឹមសារ៖ "១៩៧៦ ជាឆ្នាំគន្លឹះ។ ខ្មាំងសព្វថ្ងៃនេះ មានសភាពទ្រុឌទ្រោម និងឈានទៅស្លាប់។ បដិវត្តន៍បានគាស់រំលើងឫសគល់ ខ្សែចារកម្មត្រូវកម្ទេច។ និយាយជាវណ្ណៈ ខ្មាំងអស់ហើយ តែវានៅមានចក្រពត្តិអាមេរិក, សេ.អ៊ី.អា, កា.ហ្សេ.បេ, វៀតណាម។ ទោះជាបរាជ័យ តែវានៅតែតទៅទៀត។ មួយទៀត ខ្មាំងសត្រូវ ពួជខ្លួនយើង កងទ័ព កម្មករ សហករណ៍ ដែលនៅក្នុងជួរយើង ការធ្វើបដិវត្តន៍សង្គមនិយមជ្រាលជ្រៅខ្លាំងក្លា សត្រូវនេះត្រូវបោសសម្អាតជាបន្តបន្ទាប់ទើបបាន"។ បាទ សូមអរគុណ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** សំណួរទីមួយដែលខ្ញុំចង់សួរលោកនោះគឺ តើស្ថានភាពពាក់ព័ន្ធទៅនឹងខ្មាំងខាងក្នុង និងខ្មាំង

ខាងក្រៅនោះ ជាប្រធានបទមួយដែលត្រូវបានគេយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រសួងនោះដែរឬទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** ធ្វើសន្និបាតរបៀបនេះ គឺថាមិនមែនតែក្រសួងទេ មួយទូទាំងប្រទេសធ្វើតែអ៊ីចឹង ដូចគ្នាហ្នឹង។ ក្នុងក្រសួងក៏ធ្វើ មួយមន្ទីរក៏ធ្វើ តាមមូលដ្ឋានជនបទក៏ធ្វើ ធ្វើដូចតែគ្នាហ្នឹង។ ខ្មាំងដែលគេបញ្ជាក់គ្នា គឺខ្មាំងចក្រពត្តិអាមេរិក និងបរិវារហ្នឹង។ វាច្បាស់ណាស់អាហ្នឹង គេឃើញច្បាស់ហើយអាហ្នឹង។ យើងបានវ៉ៃរំដោះ បានពេលនោះគឺថាធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ វ៉ៃប្រជាជាតិប្រជាធិបតេយ្យ យើងវ៉ៃចក្រពត្តិអាមេរិកវាដួលរលំទៅ ហើយវ៉ៃប្រជាធិបតេយ្យគឺវ៉ៃរបបសក្តិភូមិ នាយទុន ប្រតិកិរិយា។ យើងវ៉ៃជារបប យើងបានវ៉ៃមែន អាហ្នឹងគឺវ៉ៃអ៊ីចឹង។ ហើយឲ្យយើងកសាងផ្ទៃក្នុងយើងនោះ គឺថាម្នាក់ៗ គឺថាត្រូវតែកសាងឲ្យម៉ឺងម៉ាត់ កុំឲ្យលាយលំជាមួយចក្រពត្តិអាមេរិក កុំឲ្យម៉ឺងម៉ាត់ជាមួយសក្តិភូមិ ប្រតិកិរិយាន៎ុង គឺធ្វើជាមនុស្សល្អ មនុស្សត្រឹមត្រូវ អាហ្នឹងគឺធ្វើអ៊ីចឹងឯង។

[១០:២១:២៦]

**ស៖** តើនរណាគេជាអ្នកធ្វើឧទ្ទេសនាមពាក់ព័ន្ធទៅនឹងសភាពខ្មាំងនៅក្នុងពេលសន្និបាតនោះ? តើអ្នកណាជាអ្នកធ្វើឧទ្ទេសនាមលើប្រធានបទមួយនេះ?

**ឆ៖** លោកអ៊ំ អៀង សារី ហើយគាត់អ្នកឧទ្ទេសនាម ព្រោះគាត់ទទួលខុសត្រូវរួមក្នុងសន្និបាតហ្នឹង គាត់ជាគណៈអធិបតីផុតលេខនៅក្នុងក្រសួង គឺគាត់ហ្នឹងហើយ គ្មានពីណាទេ។

**ស៖** ប្រសិនបើលោកមើលទំព័របន្ទាប់ទៀត ខ្មែរ ERN គឺ 00427941, អង់គ្លេស ERN គឺ 00003331។ ខ្ញុំចង់ឲ្យលោកផ្តោតទៅលើចំណុចដែលនិយាយអំពីទំនាស់បដិបក្ខ។ ចំណុចដែលមាននោះ គឺខ្ញុំសូមដកស្រង់សម្តី៖ "ទំនាស់រវាងបក្ស និងប្រឆាំងបដិវត្តន៍ជាបដិបក្ខ បើមានត្រូវប្រគល់ឲ្យសន្តិសុខផ្តាច់ការកម្មជីព គឺត្រូវស្រាវជ្រាវលើបញ្ហារបស់វា។ ចំពោះទំនាស់បដិបក្ខគ្មានអប់រំដាច់ខាត"។ តើនរណាគេដែរ ដែលជាអ្នកផ្តល់ការណែនាំដូច្នេះពាក់ព័ន្ធទៅនឹងទំនាស់រវាងបក្ស និងទំនាស់ផ្ទៃក្នុងបក្សនោះ?

[១០:២៣:៣៩]

**ឆ៖** ចំណុចនេះ គឺថាលោកអ៊ំ អៀង សារី ដដែល គាត់វែកញែកឲ្យឃើញច្បាស់ចំណុចនេះ។ ទំនាស់បដិបក្ខហ្នឹងយ៉ាងម៉េច? ទំនាស់ គេហៅថា ក្នុងទស្សនៈគោលជំហរដែលវានៅស្រពិចស្រពិល

វាមិនជ្រះថ្លា វាមិនជ្រះស្រឡះ អាហ្នឹងយើងត្រូវតែកែលម្អ តាមរយៈយើងស្វ័យទិតៀន ហើយតាមរយៈការកសាង តាមរយៈការសរុបមតិហ្នឹង ដើម្បីកែលម្អតទៅមុខទៀត។ ទំនាស់បដិបក្ខ ហ្នឹងគឺថា ដូចក្នុងនេះបានបញ្ជាក់ហើយថា បើថាបដិបក្ខហើយទៅនៅជាមួយគ្នាអាម៉េចកើត។ អាហ្នឹងបើវាបដិបក្ខហើយវានៅជាមួយគ្នាអត់បានទេ។ តែមួយធាតុបដិវត្តន៍ មួយទៀតធាតុបដិបក្ខហើយ គឺវានៅមិនបានទេ។ វាត្រូវបែងចែកគ្នាឲ្យច្បាស់ចំណុចហ្នឹង។ អាហ្នឹងគេត្រូវតែមានវិធានការហើយ វិធានការយ៉ាងម៉េច? វិធានការថា ឥឡូវទៅកន្លែងអប់រំទៅ ទៅកន្លែងវៃថ្ម ទៅកន្លែងបង្កបង្កើនផល កន្លែងធ្វើស្រែធ្វើចម្ការអីចឹងទៅ។ អាហ្នឹងគេកែលម្អ គឺតាមវិធីអីចឹង។ បើថាបដិបក្ខហ្នឹងវាប្រឆាំងបដិវត្តន៍ដាច់ខាតនោះ បើទុកឲ្យពួកហ្នឹងរស់ បដិវត្តន៍វាងាប់បាត់ទៅហើយ។ អានេះបដិវត្តន៍គេ ទៅចាត់ចែងតាមសភាពការណ៍ជាក់ស្តែងរបស់វាអីចឹងឯង។ ត្រូវចាត់ចែងហ្នឹងហើយ។ ត្រូវធ្វើអីៗទៅតាមទោសកំហុសរបស់បុគ្គលម្នាក់ៗដែលអំពើប្រព្រឹត្តហ្នឹង គឺធ្វើតាមហ្នឹង។

**ស៖** ផ្នែកបន្ទាប់ទៀត នៅក្នុងកំណត់ហេតុសន្និបាតសាខានេះ គឺពាក់ព័ន្ធទៅនឹងផែនការរបស់សាខាក្នុងឆ្នាំ១៩៧៧ ខ្មែរ ERN គឺ 00427942, អង់គ្លេស ERN គឺ 00003332។ តើនរណាគេដែរដែលធ្វើបទឧទ្ទេសនាមពាក់ព័ន្ធទៅនឹងផែនការរបស់សាខាក្នុងឆ្នាំ១៩៧៧ នោះ?

[១០:២៦:២៩]

**ឆ៖** ឧទ្ទេសនាមមានអ៊ំ អៀង សារី ដដែល។ ឧទ្ទេសនាម *(ឮមិនច្បាស់)* ផែនការបន្តទៅទៀតលើគាត់ហ្នឹង។

**ស៖** ផែនការសាខានេះ តើធ្វើឧទ្ទេសនាមដោយផ្ទាល់មាត់ ឬក៏ផែនការសាខានេះត្រូវបានគេចែកជូនជាឯកសារលាយលក្ខណ៍អក្សរដែរ?

**ឆ៖** គឺឧទ្ទេសនាមផ្ទាល់មាត់ មិនទាន់មានឯកសារចែកទេ។

**ស៖** នៅក្នុងផ្នែកដំបូងនៃកំណត់ ផែនការសាខាឆ្នាំ៧៧ នេះចែងដូចតទៅ៖ "ចំណុចពិសេសក្នុងឆ្នាំ១៩៧៧ នេះដែលសាខាត្រូវយកចិត្តទុកដាក់គឺ ការប្រុងប្រយ័ត្នបដិវត្តន៍ឲ្យបានខ្ពង់ខ្ពស់ជាប់ជានិច្ចម្ចាស់ការជាមុនលើខ្មាំងសត្រូវទាំងក្នុងទាំងក្រៅ" បញ្ចប់ការដកស្រង់សម្តី។ តើលោកចាំដែរឬទេ ថាលោកបានទទួលការណែនាំដូច្នេះ គឺត្រូវមានបដិវត្តន៍ប្រុងប្រយ័ត្នឲ្យបានខ្ពស់ជាប់ជានិច្ច ម្ចាស់ការជាមុនលើខ្មាំងសត្រូវទាំងក្នុង ទាំងក្រៅនោះ?

**ឆ៖** បានទទួលតើមតិហ្នឹង បានទទួល។

**សៈ** តើលោកចាំដែរឬទេ នៅក្នុងពេលណាដែរ ក្នុងអំឡុងឆ្នាំណាដែរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែលគេប្រាប់លោកឲ្យមានបដិវត្តន៍ប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ចចំពោះខ្មាំងនោះ?

[១០:២៩:០៥]

**ឆៈ** ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ហ្នឹង តាំងពីចូលធ្វើបដិវត្តន៍មក ណែនាំរហូតតាំងពីដើមទីតែម្ដង។

**សៈ** ប្រសិនបើលោកមើលត្រង់ទំព័រលេខ ERN 00427945 ទៅដល់ 427946, ERN ជាភាសាអង់គ្លេសគឺ 0000334 ដល់ 335។ មានផ្នែកមួយ ពាក់ព័ន្ធទៅនឹងមុខងាររបស់មន្ទីរ ដែលខ្ញុំចង់ស្នើសុំសួរលោកផងដែរ។ ពាក់ព័ន្ធទៅនឹងការងារមន្ទីរ ចំណុចដែលពាក់ព័ន្ធទៅនឹងការងារមន្ទីរ។ ចំណុចនេះគឺត្រង់ទំព័រខ្មែរ ERN 00427945 ចំណងជើងគឺការងារមន្ទីរ ដែលមានដូចតទៅ៖ "ត្រូវយកចិត្តទុកដាក់បំពាក់បំប៉ន -- ត្រូវយកចិត្តទុកដាក់ដោយមានផែនការសមមិត្តជាមួយនឹងប្រទេសមិនចូលបក្សសម្ព័ន្ធ។ ហើយត្រូវយកចិត្តទុកដាក់ទៅលើចំណុចនេះ"។ តើលោកចាំដែរឬទេ ដែលថាគេឲ្យលោកយកចិត្តទុកដាក់ទៅលើប្រវត្តិរូបរបស់កម្មាភិបាលក្នុងបក្សនោះ?

**ឆៈ** អាហ្នឹងជាការងារផ្ទៃក្នុង។ ចាំបាច់គឺត្រូវតែចាំអ៊ីចឹងតែម្ដង។

[១០:៣១:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវហ្នឹងដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយ -- អ៊ំ! ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់។ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី នៅពេលដែលមុនសម្រាកនេះ យើងបាននិយាយអំពីប្រវត្តិរូប តើលោកអាចជម្រាបខ្ញុំបានទេ ថាតើកម្មាភិបាលទាំងអស់ដែលធ្វើការនៅក្រសួងនោះ គឺត្រូវតែផ្តល់ប្រវត្តិរូបនោះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ត្រូវតែមានផ្តល់ប្រវត្តិរូបទាំងអស់ហ្នឹងឯង។

[១០:៥៣:៤១]

**ស៖** យើងបានពិនិត្យមើលផ្នែកមួយនៃកំណត់ហេតុចុះថ្ងៃ -- ឆ្នាំ១៩៧៧ ពីផែន -- សន្និបាតសាខានោះ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកពិនិត្យមើលលើផ្នែកខាងចុង នៅខ្មែរទំព័រ 00427948, អង់គ្លេស ERN 0003336 ផ្នែកនៅក្នុងកំណត់ហេតុនេះគឺមានចំណងជើងថា៖ "មាគ៌ាថ្នាក់ដឹកនាំ ដើម្បីអនុវត្តឲ្យបានគ្រប់ផែនការឆ្នាំ១៩៧៧"។ អត្ថបទខ្មែរនោះគឺ 00427948 បាទ។

នៅក្នុងផ្នែកមួយដែលថា មាគ៌ាថ្នាក់ដឹកនាំដើម្បីសម្រេចឲ្យបានផែនការឆ្នាំ១៩៧៧ នោះ គឺមានខ្លឹមសារថា៖ "យើងមិនត្រូវអនុញ្ញាតឲ្យមហាជនក្នុងក្រសួងដឹងផែនការរបស់យើងទេ"។ ចប់សេចក្តីដកស្រង់។ តើអ្នកណាជាអ្នកផ្តល់ការណែនាំបែបនេះ? តើលោកនៅចាំទេ?

**ឆ៖** ក្នុងសន្និបាតហ្នឹងគឺថា មានតែអ៊ំ អៀង សារី ហ្នឹងហើយគាត់អ្នកឧទ្ទេសនាមបញ្ជាក់ចំណុចណា ចំណុចផ្ទៃក្នុងកម្មាភិបាលដែលត្រូវហ្នឹង មិនអាចដឹងជាទូទៅទេ ដឹងតែក្នុងក្របខ័ណ្ឌចង្អៀតក្នុងដឹកនាំសំខាន់ៗ ដែលនៅក្នុងក្រសួងហ្នឹង។

[១០:៥៦:៣០]

**ស៖** តើលោកនៅចាំទេ ជាទូទៅថាតើបញ្ហាទូទៅ ដែលថាគេសម្រេចផ្ទៃក្នុងដែលត្រូវរក្សាការ

សម្ងាត់មិនឲ្យកម្មាភិបាលផ្សេងទៀតក្នុងក្រសួងដឹងនោះ ថាតើមានបញ្ហាអ្វីខ្លះ?

**ឆ៖** ខ្ញុំមិនចាំទេ យូរឆ្នាំហើយភ្លេចអស់ហើយ។

**ស៖** ផ្នែកមួយនៅក្នុងកំណត់ហេតុនេះ គឺឯកសារដែលខ្ញុំចង់សួរលោកដែរនោះ គឺផ្នែកមួយដែលនិយាយនៅខ្មែរ ERN 00427848 ហើយបន្តរហូតទៅដល់ 427854, អង់គ្លេស ERN 00003265 រហូតទៅដល់ 3270។ ផ្នែកនេះ នៅក្នុងកំណត់ហេតុនោះ មានចំណងជើងថា សូមដកស្រង់៖ "ថ្ងៃទី១៤ កក្កដា ឆ្នាំ១៩៧៦ ផែនការដឹកនាំរបស់ក្រសួងការបរទេស ថ្ងៃ -- ខែកក្កដា ឆ្នាំ១៩៧៦ ដល់ ១៩៧៧ ខែកក្កដា"។ សូមលោកមើលផ្នែកនេះ ក្នុងកំណត់ហេតុ ហើយខ្ញុំនឹងចង់ឲ្យលោកពិនិត្យមើលចំណុចចាប់ផ្ដើមលេខ៤ បាទ ខ្មែរ ERN 00427849, អង់គ្លេស ERN 00003267។ នៅក្នុងទំព័រនេះ នៅទំព័រ 427849 នោះគឺមានផ្នែកមួយ ដែលមានចំណងជើងថា៖ "ការងារគ្រប់ផ្នែក ដែលវាយផ្នែកផ្សេងៗហ្នឹងប្រាំពីររបស់ក្រសួង។ ផ្នែកទាំងប្រាំពីរនោះគឺ ទី១) កំណត់ថា ឃោសនាអប់រំ។ ២) ផ្នែកមន្ទីរ។ ៣) បង្កើនផល។ ៤) ផ្នែកនយោបាយ។ ៥) ផ្នែកពិធីការ។ ៦) ផ្នែកលេខាដ្ឋានរដ្ឋការ ហើយនិង ៧) គឺផ្នែកអាកាសចរណ៍ស៊ីវិល"។ សំណួររបស់ខ្ញុំជូនលោកនោះ ថាតើបញ្ជីនោះឆ្លុះបញ្ចាំងត្រឹមត្រូវពីផ្នែកទាំងអស់របស់ក្រសួងការបរទេសដែរឬទេ? រហូតមកដល់ខែកក្កដា ឆ្នាំ១៩៧៦នោះ តើផ្នែករបស់ក្រសួងការបរទេសនោះ មានប៉ុណ្ណឹងឬក៏យ៉ាងម៉េចបាទ?

[១០:៥៩:៣៧]

**ឆ៖** អានេះចំណងជើងថា គ្រប់ផ្នែក ហ្នឹងប្រាំពីរផ្នែក ត្រឹមត្រូវហើយ ដែលរៀបចំ។

**ស៖** នៅក្នុងផ្នែកទីពីរ ដែលនៅលេខ២ នោះផ្នែកមន្ទីរ តើនេះជាផ្នែកមួយរបស់ក្រសួងដែលលោកទទួលខុសត្រូវឬ?

**ឆ៖** អានេះ ទីពីរ ហ្នឹង ផ្នែកខ្ញុំទទួលខុសត្រូវហើយហ្នឹង។

**ស៖** បើសិនជាលោកត្រឡប់ទៅទំព័រខ្មែរ 00427853 ដែលអង់គ្លេស 00003269។ នៅលើទំព័រនោះជាភាសាខ្មែរមានកថាខណ្ឌទី៨ ដែលរៀបរាប់អង្គភាពមួយ គឺអង្គភាពសម្ងាត់ដែលខ្ញុំចង់សួរលោកអំពីអង្គភាពសម្ងាត់នេះ។ បាទនៅលើទំព័រនេះ ផ្នែកការងារសម្ងាត់ត្រូវបានរៀបរាប់ដូចខាងក្រោមនេះ សូមដកស្រង់៖

"ក្រោមការដឹកនាំរបស់មន្ទីរការងារ គឺស្ថិតនៅក្រោមមន្ទីរ ត្រូវរាយការណ៍ទៅឲ្យមន្ទីរ ដើម្បីអប់រំជំហរនយោបាយ សតិអារម្មណ៍ជាប់លាប់ ចាត់តាំងបំផុសចលនាកម្លាត់សេរីនិយម មានផែនការ

បង្កបង្កើនផល"។ តើលោកអាចប្រាប់តុលាការបានទេ ថាតើមុខងាររបស់ផ្នែកការងារសម្ងាត់នេះមានមុខងារអ្វីខ្លះ? តើអ្នកណាជាប្រធានផ្នែកនេះ?

[១១:០១:៤១]

**ឆ៖** ទី៨ ហ្នឹងគឺថា ក្នុងក្រសួងការបរទេសហ្នឹង វាមានផ្នែក គេទទួលខុសត្រូវផ្នែកសម្ងាត់។ ផ្នែកការងារៗ សម្ងាត់នេះ គឺមិនមែនការងារដឹងជាទូទៅទេ វាមានផ្នែករបស់វា។ ក្នុងហ្នឹងវាមានភ្ញៀវសម្ងាត់ដែរណ៎ា ភ្ញៀវសម្ងាត់ មានភ្ញៀវសម្ងាត់ មានភ្ញៀវចំហមានភ្ញៀវសម្ងាត់។ អាហ្នឹងគឺ ហើយអង្គាល់យើងត្រូវបញ្ជាក់ឲ្យគេ ឲ្យគេដឹងថាការងារសម្ងាត់របស់គេ គេត្រូវធ្វើអីខ្លះ។ គេត្រូវមានលំនាំដូចបានបញ្ជាក់នៅក្នុងក្រដាសហ្នឹងអ៊ីចឹង។

**ស៖** ប្រសិនបើលោកអាចមើលចំណុច៤ មួយភ្លែត ពាក់ព័ន្ធទៅនឹងបញ្ហានយោបាយ។ ERN ខ្មែរគឺ 00427551, អង់គ្លេសគឺ 00003268។ នេះគឺជាចំណុចមួយវែង ដែលនិយាយអំពីផ្នែកនយោ-បាយ។ ចំណុចដែលខ្ញុំចង់សួរនោះ គឺពាក់ព័ន្ធទៅនឹងផ្នែកពិធីសារ។ "ក្តោបចលនាបដិវត្តន៍នៅខាងក្នុងនិងខាងក្រៅឲ្យបានជាប់លាប់ ដើម្បីយើងអាចអនុវត្តមាគ៌ាសមូហភាពរបស់អង្គការ"។ សំណួររបស់ខ្ញុំនោះ គឺតើនរណាគេជាអ្នកផ្សព្វផ្សាយមាគ៌ានយោបាយសមូហភាព របស់អង្គការហ្នឹងទៅផ្នែកផ្សេងនោះ?

[១១:០៤:០០]

**ឆ៖** ឧទ្ទេសនាមរួម គឺថាលោកអ៊ំ អៀង សារី គាត់ឧទ្ទេសនាមរួម។ ឯតាមផ្នែកៗ គេហៅថាផ្នែកមួយៗហ្នឹង គឺដោយយកការឧទ្ទេសនាមរបស់គាត់ហ្នឹង ទៅអប់រំសមាជិករបស់ខ្លួនគឺទៅតាមហ្នឹងដែរ។ ត្រូវមានគ្រប់ខអ៊ីចឹង។ ផ្នែកដែលទទួលល្អិត ឧបមាថាផ្នែកអប់រំក៏ត្រូវយល់អ៊ីចឹង ផ្នែកបង្កបង្កើនផលក៏ត្រូវយល់អ៊ីចឹង ផ្នែកពិធិការក៏ត្រូវយល់អ៊ីចឹង ផ្នែក -- ឲ្យតែមានផ្នែកគេចាត់តាំងហ្នឹង គឺថាត្រូវយល់ ផ្នែកសម្ងាត់ក៏ត្រូវយល់អ៊ីចឹងដែរ។

**ស៖** តើនរណាគេជាប្រធានផ្នែកនយោបាយនៅក្នុងក្រសួងនេះ?

**ឆ៖** ផ្នែកនយោបាយគឺថា អ៊ំ អៀង សារី គាត់ជាប្រធានទទួលបន្ទុករួម គាត់ផ្នែកនយោបាយណ៎ា គឺលើគាត់ហ្នឹងហើយ។ ហើយបន្ទាប់មកទៀតគឺ បង សួរ ហុង ហ្នឹង នៅក្នុងក្រសួងគឺមានពីរនាក់ហ្នឹងទេ។

[១១:០៥:៣៥]

**ស៖** ទំព័របន្ទាប់ទៀត នៅក្នុងកំណត់ហេតុនេះ។ ខ្មែរ ERN គឺ 00427852, អង់គ្លេស ERN គឺ 00003269។ មានចំណុចពាក់ព័ន្ធទៅនឹងលេខាដ្ឋានអភិបាល ដែលខ្ញុំចង់ចោទសួរលោក គឺត្រង់ចំណុច៦។ អ្វីដែលខ្ញុំចង់សួរលោកនោះគឺ ដែលក្នុងនេះនិយាយអំពីលេខាធិការដ្ឋានអភិបាល។ និយាយមុខងាររបស់លេខាធិការដ្ឋាននេះដូចតទៅ៖ "ជាផ្នែកជំនួយមន្ទីរ គិតគូរឯកសារចេញចូល ពិសេសសារអបអរសាទរបុណ្យជាតិ បុណ្យកងទ័ពប្រទេសជាមិត្ត លិខិតឆ្លើយឆ្លងទូត រដ្ឋគិតគូរសន្និសីទអន្តរជាតិ គិតគូរបំពេញទំនាក់ទំនងសំបុត្រជាមួយនឹងខាងក្នុង និងខាងក្រៅប្រទេស"។ អ៊ីចឹងថាតើ ខ្ញុំចង់សួរនេះ នរណាគេជាអ្នកកាន់កាប់ផ្នែកលេខាធិការដ្ឋានអភិបាលនេះ?

[១១:០៧:១០]

**ឆ៖** នៅក្នុងក្រសួងការបរទេសហ្នឹង គឺថាគឺបងៗបញ្ញាជន គឺបង ជួន ប្រាសិទ្ធិ កាន់កាប់ការងារហ្នឹង។

**ស៖** សូមអរគុណ។ សំណួរអស់ហើយ ដែលខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងកំណត់ហេតុនេះ។ ខ្ញុំមានឯកសារមួយទៀត ដែលខ្ញុំសូមផ្តល់ជូនសាក្សីនៅពេលនេះផងដែរ គឺឯកសារ E3/857។

**លោក ខេល លីសាក់៖**

ខ្ញុំមានឯកសារនេះជាក្រដាសផងដែរ ដើម្បីផ្តល់ជូនទៅកាន់សាក្សី។ ខ្ញុំមានមូលដ្ឋាន -- សំណួរមូលដ្ឋានមួយចំនួនដើម្បីវាយតម្លៃ និងចោទសួរ ថាតើសាក្សីគាត់បានដឹងអំពីឯកសារនេះដែរឬទេ? សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[១១:០៨:៤០]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំផ្តល់ជូនលោកនេះ គឺឯកសារលេខ E3/857 ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧។ ពាក់ព័ន្ធទៅនឹងការធ្វើការងារជាមួយនឹងកម្មាភិបាល គណៈកម្មាធិការគ្រប់អង្គភាព។ ខ្ញុំចង់ឲ្យលោកមើលឯកសារនេះ ហើយលោកបញ្ជាក់ថាតើលោកស្គាល់ទេ ឯកសារនេះដែលបាន គេសរសេររៀបរាប់នៅក្នុងហ្នឹង?

[១១:១០:៣៤]

**លោក វ៉ាចម គុន៖**

**ឆ៖** ចំណុចនេះ គឺថាលោកអ៊ំ អៀង សារី ដដែលគាត់អ្នកធ្វើ។ ធ្វើចង់លើក គឺថារាយការណ៍គ្រប់អង្គភាព គឺថាអង្គភាពនេះ គឺអញ្ជើញមកអ្នកទទួលខុសត្រូវតាមខេត្ត ឱ្យចូលរួមមកប្រជុំដែរ។ ហើយអ្នកដែលនៅទីក្រុងភ្នំពេញហ្នឹង វាមានផ្នែកៗរបស់វាហ្នឹងក៏មកចូលរួមប្រជុំដែរ រាយការណ៍។

**ស៖** ចំណុចទីមួយ នៅផ្នែកដំបូងនេះ គឺមានចំណងជើងថា "សរុបលើសេចក្ដីរាយការណ៍ពីគ្រប់អង្គភាព"។ ចំណុចតូចទីមួយ នៅក្នុងហ្នឹងចំណងជើងថា "អំពីសកម្មភាពខ្មាំង" ត្រង់ខ្មែរទំព័រគឺ 00086707, ERN ជាភាសាអង់គ្លេស 00355487, បារាំង ERN គឺ 00881327 -- បារាំងគឺ 00811327។ ចំណុចដែលខ្ញុំចង់សួរលោកនោះ គឺមានដូចតទៅ៖ "នៅក្នុងសន្និបាតក្រសួងយើង យើងបានកត់សម្គាល់ថា យើងបានកម្ទេចនិងបោសសម្អាតជាមូលដ្ឋានខ្មាំងជា សេ.អ៊ី.អា, កា.ហ្សេ.បេ និងយួនលេបទឹកដី"។ បញ្ចប់ការដកស្រង់សម្ដីក្នុងនេះ។

[១១:១២:២៨]

ខ្ញុំចង់សួរថា តើនរណាគេជាអ្នករាយការណ៍នៅក្នុងពេលសន្និបាតនេះ ដែលបានលើកឡើងថា យើងបានកម្ទេច និងបោសសម្អាតជាមូលដ្ឋានខ្មាំង សេ.អ៊ី.អា, កា.ហ្សេង.បេ និងយួនលេបទឹកដីនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! រង់ចាំអង្គជំនុំជម្រះសម្រេចលើសេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីលោក អៀង សារី ជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ សួស្ដីលោកអ្នកទាំងឡាយដែលបានចូលរួម។

សាក្សីអត់ទាន់បានឆ្លើយនឹងសំណួរដែលថា តើគាត់បានឃើញឯកសារនេះ បានអានឯកសារនេះពីមុននៅឡើយទេ។ ពីព្រោះខ្ញុំកត់សម្គាល់ឃើញថា គាត់កំពុងតែអានឯកសារនេះ ដើម្បីអាចថាត្រៀមឆ្លើយសំណួរព្រះរាជអាជ្ញា។ អ៊ីចឹងសូមឱ្យសាក្សីបញ្ជាក់ថា គាត់បានឃើញឯកសារនេះពីមុនសិន ឬមិនទាន់បានឃើញ ទើបអាចបន្តសំណួរឱ្យស្របទៅនឹងវិធានដែលបានដាក់ចេញកន្លងមក។ សូមអរគុណ។

[១១:១៣:៤៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំបានឮសាក្សីគាត់បានកំណត់អំពីឯកសារសន្និបាតនេះហើយ ហើយបានលើកឡើងថា ឯកសារនេះបានចែកជូនទៅដល់កម្មាភិបាលផងដែរ។ ហេតុដូច្នេះសាក្សីបានបញ្ជាក់ទៅលើចំណុចដែលមេធាវីការពារក្ដីចោទសួរអំមិញនេះរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីឱ្យលោក អៀង សារី គ្មានប្រសិទ្ធភាព។ ហេតុផលគឺ មានដូចទៅនឹងតំណាងសហព្រះរាជអាជ្ញាបានលើកឡើងហើយ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយ តំណាងសហព្រះរាជអាជ្ញា!

[១១:១៤:៣៨]

**លោក វ៉ាថម គុន៖**

**ឆ៖** ឯកសារដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញហើយ គឺថាឯកសារធ្វើឡើងគឺថា ប្រជុំជាមួយគណៈកម្មការ ហៅថា បើកទូលាយហើយអាហ្នឹង បើកទូលាយ ដែលខ្ញុំបានឃើញឯកសារនេះ បានឃើញ បានមើលដែរ ឯកសារហ្នឹង។ គេមាន ពេលហ្នឹងគេមានអ៊ីចឹងហើយ។ ឯកសារនេះ គឺថា កំណត់ហេតុក្រោយពីផ្នែកអង្គភាពមួយៗរាយការណ៍។ រាយការណ៍ហើយគឺថា ការសន្និដ្ឋានរបស់ អង្គប្រជុំទាំងមូលគឺថា កំណត់អ៊ីចឹងគឺបានឯកភាព គេដាក់ជាភាគរយក៏មានដែរក្នុងនេះ។ ហើយបក្សថា "កម្ទេចសេ.អ៊ី.អា, កា.ហ្សេ.បេ" អីៗហ្នឹងគឺវាមានសព្វគ្រប់គេដែរក្នុងនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសំណួរចុងក្រោយរបស់តំណាងសហព្រះរាជអាជ្ញាទំនងជាសាក្សីភ្លេចហើយ។ អ៊ីចឹងតំណាងសហព្រះរាជអាជ្ញាតាំងសំណួរ ដែលលោកសួរចុងក្រោយទៅសាក្សីសាជាថ្មីម្ដងទៀត ដើម្បីឱ្យសាក្សីចាប់បាននូវខ្លឹមសារនៃសំណួររបស់លោក។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១១:១៦:១៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរជាក់លាក់ដែលខ្ញុំចោទសួរពាក់ព័ន្ធទៅនឹងប្រយោគដំបូងនៅក្នុងរបាយការណ៍នេះ

ដែលគេនិយាយថា៖ “ក្នុងសន្និបាតក្រសួងយើង យើងបានកត់សម្គាល់ថា យើងបានកម្ទេចនិងបោសសម្អាតជាមូលដ្ឋានខ្មាំងជា សេ.អ៊ី.អា, កា.ហ្សេ.បេ និងយួន”។ តើមាននរណាជាក់លាក់ដែលជាអ្នកធ្វើឧទ្ទេសនាមនៅក្នុងសន្និបាតក្រសួងនេះដែរឬទេ? ហើយប្រសិនអ្នកដែលធ្វើរបាយការណ៍នេះ តើជាអ្នកណាដែរ?

**លោក វ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះ ខ្ញុំមិនៗចាំទេគឺថា មិនដឹងជាបុគ្គលណាខ្លះ ប៉ុន្តែក្នុងសន្និបាតហ្នឹងដូចខ្ញុំរៀបរាប់អម្បាញ់មិញហ្នឹងហើយ ខ្ញុំថា៖ ទីមួយ គឺថាអ៊ំ អៀង សារី គាត់ឧទ្ទេសនាម ហើយទីពីរ គឺបង ស្វរ ហុង ហ្នឹងគាត់ជាអ្នក គេហៅថា សង្ខេបពីកំណត់ហេតុអង្គភាពតូចៗដែលតែងបានរាយការណ៍ៗជូនអង្គប្រជុំនេះ។ ហើយបានកំណត់ហេតុជាលាយលក្ខណ៍ជាអក្សរ គឺក្នុងបុគ្គលមួយៗរាយការណ៍គឺបុគ្គលមួយៗ វាច្រើន។ ច្រើនៗគ្នាណាស់ រាយការណ៍កាលហ្នឹងគឺគេកំណត់ថា គឺរាយការណ៍ប្រហែលៗគ្នាហ្នឹង គឺគេកំណត់ចេញជាលាយលក្ខណ៍ជាអក្សរគឺៗរបៀបនេះ គឺខ្ញុំ*(ឮមិនច្បាស់)* ត្រង់ថា ខ្ញុំបានឃើញឯកសារខ្ញុំបានឃើញអ៊ីចឹង។ ហើយកំណត់--

[១១:១៨:១២]

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ពេលនេះ សូមទោសដោយសារខ្ញុំកាត់ផ្តាច់លោកព្រះរាជអាជ្ញាស្ទួរ។ ដោយសារលោក នួន ជា គាត់ឥឡូវវិលមុខ មិនអាចអង្គុយបន្តទៅទៀតបាន សូមចុះទៅបន្តនៅបន្ទប់ខាងក្រោម។ ឥឡូវ គាត់មិនអាចអង្គុយបានតទៅទៀត។ សូមអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនមួយខាងក្រោមសាលសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍។ ហើយអង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬមានផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

ហើយឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ នួន ជា តាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលបន្តនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ទៅកាន់បន្ទប់ខាងក្រោមដែលមានរៀបចំសោតទស្សន៍សម្រាប់គាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

[១១:១៩:៤០]

**លោក សុន អរុណ៖**

សូមទោស។ ខ្ញុំសូមបន្ថែម សូមឲ្យអញ្ជើញលោកពេទ្យចុះទៅពិនិត្យគាត់ដោយផ្ទាល់ ពេលឥឡូវផង ក្រែងលោបញ្ហាអីកើតឡើង។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីបញ្ជាក់របស់លោកអំមិញទំនងជាគ្រូពេទ្យយល់បានហើយ ពីព្រោះបញ្ហាទាក់ទិនជាមួយនឹង មានអាការៈផ្នែកខាងសុខភាព ហើយគាត់មានកិច្ចសន្យាជាមួយនឹងខាង អ.វ.ត.ក អំពីបញ្ហាពិនិត្យនិងថែទាំសុខភាព។ ដូច្នេះ គាត់នឹងបំពេញភារកិច្ចទៅតាមតួនាទីរបស់គាត់ហើយ។

ហើយសូមរំឭកមេធាវីផងដែរថា មិនគប្បីធ្វើដូច្នេះទៅថ្ងៃក្រោយ យ៉ាងហោចណាស់ក៏អាចឲ្យមានការសួរឆ្លើយចប់មួយសំណួរដែរ។ លើកលែងតែករណីធ្ងន់ធ្ងរដែលថា វាដួល ឬក៏អីចឹង។ អាហ្នឹងសូមគប្បីធ្វើដូច្នេះបាន។ បើពុំដូច្នេះទេ គឺនាំឲ្យអាក់ខាន។ ឥឡូវហ្នឹងមិនដឹងថាដល់ត្រឹមណាទេ សំណួរចម្លើយអម្បាញ់មិញនេះ។

ករណីចាំបាច់បន្ទាន់បំផុត សូមធ្វើស្ថានភាពតក់ក្រហល់បែបនេះ។

សូមអញ្ជើញសាក្សីឆ្លើយបន្ត ប្រសិនបើលោកចងចាំ ហើយបើមិនចាំទេ លោកអាចសុំឲ្យតំណាងសហព្រះរាជអាជ្ញាតាំងសំណួរជាថ្មីម្ដងទៀត។ សំណួរចុងក្រោយអម្បាញ់មិញនេះ។

**លោក វ៉ាចាម តុន៖**

សូមគាត់តាំងសំណួរថ្មីទៀតចុះ បាទ។

[១១:២១:២០]

**លោក ខេល លីសាក់៖**

ជាការពិតលោកប្រធាន ខ្ញុំរៀបនឹងចាប់ផ្ដើមសំណួរថ្មីទៅហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចំណុចដដែលនេះចេញពីរបាយការណ៍ដែលខ្ញុំសួរលោក គឺត្រង់ខ្មែរ ERN 86707 នៅកថាខណ្ឌទី១ ចុងបញ្ចប់។ នេះ គឺឯកសារនេះបានបញ្ជាក់ថា "យើងបានឯកភាពគ្នាលើបញ្ហាបោសសម្អាតខ្មាំងនេះ។ ទន្ទឹមនេះ យើងក៏បានឯកភាពគ្នាថា ខ្មាំងមិនទាន់អស់នៅឡើយទេក្នុងក្រសួងយើង ក៏ដូចនៅក្នុងអង្គភាពនីមួយៗ។ ដូច្នេះ យើងត្រូវបន្តបោសសម្អាតឲ្យស្អាតជ្រះស្រឡះក្នុងក្រសួងក៏ដូចជាអង្គភាពនីមួយៗ។" តើនរណាគេដែរជាអ្នកណែនាំឲ្យបោសសម្អាតបន្តឲ្យស្អាតជ្រះស្រឡះក្នុងក្រសួងនោះ?

[១១:២២:៣០]

**លោក វ៉ាចាម តុន៖**

**ឆ៖** លោកអ៊ំ អៀង សារី គាត់ឈរលើមូលដ្ឋានដែលរាយការណ៍នេះ គឺគាត់សរុបហ្នឹង គឺថាត្រូវបន្តបោសសម្អាតឲ្យស្អាត។ យើងបោសសម្អាតកន្លងមក វាបានល្អហើយ ហើយក្នុងក្រសួងរបស់យើង ហើយនៅពីរភាគរយទៀត យើងបន្តបោសសម្អាតទៀត។ អាហ្នឹង គេចង់និយាយក្នុងពួដផ្ទៃក្នុងខ្លួនយើង ដែលយើងវាមានពាក់ព័ន្ធ រឿងមនុស្សខ្លះ គឺថារាយការណ៍ទៅ គឺថាវានៅជំពាក់ជំពិនខាងទស្សនៈ ខាងគោលជំហរ ខាងសតិអារម្មណ៍។ ហើយអ៊ីចឹងៗបាន គឺថាសរុបមកគឺវាមានតាមផ្នែក ឬមួយល្អិតនោះ វាមាន។ បើយើងគិតពីភាគរយ វាល្អនោះ វាច្រើន ដែលធ្វើបាននោះ វាច្រើន។ ដែលវាមិនទាន់បានល្អ វានៅភាគតិច។ អាហ្នឹងយើងត្រូវបន្តធ្វើតទៅទៀត។ អានេះខ្ញុំ សំណួរនេះ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១១:២៣:៣៧]

**ស៖** នៅក្នុងទំព័រដដែល ខាងក្រោម ខ្មែរ ERN គឺ 00086707, អង់គ្លេស ERN គឺ 00355488, បារាំង គឺ 00811327។ ឯកសារនេះមានដូចតទៅ៖ "ខ្មាំង វាបន្លឺថា គេ -- ខ្មាំងទាំងអស់នោះនឹងត្រូវចាប់ខ្លួន។ មិត្តរបស់យើងចេះវិភាគ ហើយរាយការណ៍ដល់យើង។ នៅពេលដែលយើងចាប់ខ្លួន គឺយើងនឹងធ្វើការសួរចម្លើយ ហើយយើងនឹងអាចឃើញខ្សែខ្មាំងច្បាស់។" នេះគឺជាចំណុចដកស្រង់។ តើលោកបានឮដែរឬទេ នរណាគេដែរដែលជាអ្នកលើកចំណុចនេះឡើងក្នុងពេលសន្និបាតនោះ?

**ឆ៖** ខ្ញុំមិនចាំទេ ចំណុចនេះ វាល្អិតល្អន់ពេក ខ្ញុំមិនចាំទេ។

**ស៖** នេះគឺជាសំណួរទាំងអស់ ដែលខ្ញុំចង់សួរលោកពាក់ព័ន្ធទៅនឹងឯកសារនេះ។ នៅពេលនេះ

ខ្ញុំសូមអនុញ្ញាតចូលទៅដល់ប្រធានបទមួយទៀត។ តើមានពេលណាមួយ ក្នុងអំឡុងកម្ពុជាប្រជាធិប-តេយ្យ ដែលនៅពេលនោះ មានការចាប់ខ្លួនបុគ្គលនៅក្នុងក្រសួង ហើយពេលក្រោយចាប់ខ្លួននោះ គឺបាត់ខ្លួនតែម្តង។ តើមានដែរឬទេ? ក្នុងពេលណាដែរ?

**ឆ៖** មានចាប់ ប៉ុន្តែខ្ញុំមិនដឹងថា ក្នុងឆ្នាំ៧៧, ៧៨ ហ្នឹងឯង មាន។

**ស៖** តើកម្មាភិបាលនៅក្នុងក្រសួងត្រូវបានគេបញ្ជូនទៅការដ្ឋានដើម្បីលត់ដំដែរឬទេ?

**ឆ៖** មាន។ មានបញ្ជូនទៅកន្លែងបង្កបង្កើនផល កន្លែងលត់ដំអីមាន។

**ស៖** តើកន្លែងណាដែរ ដែលជាការដ្ឋានការងារ និងកន្លែងបង្កបង្កើនផល ដែលគេបញ្ជូនកម្មា-ភិបាលទៅទីនោះនុះ នៅម្តុំណាដែរ? នៅកន្លែងណាដែរ?

[១១:២៧:០៤]

**ស៖** បើក្នុងអង្គភាពរបស់ ប-១ មានតែនៅតាខ្មៅអង្កាល់ហ្នឹង កន្លែងបង្កបង្កើនផលរបស់ក្រសួងនៅតាខ្មៅ។

**ស៖** កន្លែងបង្កបង្កើនផលនៅតាខ្មៅ និងកន្លែងការដ្ឋានការងារនៅតាខ្មៅនោះ តើមានឈ្មោះលេខកូដគេដែរឬទេ?

**ឆ៖** អត់មានដាក់លេខកូដអីផង ដាក់តែនៅ ១តាខ្មៅហ្នឹង មន្ទីរនៅតាខ្មៅអីចឹងហើយ។

**ស៖** តើបុគ្គលិកនៅក្នុងក្រសួង ត្រូវបានគេបញ្ជូនទៅកន្លែងយន្តហោះកំពង់ឆ្នាំងដែរឬទេ ការដ្ឋានយន្តហោះនៅកំពង់ឆ្នាំងនោះ?

**ឆ៖** បើពួកក្នុងក្រសួងរបស់ខ្ញុំ បើថានៅកន្លែងបង្កបង្កើនផលតាខ្មៅ អត់ទេ អត់ៗបានទៅកន្លែងអាកាសយានយន្តហោះនៅកំពង់ឆ្នាំងអត់ទេ។ អត់ដឹងទេអានោះ។ ខាងខ្ញុំអត់មានចាត់ចែងទៅនុ៎ងទេ ខាងខ្ញុំ អត់មានទេ។

**ស៖** តើកំហុសអ្វីខ្លះដែលនាំឲ្យគេបញ្ជូនបុគ្គលិកនៅក្នុងក្រសួងទៅលត់ដំនោះ?

**ឆ៖** កំហុសនោះគឺថា កំហុសតូចតាចទេ។ ឧបមាថា ធ្វើការងារមិនសកម្ម ហើយការទទួលខុសត្រូវចំពោះភារកិច្ចគេប្រគល់ឲ្យធ្វើមិនបានល្អ។ វាមានរបៀបអីចឹង។

**ស៖** តើនរណាគេជាអ្នកធ្វើសេចក្តីសម្រេច ថាបុគ្គលិកណាខ្លះនៅក្នុងក្រសួងនោះ ត្រូវបញ្ជូនទៅលត់ដំនោះ?

[១១:២៩:៥៨]

**ឆ៖** បើមានក្នុងក្រសួងគឺថា យើងធ្វើក្នុង -- ឧបមាថា កន្លែងផ្នែកផ្ទះបាយ យើងធ្វើការជាមួយផ្នែកផ្ទះបាយហ្នឹង។ ហើយបើពិនិត្យឃើញថា វាអ៊ីចឹង យើងឲ្យគេទៅលត់ដំនៅនុ៎ងទៅ។ បើផ្នែករៀបចំផ្ទះ បើឃើញហេតុភេទហ្នឹង យើងពិនិត្យក្នុងអ្នកទទួលខុសត្រូវរៀបចំផ្ទះ បើឃើញអ៊ីចឹង ឧបមាថា ហេតុភេទ វាមិនល្អ ក៏បញ្ជូនទៅ។ ក្នុងហ្នឹងគឺថា ឆ្លងការសម្រេចមានអី មានតែអ៊ំៗ អៀង សារី ហ្នឹង ហើយ គាត់អ្នកសម្រេចហ្នឹង យើងឧបមាថា យើងរាយការណ៍ជូនទៅ វាមានបញ្ហាអ៊ីចេះៗទៅ គាត់ថា អឺអាហ្នឹងទៅឲ្យគេលត់ដំកន្លែងហ្នឹងទៅអ៊ីចឹង។

[១១:៣០:៥៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន។ ខ្ញុំសូមអានការដកស្រង់សម្តីចេញពីកិច្ចសម្ភាសន៍ លើកទី២ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/63 ចំណុចដែលខ្ញុំចង់អានជូនសាក្សីនោះ ខ្មែរ ERN គឺ 00228846, អង់គ្លេស ERN គឺ 00231411, បារាំងគឺ 00376057។ យើងខ្ញុំបានជូនឯកសារនេះមួយច្បាប់រួចទៅហើយ ហើយខ្ញុំក៏នៅមានឯកសារនេះមួយច្បាប់ទៀតផងដែរ ប្រសិនបើអង្គជំនុំជម្រះត្រូវការជូនសាក្សី។ ហើយយើងខ្ញុំក៏សូមអនុញ្ញាតបញ្ចាំងចំណុចនេះ នៅលើទូរទស្សន៍ផងដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការមើលឯកសារនៅពីមុខសាក្សី ដើម្បីបង្ហាញគាត់សម្រួល និងចំណាយពេលវេលាតិច។

*(សម្រាករយៈពេលខ្លី)*

ប្រសិនរកមិនឃើញទេ យកទទួលឯកសារជាក្រដាសជាថ្មីពីតំណាងសហព្រះរាជអាជ្ញាយកជូនគាត់។

[១១:៣៣:០១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ផ្នែកនៅក្នុងកិច្ចសម្ភាសន៍ជូនសហចៅក្រមស៊ើបអង្កេត ដែលខ្ញុំចង់យកមកសួរលោកនោះ គឺនោះគឺត្រង់ទំព័រខ្មែរ ERN 00228846 គឺមានសរសេរដូចតទៅ៖ “មន្ទីរ៨៧០ បញ្ជូនដំណឹងមកអ៊ំ អៀង សារី ហើយគាត់ជាអ្នកសម្រេចថាត្រូវបញ្ជូនអ្នកណាទៅលត់ដំ”។ បញ្ចប់ការដកស្រង់សម្តីនេះ។

សំណួរដែលខ្ញុំចង់សួរទៅកាន់លោកនោះគឺ តើដំណឹងអ្វីខ្លះ ដែលមន្ទីរ៨៧០បញ្ជូនទៅអ៊ំ អៀង សារី ពាក់ព័ន្ធទៅនឹងកម្មាភិបាលដែលត្រូវបញ្ជូនទៅលត់ដំ ឬក៏ត្រូវចាប់ខ្លួននោះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ចំណុចនេះគឺថា ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញខ្លះហើយគឺ ទីមួយ បើអ៊ំ អៀង សារី ក៏ទទួលបានឯកសារពី៨៧០ ពាក់ព័ន្ធនឹងបុគ្គលយើងមើលជាក់ស្តែងវាមានសកម្មភាពតូចតាចទេ ជាក់ស្តែង ប៉ុន្តែបើបុគ្គលហ្នឹងមានចម្លើយក្នុងឯកសារ អាហ្នឹងគឺថា ៨៧០ សម្រេចដដែលហ្នឹង ហើយនិងប្រាប់អ៊ំ អៀង សារី ទៅ អ៊ំ អៀង សារី ក៏ចាត់ចែងតាមមន្ទីរ៨៧០ ដែលបានប្រាប់គាត់អ៊ីចឹងទៅ។ វាមានកន្លងមក វាមានរបៀបអ៊ីចឹងមានដែរហ្នឹង។

[១១:៣៤:៥១]

**ស៖** តើលោក អៀង សារី បានទទួលពីមន្ទីរ៨៧០ នូវចម្លើយសារភាពពីស-២១ ដែលមានឈ្មោះកម្មាភិបាលមួយចំនួននៅក្នុងក្រសួងដែលអ្នកទោសឆ្លើយដាក់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

[១១:៣៥:២៩]

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការជំទាស់ដូចគ្នាដដែល ខ្ញុំកត់សម្គាល់ឃើញថា សាក្សីគាត់ដូចជាកាន់មើលនូវសក្ខីកម្មពីមុនរបស់គាត់។ ដូច្នេះខ្ញុំគិតថា វាមិនដឹងថា យ៉ាងម៉េចទេនៅពេលដែលគាត់ឆ្លើយដែលគាត់មើលឯកសារបែបនេះនោះ ដូចដែលលោកប្រធានបានសម្រេចអម្បាញ់មិញនេះហើយ។ ដូច្នេះខ្ញុំសូមឲ្យគាត់ឆ្លើយ ដោយមិនមើលឯកសារពីមុន សក្ខីកម្មពីមុនរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការបញ្ជាក់រំឭកសាជាថ្មីម្តងទៀត។ សូមលោកសាក្សីចូលរួមនៅក្នុងកិច្ចដំណើរការសវនាការជាធម្មតា គឺឆ្លើយនឹងសំណួរដោយមិនមើលឯកសារទេ។ ហើយឯកសារដែលឲ្យមើលអម្បាញ់មិញនេះ គឺពាក់ព័ន្ធទៅនឹងការដកស្រង់នូវចំណុចជាក់លាក់ ដែលវាមានខុស ឬក៏វាមិនជាក់ច្បាស់រវាងចម្លើយដែលលោកឆ្លើយផ្ទាល់មាត់ ហើយនិងលាយលក្ខណ៍អក្សរ ដែលលោកបានធ្លាប់ឆ្លើយ

នៅចំពោះមុខអ្នកស៊ើបអង្កេតកន្លងមក ដើម្បីបញ្ជាក់ទេ។ អ៊ីចឹងកាលណាមានចំណុចដែលមានការគួសក្រហម ហើយសួរបញ្ជាក់នោះ សូមលោកពិនិត្យមើលចំណុចនោះដើម្បីឆ្លើយបញ្ជាក់ឱ្យបានច្បាស់លាស់ ពីព្រោះបញ្ហាវាយូរ ហើយនិងរឿងវាធំផង។ ហើយចំណុចផ្សេងទៀត គឺលោកចាំស្តាប់នូវសំណួររបស់សហព្រះរាជអាជ្ញាក៏ដូចជាភាគីដែរ ហើយដោយមិនបាច់មើលឯកសារទេ។ លើកលែងតែចំណុចដែលយើងពន្យល់ -- ចំណុចខាងលើអម្បាញ់មិញនេះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយសាជាថ្មី!

[១១:៣៧:០៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរសួរលោកថា តើលោក អៀង សារី បានទទួលមកពីមន្ទីរ៨៧០ អំពីចម្លើយ -- នូវចម្លើយសារភាពរបស់ស-២១ ដែលមានឈ្មោះកម្មាភិបាលក្នុងក្រសួង ហើយអ្នកទោសនៅស-២១ នោះឆ្លើយដាក់? តើគេបានបញ្ជូនឯកសារហ្នឹងមកលោក អៀង សារី ដែរឬទេ?

**លោក រ៉ចាម តុន៖**

**ឆ៖** បញ្ជូន ពីព្រោះគាត់ តែមានលាយលក្ខណ៍ជាអក្សរ គាត់ប្រាប់ហើយ តាមពិនិត្យ គឺថាមានឈ្មោះ ក អ៊ីចឹងទៅ មានពាក់ព័ន្ធចម្លើយវាអីអ៊ីចេះៗទៅ។ ដល់ហ្នឹងគឺចុងក្រោយហ្នឹងគឺថា ៨៧០ គេអ្នកដំណើរការគេទៅយកទៅ។

[១១:៣៨:១២]

**លោក ឌេល លីសាក់៖**

លោកប្រធាននៅពេលនេះ ខ្ញុំចង់អានផ្នែកមួយនៅក្នុងចម្លើយរបស់សាក្សី គឺ E3/63 នេះនៅទំព័រដដែល ខ្មែរ ERN 0022886 -- 46, ជាបារាំង ERN 00376057, អង់គ្លេស 00231411 បាទ។ ខ្ញុំសូមអនុញ្ញាដើម្បីបង្ហាញនៅក្នុង -- នៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងបទសម្ភាសន៍របស់លោកនោះ គេសួរទៅលោកនូវសំណួរដូចខាងក្រោមនេះ៖ "តើអ្នកណាជាអ្នកធ្វើសេចក្ដីសម្រេចក្នុងការបញ្ជូនមនុស្សទៅស-២១ ឬក៏ទៅលត់ដំ?" លោកបានឆ្លើយថា សូមដកស្រង់៖ "ករណីកំហុសដែលធ្ងន់ជាងគេបំផុត តាមការឆ្លើយដាក់នៅក្នុងចម្លើយសារភាព ហើយត្រូវបានរាយការណ៍ដោយ ឌុច ទៅមន្ទីរ៨៧០ រួចមកប-១។ មន្ទីរ៨៧០ បញ្ជូនដំណឹងមកអ៊ំ អៀង សារី ហើយគាត់ជាអ្នកសម្រេចត្រូវបញ្ជូនទៅលត់ដំ។ អ៊ំ អៀង សារី បានប្រាប់ខ្ញុំថាចម្លើយសារភាពនោះបានបញ្ជូនមកគាត់ដោយមានចំណារ ហើយជួនកាលគាត់ទទួលបាននៅពេលហូបរួម ហើយជួនកាលបញ្ជូនមកតាមការិយាល័យគាត់ តាមរយៈសំបុត្រសម្ងាត់"។ ចប់សេចក្ដីដកស្រង់។

[១១:៣៩:៥៧]

សំណួរទីមួយរបស់ខ្ញុំ ទាក់ទងនឹងចំណុចនេះ តើលោកដឹងទេ ថាតើអ្នកណាដែលមកពីមន្ទីរ ៨៧០ ដែលបញ្ជូនឯកសារនេះមកលោក អៀង សារី នោះ?

**ឆ៖** ៨៧០ ហ្នឹង គាត់ហូបបាយជុំគ្នា គឺថាមានតែអ៊ំទីមួយ ឬមួយអ៊ំទីពីរ ហ្នឹងហើយ។

**ស៖** តើលោក អៀង សារី បានប្រាប់លោកទេ ថាតើចំណារផ្ទាល់ដៃនៅលើចម្លើយសារភាពនោះជាចំណារប្រភេទអ្វី? តើគាត់ប្រាប់លោកអ៊ីចឹងទេ?

**ឆ៖** ក្រដាសហ្នឹង ខ្ញុំអត់បានឃើញទេ គ្រាន់តែគាត់ថាមានចម្លើយគេៗឲ្យមក។ ដល់អ៊ីចឹងគាត់អត់ឲ្យខាងខ្ញុំហ្នឹងដឹងទេ ដែលដំណើរការជាក់ស្ដែង គេថាបើត្រូវយកមនុស្សហ្នឹងទៅ គឺខាងមន្ទីរ ៨៧០ ទេជាអ្នកយកនោះ។ ខ្ញុំអត់បានឃើញទេ ចំណារហ្នឹង។ ចំណារពីណាៗ អត់ដឹងទេ។

[១១:៤១:៥០]

**ស៖** តើលោក អៀង សារី ប្រាប់លោកដែរឬទេ ថាតើគាត់ប្រើចម្លើយសារភាពធ្វើអ្វី ក្រោយពីគាត់បានទទួលមកនោះ?

**ឆ៖** គាត់ប្រាប់ខ្ញុំថាមានចម្លើយដែលវាពាក់ព័ន្ធនឹង -- ខ្លះក៏ពាក់ព័ន្ធនឹង សេ.អ៊ី.អា ខ្លះក៏ពាក់ព័ន្ធនឹង កា.ហ្សេ.បេ ខ្លះក៏ពាក់ព័ន្ធនឹងអាខ្មាំងយួនឈ្លានពាន អ៊ីចឹងទៅ។

**ស៖** នៅពេលដែលគេសម្រេចថា បុគ្គលិកក្រសួងដែលគេត្រូវចាប់ខ្លួនបុគ្គលិកនោះ តើអ្នកណាជាអ្នកចាប់ខ្លួនអ្នកទាំងនោះ?

**ឆ៖** គឺភាគច្រើនខាងៗមន្ទីរ៨៧០ ទេ។ បើគេយកឡានយកអីទៅ។

**ស៖** តើមានអង្គភាពពិសេសណាមួយទេ មកពីមន្ទីរ៨៧០ ដែលទទួលបន្ទុកក្នុងការចាប់ខ្លួននេះ?

**ឆ៖** ឃើញតែខាងហ្នឹង គេហៅយោធា យ-១០ អង្គាល់ហ្នឹង។

**ស៖** ថាតើអ្នកណាជាប្រធានរបស់យោធា យ-១០ នេះ?

**ឆ៖** ខ្ញុំស្គាល់ដំបូងនេះ គេហៅន៎ឈ្មោះៗ ហៀនៗ ឈ្មោះ ហៀន កាលនុ៎ង។ ហៀន ហើយនិង វ៉ាន់ ដែរឈ្មោះ វ៉ាន់ មួយដែរ ប៉ុន្តែ វ៉ាន់ ខាងយោធា យ-១០ ហ្នឹង។

[១១:៤៤:៤៩]

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើបុគ្គលិកយោធាមកពីយ-១០ ហ្នឹង គេមកក្រសួងការបរទេស ហើយដើម្បីមកចាប់មនុស្ស ថាតើគេមករកមនុស្សហ្នឹងឃើញដោយវិធីណាដើម្បីនាំខ្លួន ឬចាប់ខ្លួនអ្នកនោះបាននោះ?

**ឆ៖** ឧទាហរណ៍ថា ឈ្មោះ "ក" អ៊ីចឹង ខាងៗក្រសួងហ្នឹង គាត់ប្រាប់ថាឈ្មោះ "ក" អ៊ីចឹងដែលតាមចម្លើយគេដាក់ថាឈ្មោះ "ក" អ៊ីចឹង ដល់យើងប្រាប់ឈ្មោះ "ក" ឱ្យនៅកន្លែងថ្ងៃហ្នឹងកុំទៅណាអាហ្នឹង។ ខាងគេមកយកទៅ។

**លោក ឌេល លីសាក់៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតអានសេចក្តីដកស្រង់គឺនៅក្នុង E3/63 ដែរ សេចក្តីដកស្រង់នេះនៅខ្មែរ ERN 00228845, អង់គ្លេស ERN 00231411 ហើយបារាំង ERN 00376056។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះលើអេក្រង់ផងដែរបាទ។

[១១:៤៥:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងចម្លើយរបស់លោក ដែលលោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះលោកបានឆ្លើយដូចខាងក្រោមនេះ សូមដកស្រង់៖

"ប្រសិនបើមានចម្លើយសារភាពនៅក្នុងនោះ ឈ្មោះអ្នកដែលនៅ -- ឈ្មោះនោះគឺត្រូវបញ្ជូនទៅឱ្យអ៊ំ អៀង សារី ដើម្បីឱ្យគាត់បញ្ជាក់ប្រាប់ថាជននោះជាអ្នកណា? ហើយធ្វើការនៅផ្នែកណា? បន្ទាប់

មកត្រូវបានចាប់ខ្លួនដោយពួកយោធាដែលមកពីយ-១០ នៃមន្ទីរ៨៧០។ ការចាប់ខ្លួនធ្វើឡើងនៅពេលថ្ងៃ ឬក៏នៅពេលយប់។ ហើយអ្នកទោសត្រូវបានដឹកចេញតាមឡាន។" ចប់សេចក្ដីដកស្រង់។ សំណួរដែលខ្ញុំសួរលោកនោះ គឺថាតើលោកបានដឹង ឬក៏លោកបានដឹងថា លោកអៀង សារី បញ្ជាក់ៗថាឲ្យមន្ទីរ៨៧០ ហ្នឹងដឹងថាអ្នកណាត្រូវចាប់ តើលោកដឹង -- តើលោកដឹងដោយវិធីណា ដែលថាលោក អៀង សារី ហ្នឹងត្រូវប្រាប់ថាកុំទៅណា ឬក៏ប្រាប់ថាអ្នកណាដែលត្រូវគេចាប់ខ្លួនហ្នឹង? លោកដឹងដោយរបៀបណា?

[១១:៤៧:៥៩]

**លោ វ៉ាចាម តុន៖**

**ឆ៖** ជួនណាអ៊ំ អៀង សារី គាត់ប្រាប់ ជួនណាបង សួរ ហុង គាត់ប្រាប់។ ធ្វើការជាមួយគ្នា គាត់នៅហ្នឹង គាត់ថាមកឈ្មោះ "ក" គាត់ប្រាប់ទៅថាឈ្មោះ ក នេះគេត្រូវមកយកថ្ងៃនេះ ឲ្យនៅមួយកន្លែងទៅ។ ប្រាប់ជួនកាលនៅ បីនាក់ហ្នឹង អ៊ំ អៀង សារី, បងសួរ ហុង ហើយនិងខ្ញុំអ៊ីចឹងទៅ។

**ស៖** សូមអរគុណ។ ខ្ញុំរីករាយដែលថា លោកឆ្លើយថា ជួនកាលលោក សួរ ហុង នៅទីនោះដែរ ហើយខ្ញុំនឹងឲ្យឱកាសលោកបានជ្រាបដែរថា គាត់បានមកបំភ្លឺនៅតុលាការហើយ។ សក្ខីកម្មរបស់លោក សួរ ហុង នោះក៏បានបង្ហាញថា "គឺថាមានឱកាសមួយចំនួន កម្មាភិបាលដែលត្រូវគេចាប់ខ្លួននោះ គឺគេនាំមកឲ្យនៅក្រៅក្រសួងដោយលោក ហើយលោកបាននាំមកខាងក្រៅ ដើម្បីឲ្យអ្នកមកពីមន្ទីរ៨៧០ ហ្នឹងយកទៅ"។

ហើយខ្ញុំសូមអានផ្នែកមួយនៃចំណុចមួយដែលលោក សួរ ហុង នោះបានឆ្លើយ។ គឺថាឯកសារនោះគឺៗ ឯកសារ E1/69.1/18 មានសំណួរសួរទៅ ហុង ថា "តើលោកដឹងទេថា តើអ្នកណាដែលបញ្ជូនមនុស្សឲ្យគេនោះ?" គាត់បានឆ្លើយថា សូមដកស្រង់៖ "ខ្ញុំដឹងថា ជាម បាននាំអ្នកទាំងអស់នោះទៅខាងក្រៅ ហើយខ្ញុំបានសួរ ជាម អំពីរឿងថា តើគេយកអ្នកនោះទៅណា? ហើយខ្ញុំនិយាយថា "អាចនឹងវេនខ្ញុំពេលក្រោយ" ពេលនោះខ្ញុំនិយាយលេង ហើយ ជាម បានប្រាប់ខ្ញុំថា "គាត់បានយកមនុស្សទៅខាងក្រៅ ហើយមនុស្សផ្សេងទៀតបានមកយកមនុស្សទាំងនោះចេញពីគាត់ ហើយគាត់មិនបានដឹងថាយកទៅណាទេ"។

សំណួរ តើមានឱកាសណាមួយ ដែលលោកបានយកមនុស្សដែលត្រូវគេចាប់ខ្លួន ហើយយកចេញពីក្រៅក្រសួងបន្ទាប់មកគឺបុគ្គលិកមកពីយ-១០ ជាអ្នកយកបន្តទៅ។ តើធ្លាប់មានអ៊ីចឹងដែរឬទេ?

[១១:៥០:៣៣]

**ឆ៖** ចំណុចនេះមាន ដូចបង សួរ ហុង គាត់បានបញ្ជាក់។ ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ គឺថា ពេលខ្លះ ខ្ញុំនាំទៅ នាំទៅឲ្យ -- បានណាត់គ្នាថានៅផ្ទះត្រង់ណា គេមកយកនៅផ្ទះហ្នឹងទៅ។ ហើយគេយកទៅណាទៀតទៅ ខ្ញុំមិនដឹងដែរ គេយកតៗទៀតទៅ។ អ៊ីចឹង មានអ៊ីចឹង។

អាហ្នឹងឈរលើមូលដ្ឋាន ដូចខ្ញុំបានបញ្ជាក់ពីខាងដើមថា បើថាមានចម្លើយមកពី៨៧០ហើយ ហើយបើ៨៧០ ប្រាប់ទៅអ៊ំ អៀង សារី បើអ៊ំ អៀង សារី បានមកប្រាប់មកយើង គឺយើងដំណើរការ អ៊ីចឹងទៅ។ ជួនណាអ៊ំ អៀង សារី, ជួនណាអ៊ំ -- នែបង សួរ ហុង ប្រាប់អ៊ីចឹង។

[១១:៥១:៣៥]

**ស៖** បាទ នេះជាសំណួរបន្ទាប់ដែលខ្ញុំចង់សួរ នៅពេលឱកាសដែលលោកបានយកមនុស្សទៅខាងក្រៅ ហើយគេមកចាប់ខាងក្រៅ។ អ្នកណាជាអ្នកណែនាំឲ្យលោកធ្វើបែបនោះបាទ?

**ឆ៖** ណែនាំ ដូចខ្ញុំបានបញ្ជាក់ពីខាងដើមហើយ អំមិញ គឺថាមានតែអ៊ំ អៀង សារី មានតែបង សួរ ហុង ទេលើខ្ញុំនោះ។ មានតែគាត់ពីរនាក់ហ្នឹងទេ។

**ស៖** នៅក្នុងករណីដែលកម្មាភិបាលក្រសួងត្រូវបានគេយកចេញទៅដែលថា បុគ្គលិកមកពីមន្ទីរ ៨៧០ នាំយកទៅ តើលោកធ្លាប់បានជួបអ្នកដែលគេនាំទៅហ្នឹងនៅពេលក្រោយមកទេ ត្រឡប់មកវិញទេ អ្នកដែលគេចាប់ទៅនោះ?

**ឆ៖** បើចាប់ទៅហើយ មិនដឹងទេ អត់ឃើញគេ អាឃើញមកក្រោយទៀតទេ ទៅបាត់ហើយ មិនដឹងទៅដល់ណាទេ មិនដឹងដែរ។

[១១:៥២:៥៩]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់ទៅចំណុចមួយទៀត ប្រធានបទមួយទៀត ដោយសង្ខេបអំពីបញ្ហា -- អំពីនិស្សិត ហើយនិងពួកបញ្ញាជនដែលត្រឡប់មកពីបរទេសវិញ មកកម្ពុជា។ បន្ទាប់ពីរំដោះ តើលោកបានដឹងថា តើលោក អៀង សារី បានណែនាំ ឬក៏បញ្ចុះបញ្ចូលឲ្យនិស្សិត ឬ បញ្ញាជន ដែលរស់នៅឯបរទេសឲ្យពួកអ្នកទាំងនោះត្រឡប់មកកម្ពុជាដែរឬទេ?

**ឆ៖** ចំណុចនេះ ដូចខ្ញុំបានបញ្ជាក់ពីបន្តបន្ទាប់ហើយថា ពីក្នុងឋានៈគាត់ទទួលខុសត្រូវខាងផ្នែកក្រសួងការបរទេសអ៊ីចឹង គឺគាត់មានអប់រំទាំងកម្មាភិបាល ទាំងយុទ្ធជនយើង គឺថាបញ្ញាជន ដែលថាគេស្ម័គ្រចិត្ត ដែលគេពេញចិត្តមកបម្រើការងារក្នុងប្រទេសហ្នឹង គឺថាគាត់ គាត់នឹងរីករាយទទួលគេហើយ គាត់នឹង -- កន្លងមកគឺថា ជាក់ស្តែងគឺគាត់យកកម្លាំងសំខាន់ៗមកធ្វើការងារក្នុងក្រសួងការបរទេស

ហ្នឹង។ ភាគច្រើនហ្នឹង គឺបញ្ញាជនទាំងអស់ម្ដង។ យើងកសិករក្រីក្រហ្នឹង កម្មករហ្នឹងមិនចេះធ្វើទេ ការងារក្រដាសស្នាមអីនោះ មិនចេះធ្វើទេ។ ទាល់តែបងៗហ្នឹងបានគាត់ចេះ គាត់មានពិសោធន៍អារឿង ការងារទូតផង គាត់មានពិសោធន៍ទំនាក់ទំនងបរទេសផង។ ដល់អ៊ីចឹង គាត់រៀបចំ អាហ្នឹងគេមកធ្វើ ការងារ។ ច្រើនដែរនៅនឹងក្រសួងការបរទេសហ្នឹង គឺថាធ្វើការងារបានច្រើន។

[១១:៥៥:០៧]

**ស៖** តើពួកនិស្សិតនិងបញ្ញាជនទាំងអស់នោះដែលបានត្រឡប់មកវិញពីប្រទេស បរទេសផ្សេងៗ នៅក្នុងសម័យនោះ។ ថាតើគេបញ្ជូនទៅណាខ្លះនៅពេលដែលគេមកដល់ប្រទេសនោះ? ហើយតើក្រោយ មកជោគវាសនាអ្នកទាំងអស់នោះទៅជាយ៉ាងម៉េចដែរ?

**ឆ៖** ចំណុចនេះគឺថា តាំងពីរំដោះ ១៧ មេសា ៧៥ មកៗតាំងពីនោះមក គឺថាខាងប្រាំបីរយ-- មន្ទីរ៨៧០ ជាអ្នកគ្រប់គ្រងផ្ទាល់ ខាងខ្ញុំអត់មានទេ។ ខាងខ្ញុំគេរើសតែអ្នកចម្រើនៗ ដែលគេ ខាង៨៧០ គេឲ្យមក គឺគាត់នៅធ្វើការនៅក្រសួងហ្នឹង។ ឯក្រសួងផ្ទាល់ បងៗបញ្ញាជនមួយចំនួនទៀត អត់បាន គ្រប់គ្រងទេ។

**ស៖** តើលោកបានដឹងទីតាំងដែលស្ថិតក្រោមមន្ទីរ៨៧០ ដែលគេឲ្យនិស្សិតហើយនិងពួកបញ្ញាជន មកពីបរទេសនៅកន្លែងហ្នឹង តើលោកស្គាល់ទីតាំងកន្លែងហ្នឹងទេ?

**ឆ៖** ទីតាំងហ្នឹង គឺថានៅបឹងត្របែក កន្លែងហ្នឹងហើយធំជាងគេ។ ហើយដែលគេហៅថា ពន់តាឡី ត្រង់ណាទេ ពន់តាឡី គេហៅពន់តាឡី ឮតែឈ្មោះ ឮឈ្មោះពីរហ្នឹង។

**ស៖** តើបឹងត្របែកនៅពេលណាមួយនោះ គឺគេផ្ទេរទៅឲ្យ បាទ ផ្ទេរពីមន្ទីរ៨៧០ ឲ្យទៅខាង ក្រសួងការបរទេសគ្រប់គ្រងវិញដែរឬទេ? បឹងត្របែកនេះបាទ។

**ឆ៖** ចុងឆ្នាំ៧០ -- ៧៨ គឺថាបានៗ -- អង្កាល់ហ្នឹងបាត់ ប៉ង់ ទៅ ហើយបាត់នែ ឈ្មោះៗ អារ៉ន នៅគ្រប់គ្រងនៅបឹងត្របែកហ្នឹង បានក្រោយមកខាងមន្ទីរ៨៧០ ហ្នឹងប្រគល់ឲ្យខាងប-១ គ្រប់គ្រង។ គ្រប់គ្រង ពេលហ្នឹងគឺថា បងបញ្ញាជន បង ចេង អុន ហើយបន្ទាប់ទៀត បង ហោ ណាំហុង នៅនុ៎ងដែរ។ នៅអាចុងក្រោយនេះ។

[១១:៥៨:៣០]

**ស៖** មុនពេលដែលគេផ្ទេរបឹងត្របែកមកឲ្យក្រសួងការបរទេស តើលោកដឹងដែរឬទេថាលោក អៀង សារី ក្នុងឋានៈគាត់ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ មានការពាក់ព័ន្ធ ឬក៏ការទទួលខុសត្រូវចំពោះ

និស្សិត និងបញ្ញាជន ដែរឬទេនៅបឹងត្របែកនោះ?

**ឆ៖** ចំណុចហ្នឹងខ្ញុំអត់ដឹងថាមានការពាក់ព័ន្ធនៅក្នុងហ្នឹង ខ្ញុំអត់ដឹងទេៗ។ ប៉ុន្តែពេលដែលមន្ទីរ ៨៧០ ប្រគល់ឲ្យហ្នឹង គឺថាគាត់ទៅធ្វើការនៅហ្នឹង គឺថា គាត់បង សួរ ហុង ហើយខ្ញុំធ្វើការនៅហ្នឹង ទៅជួបបងៗបញ្ញាជនដែលនៅនុំង ទៅជួបដែរ ហើយបានបិទវគ្គរៀនសូត្រជាមួយគាត់នៅហ្នឹងទៅ។

**ស៖** តើលោកបានទៅបឹងត្របែកប៉ុន្មានដង នៅពេលដែលៗ មន្ទីរបឹងត្របែកហ្នឹងស្ថិតនៅមន្ទីរ ប-១ នោះ ក្រសួងការបរទេស?

**ឆ៖** ចាប់ពីពេលដែលថា បានប្រគល់ឲ្យខាងៗក្រសួងហ្នឹងមើលការខុសត្រូវ ខ្ញុំទៅញឹកញាប់ដែរ។ ញឹកញាប់គឺថា វាពាក់ព័ន្ធរឿងជីវភាពទេ។ វាពាក់ព័ន្ធអារឿងអង្ករម្ហូបម្ហារអីនេះ គឺថាខ្ញុំចេះតែដានទៅមើលដែរ គឺថាខ្ញុំទៅញឹកញាប់។ ជួនណាមួយអាទិត្យម្តងក៏មានដែរ។ ជួនណា១០ថ្ងៃម្តងក៏មានដែរ។ បើថាមានការចាំបាច់ ស៊ើងឆ្ងល់នៅកន្លែងនុំងទៅ ទៅភ្លាមក៏មានដែរ។ អ៊ីចឹង។

[១២:០០:៤៥]

**ស៖** តើលោកដឹងថា លោកអៀង សារី បានទៅបឹងត្របែកប៉ុន្មានដងទេបាទ?

**ឆ៖** តាមដែលបើគាត់ទៅហ្នឹង គឺថាគាត់ទៅខ្ញុំក៏ទៅ បងហុង ក៏ទៅ តាមខ្ញុំចាំគឺដូច ព្រោះវាចុង ៧៨ ហើយ គឺថាដូចជាបីដងទេ គាត់ទៅ។

**ស៖** ថាតើនៅបឹងត្របែកនោះមានមនុស្សប៉ុន្មាននាក់នៅក្នុងមន្ទីរហ្នឹង នៅពេលដែលលោកទៅនោះ?

**ឆ៖** ពេលដែលគាត់ទៅ -- ខ្ញុំទៅនោះ ឃើញគ្នាគាត់ច្រើន។ ប៉ុន្តែខ្ញុំមិនចាំឈ្មោះគាត់មិនអស់ទេ ចាំអត់អស់ទេ ប៉ុន្តែច្រើន។ មកមន្ទីរហ្នឹង គឺថាមកច្រើនទាំងប្តីប្រពន្ធៗ គាត់ហើយនិងកូនគាត់ក៏មានដែរ។ វាច្រើនពេក ខ្ញុំទៅគឺមនុស្សច្រើន ច្រើនមែនទែនតែម្តងនៅនុំង មិនតិចទេ។

**ស៖** លោកបាននិយាយថា លោក អៀង សារី បានផ្តល់ការណែនាំ ឬក៏ការបង្រៀន នៅពេលដែលគាត់ទៅបឹងត្របែក។ តើលោកអាចនិយាយឲ្យលម្អិតជាងហ្នឹងបន្តិចបានទេ ថាតើគាត់និយាយពីអ្វីគាត់បង្រៀនពីអ្វីនៅពេលនោះនុះ?

**ឆ៖** ខ្ញុំចាំពេលហ្នឹងគឺថា បើករៀនសូត្រហ្នឹង។ ទីមួយ គាត់ឧទ្ទេសនាមសភាពការណ៍សកលលោកហ្នឹងហើយ។ ហើយទីពីរ គាត់ឧទ្ទេសនាមសភាពការណ៍ក្នុងប្រទេស ហើយនិងក្នុងហ្នឹងគាត់សង្កត់ធ្ងន់គឺថា តួនាទីរបស់បញ្ញាជន ដែលត្រូវរួមចំណែក ហៅថាធ្វើបដិវត្តន៍សង្គមនិយមនេះក៏គាត់

វែកញែកឲ្យឃើញដែរ។

[១២:០៣:២២]

ទៅរួមចំណែក ព្រោះអីអ្នកដែលរៀនចេះដឹងជ្រៅជ្រះ ទៅចូលរួមធ្វើការកសាងខ្លួនក្នុងតាមទិសដៅដែលបដិវត្តន៍ដែលចង់បាន។ ហើយស្វ័យទិតៀន ទិតៀនដែរហ្នឹង ជួយមតិអីអីចឹងដែរ។ ដូចគេដូចឯងអីចឹង។ វាអីចឹង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំនៅសល់ពេលប្រហែល១០នាទីទៀត សម្រាប់សួរសំណួរ ហើយខ្ញុំបានសួរមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមេធាវីនាំមុខ ហើយគាត់ថា គាត់មិនត្រូវការល្ងាចទាំងស្រុងទេ។ ដូច្នេះ ខ្ញុំនឹងត្រូវការប្រើពេល១០នាទីចាប់ពីម៉ោងចាប់ផ្តើមពេលល្ងាចនេះ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តបញ្ចប់ ឬក៏អនុញ្ញាតឲ្យខ្ញុំចាប់ផ្តើមប្រើពេលនេះល្ងាច ១០នាទីមុននឹងដើមបណ្តឹងរដ្ឋប្បវេណីបាទ?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ ហើយចំណែកឯពេលវេលាដែលលោកស្នើសុំបន្ថែមបន្តទៀតនោះ គឺលោកអាចប្រើប្រាស់នៅពេលរសៀលជាមួយនឹងពេលវេលាដែលត្រូវបានបែងចែកជូនទៅខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី/អ្នកជំនាញ។ ចំពោះសាក្សីនៅក្នុងអំឡុង -- និងមេធាវីប្រឹក្សារបស់គាត់ នៅក្នុងអំឡុងពេលឈប់សម្រាកពិសាថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបានកំណត់អម្បាញ់មិញនេះ គឺម៉ោងមួយនិងសាមសិបនាទីរសៀល។

មន្ត្រីរដ្ឋបាល អ៎! មន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងរសៀលនេះឲ្យនាំគាត់មកកាន់បន្ទប់សវនាការវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី អាចប្រើប្រាស់ពេលវេលាសមស្របតាមសំណើសុំរបស់លោកកាលពីព្រឹកមិញ។

សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានប្រធានបទមួយចំនួនតូចទៀត ដែលត្រូវសួរទៅលោក។ ខ្ញុំចង់ត្រឡប់ទៅបញ្ហាដែលយើងបាននិយាយគ្នាកាលពីថ្ងៃសុក្រ គឺនិយាយអំពីដំណើររបស់លោក អៀង សារី នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៤។ លោកអាចជម្រាបខ្ញុំបានទេ ថាតើនៅពេលដែលគាត់ត្រឡប់មកឆ្នាំ១៩៧៤ តើគាត់ធ្វើដំណើរបានប្រហែលជាប៉ុន្មានដង? ប៉ុន្មានលើកដែរ?

[១៣:៣៥:២៥]

**លោក រ៉ចាម តុន៖**

**ឆ៖** តាមខ្ញុំចាំ គឺថាក្នុងៗ ៧៤ ហ្នឹងដូចជាដើមឆ្នាំដូចជាម្តង ហើយក្រោយមកទៀតដែលពេលមកចូលមហាសន្និបាតនៅ៧៤ម្តង តាមខ្ញុំចាំ ពីរដងហ្នឹង។

**ស៖** ដំណើររបស់គាត់ដែលចូលរួមនៅក្នុងមហាសន្និបាត នៅក្នុងខែមិថុនា ឆ្នាំ៧៤ ដែលយើងនិយាយគ្នាកាលពីថ្ងៃសុក្រនោះ។ តើគាត់ធ្វើអ្វីខ្លះទៀតក្នុងដំណើររបស់គាត់នៅឆ្នាំ១៩៧៤ នោះ? គាត់មានបំពេញកិច្ចការអ្វីទៀតដែរ បើតាមលោកចាំបាននោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី។ សូមអញ្ជើញលោកមេធាវី!

[១៣:៣៦:៣៩]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទចង់ធ្វើការបញ្ជាក់មួយ តាមរយៈអ្នកបកប្រែខ្ញុំបានឮតំណាងអយ្យការលើកឡើងថា គាត់បានជួបជាមួយសាក្សីនៅថ្ងៃសុក្រ។ អ៊ីចឹងខ្ញុំមិនដឹងថា ជួបនៅក្នុងសវនាការ ឬមួយក៏ជួបថ្ងៃសុក្រក្រោយសវនាការ ព្រោះថាថ្ងៃសុក្រយើងអត់មានសវនាការទេ។ សូមបញ្ជាក់បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកមេធាវី។ ខ្ញុំច្រឡំ គឺថាតាមការពិតខ្ញុំចង់សំដៅថាថ្ងៃព្រហស្បតិ៍ទេ តែខ្ញុំបានថាថ្ងៃសុក្រ។

[១៣:៣៧:២៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះក្រៅពីកិច្ចប្រជុំដែលយើងនិយាយគ្នាកាលពីថ្ងៃព្រហស្បតិ៍ និយាយអំពីមហាសន្និបាតដែលលោក អៀង សារី ចូលរួមនោះ ថាតើគាត់មានធ្វើដំណើរក្រៅពីហ្នឹងទៀតដែរឬទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** តាមៗខ្ញុំចាំដូចគាត់ចូលរួមសន្និបាត ដូចជាអត់មានទៅណាទៀតទេ គឺថាចប់សន្និបាតហើយគាត់ត្រឡប់ទៅវិញ។ ខ្ញុំអត់ចាំទេចំណុចហ្នឹង ខ្ញុំអត់ចាំគាត់ទៅណាទៀត អត់ដឹងដែរ។

**ស៖** លោកចាំទេ ថាតើមានការពិភាក្សាគ្នាអំពីការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញដែរឬទេនៅសន្និបាតខែមិថុនា ឆ្នាំ៧៤ នុ៎ង?

**ឆ៖** ចន្លោះហ្នឹង ដូចខ្ញុំស្តាប់អត់បានទេអាហ្នឹង ដូចអត់ឃើញបានពិភាក្សារឿងហ្នឹងទេ។

**ស៖** ប្រធានបទដែលខ្ញុំសួរលោកបន្ទាប់ទៀតនោះ ក្នុងរយៈពេលប៉ុន្មានខែដែលជិតមកដល់១៧ មេសា ៧៥ នោះ តើលោកមានដឹងឮ សួរគេនិយាយគ្នាអំពីពួកៗ មហាក្សត់ប្រាំពីរនាក់នៃរបប លន់ នល់នោះដែរឬទេ? លោកមានឮរឿងនេះទេ?

[១៣:៣៩:១១]

**ឆ៖** អត់ទេ អត់ដឹងទេ។

**ស៖** ខ្ញុំចំណុចដែលខ្ញុំចង់ត្រឡប់ថយទៅក្រោយវិញ គឺនិយាយពីកិច្ចប្រជុំនៅប-៥ នៅថ្ងៃ១៧ មេសា ៧៥ ដែលលោកបានលើកឡើងកាលពីថ្ងៃព្រហស្បតិ៍។ តាមរយៈការប្រជុំនៅប-៥ នោះ គឺការប្រជុំដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ។ តើផែនការនេះ ជាផែនការមួយដែលគេដឹងឮទូលំទូលាយ ដែលកម្មាភិបាលនៅប-៥ ទាំងអស់ដឹងឮគ្រប់ៗគ្នាដែរ ឬក៏យ៉ាងណា?

[១៣:៤០:០៨]

**ឆ៖** ក្រោយពីបានក្រុមដឹកនាំបានប្រជុំពិគ្រោះពិភាក្សា ក្រោយមកៗ គេផ្សព្វផ្សាយឲ្យដឹងឮគ្រប់ៗគ្នាហ្នឹងហើយ។

**ស៖** សូមអរគុណលោកសាក្សី។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមចាក់បញ្ចាំងខ្សែវីដេអូរយៈពេលតែ ១០នាទីទេ គឺដកស្រង់ចេញពីសំណុំរឿង D108/32.2 ដែលឯកសារមាន ERN 0017 -- គឺឯកសារ D69/V00172512 - V00172512 OK។ គឺខ្សែវីដេអូនេះ តែបញ្ចាំងមួយនាទី មានរយៈពេល ១:៤៤:២២ ដល់ ៣៤។ ខ្ញុំជឿ -- ខ្ញុំដឹងថា អង្គភាពខាងប្រព័ន្ធសោតទស្សន៍នេះ គឺគាត់មានខ្សែវីដេអូនេះ។ យើងខ្ញុំមិន -- នឹងមិនបញ្ចាំងឲ្យឮទាំងសំឡេងទេ គ្រាន់តែបញ្ចាំងឲ្យចេញជារូបភាព ដើម្បីរំឭកនូវការចងចាំ។ សូមជម្រាបលោកប្រធានថា ប្រហែលជា ១០ វិនាទីទេ មិន ១០នាទី ដូចថាអម្បាញ់មិញទេ។

[១៣:៤២:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ផ្នែកខាងសោតទស្សន៍ចាក់បង្ហាញឯកសារវីដេអូនេះ នៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី បើសិនជាលោកចង់មើលម្តងទៀត ខ្ញុំអាចសុំការបញ្ចាំង? តែលោកចាំទេរូបអម្បាញ់មិញ រូបមនុស្សបីនាក់នៅក្នុងខ្សែវីដេអូនេះ លោកស្គាល់ទេ?

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ដាក់បញ្ចាំងឯកសារអម្បាញ់មិញនេះម្តងទៀត!

[១៣:៤៣:៥៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកអាច -- តើលោកស្គាល់មនុស្សបីនាក់នៅក្នុងខ្សែវីដេអូនេះដែរឬទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** បីនាក់នេះ ឃើញ អ៊ំ ប៉ុល ពត, អ៊ំ នួន ជា ហើយ អ៊ំ ខៀវ សំផន អំមិញហ្នឹង។

**ស៖** ហើយតាមរយៈខ្សែវីដេអូនេះ លោកឃើញខ្ទមមួយ ខ្ទមដែលមានដំបូងស្លឹក ដំបូលស្បូវនេះ គឺតើខ្ទមនេះ វាដូចគ្នាទៅនឹងខ្ទមនៅ ប-៥ ដែលលោកបានជម្រាបជូនតុលាការកាលពីថ្ងៃព្រហស្បតិ៍ថា មានកិច្ចប្រជុំនៅថ្ងៃ១៧ មេសា ៧៥ នោះ។ តើខ្ទមហ្នឹងមានលំនាំរាងរ៉ូវវាដូចគ្នាទៅនឹងអ្វីដែលលោកថាមានប្រជុំនៅថ្ងៃ១៧ មេសា ៧៥ នោះដែរឬទេ នៅ ប-៥ នោះ?

[១៣:៤៥:០៥]

**ឆ៖** ខ្ទមហ្នឹងដូចគ្នាហ្នឹងហើយ ឃើញដូចគ្នាអំមិញហ្នឹង។ ប៉ុនអំមិញឃើញតែបីនាក់ ដែលខ្ញុំនិយាយថ្ងៃមុនហ្នឹងឃើញគ្នាច្រើនទេអាន៎ុង។

**ស៖** សូមអរគុណលោកជាច្រើន លោកសាក្សី លោកចំណាយពេលវេលា និងផ្តល់ការពន្យល់ជាលម្អិត។

**លោក ឌេល លីសាក់៖**

លោកប្រធាន សូមជម្រាបថាខាងតំណាងសហព្រះរាជអាជ្ញាគឺអស់សំណួរហើយ។

សូមអរគុណ។

[១៣:៤៥:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ មេធាវីនាំមុខនឹងសូមអនុញ្ញាតផ្ទេរការសួរនេះជូនទៅលោក ឡោ ជុនធី ហើយបន្ទាប់មក លោកស្រី អេលីហ្សាបេត

ស៊ីម៉ុនណូហ្វត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៤៦:២៨]

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ ហើយជាដំបូង ខ្ញុំបាទសូមគោរពលោកប្រធាន ហើយសូមគោរពលោកលោកស្រីចៅក្រម ហើយសហភាគា ហើយបងប្អូនដែលចូលរួមនៅសវនាការនេះ ហើយសូមជម្រាបសួរលោកសាក្សីផង បាទ។ ខ្ញុំបាទឈ្មោះ ឡោ ជុនធី ជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។

**ការតាំងសំណួរដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះ ខ្ញុំបាទនឹងជម្រាបសួរលោកពូទៅតាមប្រធានបទនីមួយៗ ដែលបានលើកឡើងនៅក្នុងបរិបទប៉ុន្មានថ្ងៃនេះ។ ដូច្នេះខ្ញុំបាទសូមជម្រាបសួរសំណួរដំបូង ថាតើលោកសាក្សីដែលបានចូលបដិវត្តន៍ហ្នឹង គឺបានចូលបដិវត្តន៍ពីឆ្នាំណាមកដែរ?

**លោក រ៉ាចាម តុន៖**

**ឆ៖** ខ្ញុំចូលបដិវត្តន៍ហ្នឹងគឺថា ដើមឆ្នាំ៦៣។ ហើយខ្ញុំបានចេញពីផ្ទះ គឺថា៦៦ ថ្ងៃ២៤ ខែ៨ ៦៦ ខ្ញុំចេញពីផ្ទះ។ កាល ៦៣ ហ្នឹងគឺថាធ្វើបដិវត្តន៍ ធ្វើផ្ទះ បដិវត្តន៍ក្នុងភូមិ នៅភូមិរបស់ខ្លួនហ្នឹង។

[១៣:៤៨:២១]

**ស៖** បាទ អរគុណ។ ខ្ញុំជម្រាបសួរថាតើពេលដែលលោកចូលបដិវត្តន៍ហ្នឹង លោកកាលណោះប្រហែលជាអាយុប៉ុន្មានដែរ?

**ឆ៖** ខ្ញុំកាលណោះ គឺអាយុ១៦-១៧ ឆ្នាំហ្នឹងឯង។

**ស៖** បាទ អរគុណ។ ខ្ញុំចង់ដឹងថា តើនៅពេលដែលលោកចូលបដិវត្តន៍ តើលោកយល់អំពីថាខ្លឹមសារថា អ្វីទៅជាបដិវត្តន៍នោះ? បាទ លោកយល់ពីចំណុចនេះទេ?

**ឆ៖** ខ្ញុំមានលំនាំរបស់ខ្ញុំ គឺថាលោកពូរបស់ខ្ញុំហ្នឹង គាត់អង្គាល់៥៤ ហ្នឹង គឺគាត់ទៅវៀតណាមដែរ ហ្នឹងគឺអ៊ីចឹង។ ហើយលោកឪខ្ញុំ គឺថាជំនាន់ឥស្សរៈហ្នឹងគាត់ចូលរួមក្នុងឥស្សរៈដែរ។ ដល់អ៊ីចឹង

គាត់ចេះទេប្រាប់ហូរហែមក គាត់ថាមើលគំរូពូ លោកពូក៏ទៅ តាំងពី៥៤ហ្នឹង បាត់ខ្លួនឃើងអត់ឃើញ គាត់ចូលរួមទៅសិក្សាពីរឿង -- អង្កាល់ហ្នឹងទៅសិក្សាពីរឿងថា "កុម្មុយនីស្ត" ហើយនៅពេលនោះ វាមែនទែន វាមិនច្បាស់លាស់អីទេ។ ហើយឃើញចលនាវៀតណាមខាងជើងហ្នឹងក៏មាន គឺថាឆ្លងកាត់ៗពីជើងទៅត្បូងហ្នឹង ឃើញក្នុងលាក់ការណ៍ដែរ ឃើញៗគេមានកាំភ្លើង ឃើញគេមាន -- គេហៅថា ឯកសណ្ឋានរបៀបគេថាមានកាំភ្លើងមានទូសៀរ មានខោអាវអីស្អាតបាត មានម្ជូកអីចឹង។ ឃើញដំបូង ឃើញលំនាំឃើញអីចឹង។

**ស៖** បាទ អរគុណ។ ចំណុចអ្វីដែលខ្ញុំចង់បញ្ជាក់បន្ថែម គឺថាអ្វីដែលលោកបានលើកឡើងហ្នឹង គឺថាវាមានពាក់ព័ន្ធខ្សែស្រឡាយតាំងពីលោកឪពុក តាំងពីអ៊ំ តាំងពីអីមកណោះ។ ប៉ុន្តែអ្វីដែលមកដល់ជំនាន់លោកពូថា តើខាងៗខ្មែរក្រហមហ្នឹងគេបានបញ្ចុះបញ្ចូលលោកពូជំនាន់ហ្នឹងថាម៉េចដែរ ចំពោះលោកពូដែលជាជនជាតិ គឺថាជនជាតិនៅខាងរតនគិរី ជនជាតិចារាយហ្នឹង តើគេបញ្ចុះបញ្ចូលយ៉ាងម៉េចថាបដិវត្តន៍ហ្នឹងមានការដឹកនាំល្អ ឬមួយយ៉ាងម៉េចបាទ?

[១៣:៥២:១៤]

**ឆ៖** ឃើញជាក់ស្តែងនៅក្នុងភូមិខ្ញុំដំបូងហ្នឹង គឺថាៗនាំសំបុត្រពីភូមិមួយទៅភូមិមួយ។ អាហ្នឹងខ្ញុំឃើញហេតុការណ៍ដែលខ្ញុំចូលរួម។ ហេតុការណ៍មួយទៀត ឃើញប្រជុំក្នុងព្រៃនាំគ្នាប្រជុំក្នុងព្រៃហ្នឹងៗពួបងថ្លៃខ្ញុំគាត់អប់រំ កាលហ្នឹងមិនដឹងថាគេហៅថា "យុវជនយុវនារី" ក្នុងព្រៃគាត់ថា "យើងជាយុវជនយុវនារី ហើយយើងជាជនជាតិ គឺថាការរៀនសូត្រក៏គ្មាន ការចេះដឹងអីៗ ក៏គ្មានដែរ។ ដូច្នេះយើងនេះ ឥឡូវវាមានពន្លឺៗថាកាលហ្នឹងគឺថា កាលហ្នឹងមិនទាន់ដាច់ដោយឡែកទេគឺថា ធ្វើបដិវត្តន៍ឥណ្ឌូចិនមែនទែនពេលនុ៎ង ឥណ្ឌូចិន ថាអីចឹង។ មិនទាន់ច្បាស់ថាខ្មែរយើងទេ ព្រោះខ្ញុំកាលហ្នឹង ខ្ញុំក៏ចេះខ្មែរដែរ ខ្ញុំអត់ចេះទេកាលនុ៎ងនោះ។ ខ្ញុំអត់ទាន់ឃើញខ្មែរផង កាលដំបូង។ ខ្ញុំដឹងតែតាមរយៈបងថ្លៃខ្ញុំទេ គាត់បានអប់រំអីចឹង។ គាត់បានជួបៗគេហើយ តែខ្ញុំមិនទាន់បានទេ ខ្ញុំនៅក្មេងណាស់ កាលជំនាន់ហ្នឹង។ គាត់អប់រំអីចឹង គាត់ថា "ក្នុងន័យធ្វើបដិវត្តន៍នេះ គឺន័យហ្នឹងគាត់បញ្ជាក់ថាមានការជិះជាន់ គឺមានការតស៊ូ។ បើចង់ទៅតស៊ូឈ្នះហ្នឹង ទាល់តែធ្វើបដិវត្តន៍។ ហើយថាធ្វើបដិវត្តន៍ហ្នឹង ទាល់តែធ្វើប្រទេសយើងតែមួយជួយមិនឈ្នះទេ ទាល់តែវៀតណាមផង ឡាវផង យើងផង។ រួមគ្នាធ្វើបដិវត្តន៍ បានសត្រូវដែលយើងបានកំណត់ បានយើងបាញ់ទៅវាឆាប់ឈ្នះ។ គាត់និយាយជាភាសានៅក្នុងហ្នឹង គាត់មិនដឹងគាត់យល់ដឹងពីណាមកទេ ប៉ុន្តែគាត់មានការរៀនសូត្រនេះហ្នឹង ខ្ញុំៗទទួលពីគាត់ៗនិយាយអីចឹង។

និយាយអ៊ីចឹងខ្ញុំក៏ ដូចៗក្នុងយុវជនយុវនារីក្នុងភូមិហ្នឹង មានគេភ្ញាក់រឭកខ្ញុំប៉ុន្មានហើយ ប៉ុន្មាននាក់ទៅហើយ ខ្ញុំហ្នឹងបើកវគ្គទីពីរ។ វគ្គទីមួយបងៗ មុនខ្ញុំហ្នឹង មួយចំនួនធំទៅហើយ។ ខ្ញុំវគ្គពីរទេ ខ្ញុំវគ្គពីរ។

[១៣:៥៥:១១]

កាលហ្នឹងពិគ្រោះពិភាក្សាជាមួយម៉ែឪទៅ គាត់ថាកូនប្រុសនោះ បើអាចទៅឆ្ងាយទៅ ក៏ទៅរៀនសូត្រនឹងគេនឹងឯងទៅ។ ពូឯងមានគំរូ ពូឯងទៅមួយហើយមិនដឹងជាពូ -- ឥឡូវមិនដឹងថាយ៉ាងណាទេ គាត់ថាថ្ងៃណាមួយគាត់នឹងត្រឡប់មកវិញ។ ម៉ែឪខ្ញុំគាត់ពិគ្រោះពិភាក្សាគ្នាអ៊ីចឹង ហើយបងប្អូនខ្ញុំ គាត់លើកឡើងថា ដូចបងខ្ញុំ ខ្ញុំមានបងគេបង្អស់ហ្នឹងមួយ។ ហើយគាត់មានឥទ្ធិពលលើខ្ញុំដែរ គាត់ថាប្អូនឯង គាត់ថា ប្អូនឯងមិនសូវឈឺមិនសូវអីអ៊ីចឹងទៅៗ។ បងៗឧស្សាហ៍ឈឺ បងមិនបានទៅទេ។ ប្អូនឯងទៅមុនទៅ គាត់ថាអ៊ីចឹង។

អ៊ីចឹងខ្ញុំរៀបរាប់អារឿងពីផ្ទាល់ខ្លួនខ្ញុំ ដែលខ្ញុំថា ចូលរួមធ្វើបដិវត្តន៍ ដូចថា ដូចជាមិនដែលបង្ខំអីប៉ុន្មានផង។ ដូចជាស្ម័គ្រចិត្ត ស្រាប់តែចូលទៅនៅក្នុងព្រៃ ចូលនឹងគេនឹងឯងអ៊ីចឹងទៅ។ គេថាៗលំបាក។ ទេលំបាក គេម៉េចក៏ចូលយើងម៉េចក៏ចូលបាន ខ្ញុំតាំងចិត្តអ៊ីចឹង។ ខ្ញុំចូលទៅ។ ចូលទៅមុនដំបូងទៅនៅកណ្តាលព្រៃហ្នឹងរាប់ខែដែរហ្នឹង។ អ៊ីចឹង។

[១៣:៥៦:២៦]

**ស៖** បាទ អរគុណលោកពូច្រើន។ ដោយសារខ្ញុំលើកសំណួរនេះ ពីព្រោះថា ក្នុងរឿងបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យនេះ វាមាន គឺថាការបញ្ចេញនូវមនោគមន៍វិជ្ជា។ អ៊ីចឹងហើយបានជាខ្ញុំលើកឡើងថា តើអ្វីដែលបក្សបានដឹកនាំ ហើយតើបក្សដឹកនាំប្រជាជនទៅបែបណាដែលធ្វើឲ្យដណ្តើមបាននូវជ័យជម្នះហ្នឹង។ អ៊ីចឹងហើយ សំណួរខ្ញុំ ខ្ញុំលើកឡើងថា តើអ្វីដែលបក្សដឹកនាំហ្នឹង តើដឹងថា គោលដៅរបស់បក្សដែលបានដឹកនាំហ្នឹង ធ្វើឲ្យសម្រេចនូវគោលដៅណាមួយ ឬមួយយ៉ាងម៉េច?

**ឆ៖** បន្ទាប់មកទៀត អាហ្នឹងខ្ញុំនិយាយតែក្នុង៦៣។ ៦៤ហ្នឹង មានឮដំណឹងបងថ្លៃខ្ញុំថា ថាយើងបន្តិចទៀត យើងនឹងមានបដិវត្តន៍ខ្មែរ។ គាត់ថា បន្តិចទៀតគេមានហើយ បន្តិចទៀតយើងបានឃើញទាំងអស់គ្នាហើយ។ ដល់ឃើញទាំងអស់គ្នា រឹតតែជិត រឹតតែចង់ឃើញទៀតណ៎ា ចិត្តចង់តែម្តង។ ចង់គេថា បដិវត្តន៍ហ្នឹង គឺថាចង់តែធ្វើតែម្តង គឺត្រូវចិត្តខ្លួនឯង ចង់តែម្តង គឺដូចស្តាប់ ដូចជាស្រួលដែលលំបាកដែរ ប៉ុន្តែដូចជាមើលថាទៅ ដូចជានិយាយទៅ ដូចជា វាដូចថា ដូចជាចាប់អារម្មណ៍ថា ដូចមានកំហឹងមួយកម្រិតតែម្តង។ កំហឹងយ៉ាងម៉េច? ដល់គេនិយាយតែរឿងជិះជាន់ហ្នឹង គឺថាមានកំហឹងយក

ម្តង។ កំហឹងត្រង់ថា យើងជាមនុស្សមួយនឹងគេដែរ យើងកូនប្រុសនឹងគេមួយដែរ យើងទៅខ្លាចអីលំបាកហ្នឹង។ គេធ្វើម៉េច យើងធ្វើអ៊ីចឹងទៅ។ អាហ្នឹងខ្ញុំនិយាយបញ្ជាក់ថា ចិត្តខ្លួនឯងអ៊ីចឹង។

[១៣:៥៨:៤១]

ដល់ចេះតែតាមដានមក៦៤។ ៦៥ ស្រាប់តែឃើញចលនាវៀតណាមហ្នឹងខ្លាំងជាងគេតែម្តង។ មកចុះពីហាណូយមក មកវៀតណាមខាងត្បូង ៦៥ហ្នឹងច្រើនមែនទែនម្តង។ ពេញព្រៃ ពេញទឹកសុទ្ធតែវៀតណាមតែម្តង។ ហើយមកដល់អង្កាល់៦២ហ្នឹង វាមានបញ្ហាអាសន្នអ៊ីចេះ កាលនៅជិតភូមិខ្ញុំហ្នឹង គេហៅថា ភូមិញ៉ាង ហ្នឹង។ កាលហ្នឹងលេងកប៉ាល់ហោះទៅទម្លាក់ម្តង កាល៦២ហ្នឹងទៅទម្លាក់មុនគេ មុនឯងម្តងនៅកន្លែងហ្នឹង។ ថាឃើញទម្លាក់ហ្នឹង ឃើញហ្នឹងដល់ហើយ រត់ ដូចវេទនាតែម្តង។ យី! អាចក្រពត្តិអាមេរិកហ្នឹង វានិយាយទៅវាឆាប់យល់ដែរ ថាចក្រពត្តិអាមេរិកវាមកឈ្លានពានអ៊ីចឹង វាមកទម្លាក់ យើងមិនមានរឿងរ៉ាវអីវាផង ស្រាប់វាមកទម្លាក់ ទាំងងាប់ ទាំងរបួស។ អង្កាល់ហ្នឹងព្រះករុណាយក -- អ្នករបួស ព្រះករុណាយកកប៉ាល់ហោះទៅយក ទៅដឹកមកព្យាបាលនៅភ្នំពេញ។ ជាដឹកទៅវិញ។ ដល់រូបនោះ ខ្ញុំកាន់តែឃើញច្បាស់ម្តង ហ៎! អាហ្នឹងគេហៅថា ចក្រពត្តិហ្នឹង គេបង្រៀនតែចក្រពត្តិហ្នឹង ចក្រពត្តិអ៊ីចឹងមែន ដល់តែទម្លាក់ដាក់គេដាក់ឯងហ្នឹង។ ប្រទេសវាយ៉ាងម៉េច បើទម្លាក់ប្រជាជនៗវាមិនខឹងវា? អានេះវាឆ្លង មិនដឹងទ្វីបណាផង លេងមកឈ្លានពាន មកទម្លាក់មកដល់ស្រុកខ្មែរ ជាយដែន។ អានេះ ខ្ញុំឃើញរូបភាព ខ្ញុំឃើញរូបភាពហ្នឹងមួយ ហើយខ្ញុំឃើញរូបភាពចលនាពីវៀតណាមខាងជើង មកខាងត្បូង ច្រើនមែនទែនម្តង៦៥។

[១៤:០០:១៤]

ឃើញទៅកាន់តែឃើញពន្លឺ អ្ហែ ធ្វើបដិវត្តន៍នៅឥណ្ឌូចិនបែបសប្បាយដែរតាមមើល។ ឃើញមកជាអង្គភាពៗតែម្តង ដល់ហ្នឹង៦៥។ ដល់៦៦ នេះ សម្រេចចិត្តតែម្តងចេញពីភូមិបណ្តោយ ចេញពីភូមិទៅនៅ -- ចេញពីភូមិខ្លួនឯងទៅនៅភូមិខាងពុកខ្ញុំទេ។ ប៉ុន្តែពុក -- ភូមិពុកខ្ញុំ នៅក្នុងភូមិខាងពុកក៏ដោយ យី! គេថាគេ -- ចាកចេញពីផ្ទះ គេថាទៅធ្វើបដិវត្តន៍ គឺថាត្រូវតែទៅនៅហ្នឹងតែម្តង។ ទៅៗនៅហ្នឹងមួយរយៈធំដែរ បានឃើញៗអ្នកអប់រំហ្នឹង គឺថាមិនទាន់មានអីទេ មានតែជនជាតិគ្នាឯងហ្នឹងច្រើនណាស់ ដល់ចូលទៅ បានឃើញគេទៅប្រជុំ បានឃើញ ថាអ្ហូ ភូមិនេះៗក៏មានមេដឹកនាំ ភូមិនោះក៏មានមេដឹកនាំៗ។ ដល់អង្កាល់ហ្នឹង ខ្ញុំមិនទាន់ដើរទៅឯណាទេ ខ្ញុំនោះ អត់ដើរទេ ខ្ញុំនៅតែក្នុងភូមិហ្នឹងដល់ខ្ញុំចូលបដិវត្តន៍ ស្រាប់ឃើញគេមករៀនសូត្រហ្នឹង ឃើញប្លែកៗ ហើយនិយាយទៅវារាង លើក

ឡើងចលនា ដូចវាវាងរំភើបដែរ ឃើញអ៊ីចឹង។ នេះដោយជម្រើសដែលធ្វើបដិវត្តន៍ហ្នឹងគឺថា ដែលៗ បដិវត្តន៍ដែលច្បាស់ជាងគេ ដល់ខ្ញុំជួបអ៊ំ អៀង សារី ដល់៦៧ គាត់អប់រំបានច្បាស់។ បានឃើញហ្នឹង រូបហ្នឹងគឺថា ម៉ាក្ស, អង់ហ្គែល, លេនីន, ស្តាលីន។ គាត់អប់រំនេះបានច្បាស់តែម្តង។ អូ៎ បដិវត្តន៍នេះតើ វាមានទិសដៅរបស់វាច្បាស់អ៊ីចឹងតើ គេហៅថា បដិវត្តន៍ហ្នឹង។ អ៊ីចឹង ខ្ញុំចង់រៀបរាប់ជាក់ស្តែងដែលខ្ញុំ បានឆ្លងកាត់វាអ៊ីចឹង។

[១៤:០១:៥៣]

**ស៖** បាទ អរគុណ។ សំណួរខ្ញុំបន្តទៀតគឺ នៅថ្ងៃទី២៦ កក្កដា ឆ្នាំ២០១២ នេះ វេលាម៉ោង ១១ និង១១នាទី ពេលដែលលោកតំណាងអយ្យការបានសួរទៅលោកពីរូបថតចំនួនបីសន្លឹក។ លោកបាន និយាយថា "ទីតាំងនៃរូបនេះគឺនៅជិតភូមិត្រពាំងព្រៃ"។ តើត្រពាំងព្រៃនេះ នៅខាងណាភូមិត្រពាំងទឹម ដែលសព្វថ្ងៃនេះ នៅខាងលិចស្ទឹងជីនិត ក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ? នេះគឺចង់បញ្ជាក់ អំពីទីតាំង ថាតើត្រពាំងព្រៃ ឬមួយត្រពាំងទឹមបាទ? លោកឆ្លើយ។

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះគឺថា ត្រពាំងទឹម ត្រពាំងព្រៃ ហើយមន្ទីរនេះវានៅចន្លោះ ត្រពាំង ទឹម ហើយនិងត្រពាំងព្រៃ។ បើយើងធ្វើដំណើរពីលិចទៅ ទៅត្រពាំងទឹមនោះហើយ បើយើងធ្វើដំណើរពី ត្រពាំងទឹមទៅ បានវាទៅដល់មន្ទីរហ្នឹងៗ។ មន្ទីរហ្នឹងគឺថា វាជិតទៅភូមិត្រពាំងព្រៃហ្នឹង មន្ទីរហ្នឹង ហើយវានៅខាងលិចស្ទឹងជីនិត។

**ស៖** បាទ អរគុណ។ សូមបញ្ជាក់ឡើងវិញល្អ។ នៅក្នុងឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៤ តើ ប៉ុល ពត និងលោក ខៀវ សំផន មានការជួបគ្នាជាញឹកញាប់ដែរឬទេ?

[១៤:០៤:០៤]

**ឆ៖** ពីឆ្នាំ៧១ ចន្លោះហ្នឹង គឺជួបគ្នាញឹកញាប់ ដែលមន្ទីរដែលនៅដាច់ពីគ្នាមួយរយៈខ្លីទេ ដល់ ក្រោយមកគឺមន្ទីរនៅជាមួយគ្នាតែម្តង ក្នុង៧១ហ្នឹងមន្ទីរនៅជាមួយគ្នាតែម្តង។ គាត់គឺថា អ៊ំ ខៀវ សំផន ក៏មកនៅៗមន្ទីរហ្នឹងបណ្តោយអ៊ីចឹង នៅជាមួយគ្នា។ ដូចខ្ញុំបញ្ជាក់កាលពីថ្ងៃមុនហើយថា ពេលខ្លះគាត់ ធ្វើការជុំគ្នា គាត់បីនាក់ មែនទែនបីនាក់ អ៊ំទីមួយ អ៊ំទីពីរ ហើយអ៊ំ ខៀវ សំផន។ ប៉ុន្តែថ្ងៃខ្លះហ្នឹង អ៊ំ ប៉ុល ពត គាត់សរសេរសៀវភៅ សរសេរន៎ៃ សរសេរនៅនឹងផ្ទះគាត់ទៅ។ អ៊ំ នួន ជា គាត់សរសេរនៅផ្ទះហ្នឹង គាត់ទៅ ហើយអ៊ំ ខៀវ សំផន សរសេរនៅនឹងផ្ទះគាត់ហ្នឹងទៅ។ អ៊ីចឹង ឃើញគាត់ធ្វើការអ៊ីចឹង។ បើមិន ប្រជុំគ្នាបីនាក់ទេ គឺរៀងៗខ្លួនគឺសរសេរ។

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលគាត់ជួបគ្នា ហើយអ៊ំបានសង្កេតឃើញទេថា តើពេលជួបគ្នាហ្នឹង អាចថាពេលល្ងាចៗឡើងគាត់ឧស្សាហ៍ជួបគ្នា ឬមួយយ៉ាងណាដែរ? ជួបគ្នាពិភាក្សាគ្នាបាទ។

[១៤:០៥:៤៧]

**ឆ៖** ជួបគ្នាហ្នឹង គឺថាពេលព្រឹកត្រូវនែ ទៅហូប -- ទៅពិសាបបរ ឬមួយពិសា ថាពិសាបបរទៅចុះ ពិសាបបរ។ គាត់ពិសាបបរហើយ គាត់នែ រួចហើយគាត់ជួបជុំគ្នាទៅ។ ពីម៉ោងប្រាំបីព្រឹកដល់ម៉ោងដប់មួយអ៊ីចឹងទៅ។ ដល់ថ្ងៃត្រង់គាត់ទៅពិសាបាយជុំគ្នាទៀត ហ្នឹង។ ហើយដល់គាត់សម្រាកទៅថ្ងៃរសៀលគាត់ធ្វើការទៀត។ ដល់ល្ងាចដល់ម៉ោងគាត់ចប់ពីការងារ គាត់ពិសាបាយ ពិសាបាយហ្នឹងគឺថានៅតាមរៀងៗខ្លួនតាមផ្ទះហ្នឹងទៅ អ៊ីចឹងទៅ។

**ស៖** អ៊ីចឹងមានន័យថា គាត់ឧស្សាហ៍ជួបគ្នា ហើយជួបគ្នាហ្នឹងជាញយៗដង ហើយបានន័យថាជួបគ្នាជាបន្តបន្ទាប់ ពិភាក្សាគ្នាជាបន្តបន្ទាប់ ជាៗរឿយៗអ៊ីចឹងតែម្តង ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ គាត់ជួបគ្នាញឹកញាប់ជារឿយៗ ខ្ញុំឃើញជាក់ស្តែងអ៊ីចឹង។

**ស៖** ចំណុចមួយទៀត ដែលខ្ញុំចង់ជម្រាបសួរផងដែរ គឺថានៅមុនពេលរំដោះនៅឆ្នាំ១៩៧៥ នៅខែមេសា ថ្ងៃទី១៧ មេសា បាទ។ តើមានសេចក្តីអំពាវនាវអំពីអ្នកណាដល់ទាហាន លន់ នល់ និងប្រជាជនដែរឬទេ? អ្វីដែលៗខ្ញុំចង់សួរនេះ ថាតើការអំពាវនាវនេះតាមវិទ្យុ តើលោកបានៗដឹងឮការអំពាវនាវហ្នឹងដែរអត់ទេ? ហើយការអំពាវនាវហ្នឹងដោយអ្នកណាដែរ?

[១៤:០៧:៥៩]

**ឆ៖** អំពាវនាវ គឺៗថាចំហហ្នឹង គឺលោកអ៊ំ ខៀវ សំផន ហើយគាត់អ្នកគាត់អំពាវនាវ។

**ស៖** បាទ អរគុណ។ ថាតើការអំពាវនាវរបស់លោក ខៀវ សំផន ហ្នឹង តើជាការអំពាវនាវទៅលើឲ្យនរណាចូល ឬមួយឲ្យទាហានហ្នឹងដាក់អាវុធ ឬមួយយ៉ាងម៉េច ការសេចក្តីអំពាវនាវរបស់គាត់ហ្នឹងបាទ?

**ឆ៖** សេចក្តីអំពាវនាវរបស់អ៊ំ ខៀវ សំផន ព្រោះអង្កាល់នុំង គឺថាគាត់ជាអគ្គបញ្ជាការ។ នេះវា -- អំពាវនាវទាំង -- គេហៅថា ទាំងទាហាន ទាំងស៊ីវិល អំពាវនាវទាំងប្រជាពលរដ្ឋ ដើម្បីកុំឲ្យបង្ហូរឈាមខ្មែរគ្នាឯង។

**ស៖** បាទ អរគុណ។ ខ្ញុំចូលនៅចំណុចមួយទៀតថា កន្លងមកបដិវត្តន៍បានជម្លៀសប្រជាជននៅ

ក្រុងមួយចំនួន នៅតាមតំបន់រំដោះមួយចំនួននោះណា។ ថាតើការជម្លៀសហ្នឹង ដែល ពេលដែលជម្លៀសចេញហើយ ប្រជាជននុំង ត្រូវឲ្យត្រឡប់មកផ្ទះសម្បែងវិញដែរអត់ទេ?

**ធ៖** តាមឃើញជាក់ស្តែង គឺថាអ្នកដែលបានជម្លៀសហើយ មិនដែលមានផែនការអីថាឲ្យត្រឡប់មកវិញទេ អត់មានទេ អត់ឃើញទេ។

**ស៖** បាទអរគុណ។ ចុះតើនៅពេលដែលមានការរៀបចំប្រជុំបង្កើតនូវសេចក្តីសម្រេចមួយដើម្បីធ្វើជម្លៀសប្រជាជនចេញតាមទីប្រជុំ និងជាពិសេស នៅទីក្រុងភ្នំពេញតែម្តងនេះ មុនឆ្នាំ មុនថ្ងៃជ័យជម្នះ ១៧ មេសា ថាតើការជម្លៀសនេះ យកបទពិសោធន៍ពីការជម្លៀសមុនៗ ត្រង់ចំណុចណាខ្លះ ដែលយកបទពិសោធន៍ហ្នឹងមកបាទ?

[១៤:១១:៤៣]

**ធ៖** ឃើញៗ ជាក់ស្តែង គឺថាដែលរំដោះមុននឹងរំដោះភ្នំពេញ ខ្ញុំឃើញជាក់ស្តែង ដែលខ្ញុំបានឆ្លងកាត់ ខ្ញុំឃើថា មានតែឧដុង្គហ្នឹងមួយទេ ឧដុង្គដែលខ្ញុំបានឆ្លងកាត់ជាក់ស្តែង។ ឯក្រៅពីហ្នឹង ដូចកន្លែង បងសេន ក៏ដូចគ្នា ដូចជម្លៀសដូចគ្នាដែរ។ ហ្នឹងគឺថាយកពិសោធន៍ហ្នឹង ឃើញថាប្រជាជនដែលយើងជម្លៀសពីទីប្រជុំទៅ គាត់ទៅតាមៗសហករណ៍ ឬក៏មួយទៅតាមមូលដ្ឋានតំបន់។ និយាយរួមទៅនៅមូលដ្ឋានរំដោះរបស់យើង ថាវាមិនដែលមានរឿងអី ដែលអាចលើកឡើង អាចឃើញជាបញ្ហាគឺឃើញដូចជាវាអត់មាន ចន្លោះហ្នឹង ដូចអត់មាន។ ឃើញថា លំនាំហ្នឹង ឃើញថាវាល្អ។

[១៤:១៣:០៣]

ហើយតាមដែលកងទ័ពដែលជាក់ស្តែងដែលនៅលើសមរភូមិ កងទ័ពដែលធ្វើការងារ ដែលកន្លែងរំដោះ កន្លែងដែលអីរំដោះហើយ គាត់ថាបើយើងជម្លៀសចេញប្រជាជនអ៊ីចឹង គឺថាវាស្រួលគ្រប់គ្រងតែម្តង។ វាស្រួលគ្រប់គ្រង។ វាអត់មានរញ៉េរញ៉ៃជាមួយប្រជាជន។ អាហ្នឹងគឺថាវាល្អតែម្តង វាអត់មានបញ្ហាអីជាមួយប្រជាជន គឺថាគាត់ចេញអស់ហើយ គឺអស់ហើយ។ នៅកន្លែងហ្នឹង គឺនៅតែយើងហ្នឹងវាៗតែមួយអ៊ីចឹងទៅ វាអត់មានបញ្ហាលំបាកទេ វាស្រួល។ ក្តាប់សភាពការណ៍ បើខ្មាំងចង់បង្កប់ក៏មិនមានអីនឹងពិបាករកទេ អាហ្នឹង។ បើថាឃើញថាវាស្រួល អ៊ីចឹង។

[១៤:១៣:៥៣]

**ស៖** ខ្ញុំចង់បន្តបន្តិចនូវអ្វីដែលលោកពូបានលើកឡើងអម្បាញ់មិញ គឺថាការជម្លៀសនៅឧដុង្គ គឺលោកពូបានដឹងអំពីបញ្ហានេះ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើការជម្លៀសនៅឧដុង្គហ្នឹង មានផលវិបាកអីខ្លះ

ដែលកើតឡើង? ព្រោះអាចថា ប្រជាជនមានការភ័យខ្លាច ហើយពេលដែលជម្លៀសចេញទៅ អត់បានចូលមកវិញនេះ តើវាមានផលវិបាកអីខ្លះ?

**ឆ៖** គឺកន្លែងហ្នឹង គឺទៅគឺថាខ្ញុំចុះឡើងៗតាមហ្នឹង ឃើញថាជម្លៀសចេញវាផុតៗ ដូចមិនមានស្អីពិបាកផង ហើយប្រជាជនម្តុំហ្នឹង មែនទែន ជម្លៀសក៏មិនទៅណាឆ្ងាយដែរ គឺថាចុះវា ជុំវិញតំបន់ -- ជុំវិញឧដុង្គហ្នឹង គឺថាតំបន់រំដោះទៅហើយ។ បើចេញផុតពីនេះបន្តិចទៀតហ្នឹង ក៏ដូចជាអត់មានបញ្ហាស្អីផង គាត់នៅតំបន់រំដោះហ្នឹងហើយ។ នេះខ្ញុំឃើញស្តែង វាមិនឃើញមានអី ឃើញប្រជាជនក៏ដូចជានិយាយមិនមានអីផលពិបាកអីហ្នឹង ដូចមិនមានអីទេ។ ហើយស្បៀងអាហារអីហ្នឹង នៅចូលតំបន់រំដោះទៅមានអី គឺថា គឺជា គឺថាជាសមាជិករបស់គេក្នុងតំបន់រំដោះហើយ។ ដូច្នេះគេជួយ គេឧបត្ថម្ភ គេធ្វើការងារស្អីជាមួយគេជាមួយឯងអីចឹង។ ត្រូវធ្វើស្រែៗទៅ ធ្វើចម្ការៗអីសិនទៅ ដល់ឡើងត្នោតៗអីចឹងទៅ ខ្ញុំឃើញអីចឹង។ ឃើញជាក់ស្តែង នៅឧដុង្គ ខ្ញុំឃើញជាក់ស្តែង វាឃើញ ពេលជាក់ស្តែងឃើញអីចឹង។

**ស៖** បាទអរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិចអំពីការប្រជុំដែលធ្វើផែនការជម្លៀសប្រជាជនពិសេសជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះឯង។ សួរថាតើលោកពូបានដឹងទេថា ផែនការនៃការជម្លៀសគេហ្នឹង គេបានគិតគូរដល់ចំណុចគ្រោះថ្នាក់របស់ប្រជាជនដែលកាលនោះ ១៧ មេសា បានន័យថាជារដូវប្រាំង ពេលដែលប្រជាជនទៅ វាអាចប៉ះពាល់នូវជីវភាពរបស់ប្រជាជន។ តើគេមានផែនការលម្អិតយ៉ាងម៉េច តើលោកពូអាចជម្រាបអង្គជំនុំជម្រះបានទេបាទ?

[១៤:១៦:៤៣]

**ឆ៖** ចំណុចនេះ គឺថាដល់រំដោះភ្នំពេញហើយ គឺថាប្រជាជនចេញគ្រប់ទិសទាំងអស់ ពព្រោងពព្រាតហ្នឹង គឺថា -- ខ្ញុំមិនឮដំណឹងអីថាជុំវិញការជម្លៀសហ្នឹងវាមានផលលំបាក ឬមួយផល -- និយាយពីរឿងជម្លៀសយ៉ាងម៉េចៗ ខ្ញុំដូចអត់មានឮអីទេ ឃើញតែប្រជាជនចេញពព្រោងពព្រាតអីចឹង។ ខ្លះរែកអាខ្លះពន់ ខ្លះដើរអត់ស្បែកជើងអីក៏មានដែរ ឃើញៗវាមានអីចឹង។ ប៉ុន្តែថ្ងៃៗហ្នឹង គេមកខាងភ្នំពេញខាងលិចភ្នំពេញហ្នឹង ខ្ញុំៗជួបប្រជាជនទេ ជួបខ្លួនឯងទេហ្នឹង។ ខ្ញុំទៅនេះហ្នឹង ឃើញប្រជាជនគាត់រែកគាត់រែកៗតែមួយគ្រួសារហ្នឹង រែកលុយតែម្តង រែកពីរបាវ រែកបែកញើសរហាម។ ខ្ញុំថា "លោកពូ! រែកអីហ្នឹង?" គាត់មិនប៊ានប្រាប់ផង គាត់អេះអុញៗ ខ្ញុំទៅឆែកមើលឃើញលុយ។ ខ្ញុំថា "លោកពូឯងមិនបាច់ៗយករែកទេ លុយនេះ នាំតែហាត់អត់ប្រយោជន៍ទេ ទៅតំបន់រំដោះគេអត់ចាយទេ គេឈប់ចាយ

ហើយ របបៗមុនគេឈប់ចាយហើយ។ ឥឡូវទៅតំបន់រំដោះគេអត់ចាយទេ"។ លែងគាត់យំហ៎ី។ ខ្ញុំថា ធ្វើម៉េចទេលោកពូអើយ បើៗសភាពការណ៍វាវិវត្តន៍អ៊ីចឹងទៅហើយ មិនបាច់ទៅយំទេ កុំទៅសោកស្តាយវា ដូចគេដូចឯងទៅ។ ខ្ញុំប្រាប់ថាអ៊ីចឹង ដូចគេដូចឯងទៅ។ នេះខ្ញុំចង់បញ្ជាក់ថា ការដែលជម្លៀសប្រជាជននេះវាមានការលំបាកក៏ វាមានការស្រួលក៏វាមាន ប៉ុន្តែឧបសគ្គអីធំដុំចំពោះមុខហ្នឹង ដូចជាមិនឃើញមានស្អីផង។ ព្រោះទៅតំបន់រំដោះ គេៗទទួលអស់ហើយ សហករណ៍គេមានបាយហូប គេមានម្ហូបហូប គេនៅហ្នឹងគេៗថា ដូចគ្មានការទិញដូរអាហ្នឹង គឺថាគេនៅរាប់ៗសែនរាប់លានតាមជនបទ គេនៅរស់នៅបាន ហើយយើងចេញតែភ្នំពេញ១លាន ២លាន ហ្នឹងទៅតាមជនបទ រឿងអីមានរឿងអីពិបាក គឺរស់ដូចគេដូចឯងទៅ។ អាហ្នឹង គឺទស្សនៈខ្ញុំផ្ទាល់ទេណ៎ា ខ្ញុំចង់បញ្ជាក់ដែលពេលដែលខ្ញុំជួបគេអ៊ីចឹង។ ខ្ញុំថា ខ្ញុំបញ្ជាក់អ៊ីចឹងទៅ។

[១៤:១៩:១៧]

**សៈ** បាទ អ៊ីចឹងមានន័យថា នៅពេលដែលមុនៗជម្លៀសហ្នឹង បានន័យថាអត់បានជម្រាបជូនទៅប្រជាជនឲ្យបានយល់អំពីបញ្ហាជម្លៀសនេះទេ ឬមួយមានគោលដៅថាតើជម្លៀសចេញទៅហ្នឹង ជាលក្ខណៈយូរអង្វែង ឬមួយជាលក្ខណៈយ៉ាងម៉េច? ហើយជាលក្ខណៈបោសសម្អាត ឬមួយវាមានបញ្ហាអ្វីដែលថាគ្រប់គ្រងវាមិនបាន ខ្លាចខ្មាំងវាយលុក ឬមួយយ៉ាងម៉េចបានជាធ្វើផែនការជម្លៀស ហើយមិនគិតទៅដល់ផលវិបាកដ៏ធ្ងន់ធ្ងរ បាទ?

**ឆៈ** ខ្ញុំនិយាយដោយស្មោះគឺថាៗ កិច្ចការជម្រៅរបស់ថ្នាក់លើដែលបញ្ហាជម្លៀសចេញទៅទាំងអស់ហ្នឹង ខ្ញុំយល់វាមិនអស់ទេៗ។ ប៉ុន្តែខ្ញុំឃើញថា ដែលខ្ញុំឃើញជាក់ស្តែងហ្នឹង គឺជម្លៀសចេញពីភ្នំពេញហ្នឹង ដល់យើងចូលទៅវាអត់មានឃើញ វាស្ងាត់ល្អដែរ។ ស្ងាត់ល្អៗ គឺថាយើងរស់នៅហ្នឹងគឺថាយើង-- ខាងសន្តិសុខហ្នឹង គឺយើងធានា១០០ភាគរយ មិនមានស្អីកើតឡើងកើតទេ។ យើងកាន់កាប់ទាំងស្រុងហើយអាហ្នឹង អត់មានអីរញ៉េរញ៉ៃអីទៀតទេ។ វាក្រោយមកហ្នឹង ឮដែរ ទ័ពគេនិយាយ តាមមូលដ្ឋានគេនិយាយខ្លះដែរ គេថា អ្ហ៊ឺ!ប្រជាជនចេញពីភ្នំពេញទៅនឹងវេទនាណាស់ លំបាកណាស់។ អើ! គេធ្លាប់ស្រួលហើយឲ្យគេលំបាកខ្លះទៅ បើយើងលំបាករាប់រយឆ្នាំហើយ យើងធ្វើម៉េចអាហ្នឹងវាទៅជាអ៊ីចឹង។ អាហ្នឹងគេមានមតិខ្លះអ៊ីចឹងដែរ បើគិតទៅវាមាន -- គេមានមតិអ៊ីចឹងដែរ។ ហៅថាលំបាកៗលំបិនដូចតែយើងសិនទៅ។ អាហ្នឹងអ៊ីចឹង។

[១៤:២១:៣៥]

**ស៖** បាទ អរគុណ។ ចុះអ្វីដែលលោកពូបានជួបប្រទះជាក់ស្តែងនៅពេលដែលជម្លៀសភ្លាម ហើយបានចូលមកទីក្រុងភ្នំពេញ ដែលបានរៀបរាប់អម្បាញ់មិញថា អត់មានជួបការលំបាកអីទេ ហើយ តើមានការជួប ដែលពេលដែលប្រជាជនដែលចេញទៅតាមផ្លូវហ្នឹងមានបានឃើញថា ទាហានខ្មែរក្រហមគាត់បានអម ឬមួយធ្វើអំពើហិង្សា ឬមួយយ៉ាងម៉េចទៅលើប្រជាជនដែលៗគាត់ដូចថា គាត់ចេញហើយ ដូចថាភ្លេចអីអ៊ីអីវ៉ាន់នៅក្នុងផ្ទះអីចឹងគាត់ត្រូវត្រឡប់មកវិញ ហើយមកជួបខាងទាហានខាងខ្មែរក្រហមហ្នឹងមានប្រើអំពើហិង្សានៅចំពោះពេលនោះតែម្តង។ តើលោកពូបានដឹងរឿងនេះទេ? ហើយឬមួយបានជួបរឿងនេះទេ?

[១៤:២២:៤៨]

**ឆ៖** ខ្ញុំអត់បានជួប នែ៎ៗ ដូចគាត់រៀបរាប់អម្បាញ់មិញនេះ ខ្ញុំអត់បានជួបទេ។ ខ្លួនខ្ញុំផ្ទាល់អត់មានបានជួបទេ។

**ស៖** អរគុណបាទ។ ចុះចំណុចមួយទៀត ដែលខ្ញុំសូមជម្រាបសួរទៅលើលោកពូដែរថា លោកពូបានដឹងទេពីរឿងគេថា ប្រជាជនដែលជម្លៀសចេញហ្នឹងគេឲ្យប្រភេទឈ្មោះគាត់ថា ជាប្រជាជនថ្មី ប្រជាជន១៧មេសា ឬមួយជាប្រជាជនបញ្ញើ។ តើលោកពូអាចពន្យល់នូវចំណុចនេះបានទេបាទ?

[១៤:២៤:០៩]

**ឆ៖** ចំណុចនេះ គឺថាគ្រប់មូលដ្ឋាន ឧបមាថា ប្រជាជនយើងចេញពីភ្នំពេញថ្ងៃ១៧ មេសាហ្នឹងគឺទៅដល់តាមមូលដ្ឋានអីលើ។ គេថាប្រជាជនថ្មីក៏មានដែរ ពាក្យហ្នឹងគេថា គេថាទៀត គេថាប្រជាជន១៧មេសា ក៏ថាដែរ ពីព្រោះទៅដល់មូលដ្ឋានហ្នឹងគឺថា ប្រជាជនដែលនៅចាស់ហ្នឹង គេធ្វើស្ថិតិអាហ្នឹងអីចឹង ហើយប្រជាជនដែលទើបជម្លៀសពីទីក្រុងភ្នំពេញ ឬមួយជម្លៀសពីទីប្រជុំណាមួយគេធ្វើស្ថិតិឲ្យដឹងដែរ ក្នុងមូលដ្ឋានរបស់គេមួយៗ។ គថា យើងធ្វើអីចឹងបានយើងក្តាប់បានថា តើចំនួនមនុស្សដែលទៅនៅក្នុងតំបន់រំដោះយើងហ្នឹង ប្រជាជនយើងនៅមូលដ្ឋានជាអចិន្ត្រៃយ៍យូរហើយហ្នឹងមួយផ្នែក។ មួយផ្នែកប្រជាជនដែលមកពីជម្លៀសហ្នឹងវាមួយផ្នែក អាហ្នឹងទាល់ធ្វើបញ្ជីទៅបានយើងក្តាប់បានមនុស្សហ្នឹង។ ហើយក្នុងហ្នឹងយើងតាមដាន បើវាល្អ តាមហ្នឹងទៅ បើវាមិនល្អទៀត អាហ្នឹងត្រូវដោះស្រាយយ៉ាងម៉េចទៀត អាហ្នឹងស្រេចតែមូលដ្ឋាននីមួយៗទេ។

**ស៖** ចំណុចដែលសំខាន់ គឺអ្វីដែលផែនការនៃការជម្លៀសនេះ សួរថាតើពេលដែលដាក់ផែនការនៃការជម្លៀសនេះចេញ ជម្លៀសប្រជាជនដែលចេញពីទីក្រុងភ្នំពេញហ្នឹង តើមានផែនការថាផ្តល់ឲ្យ

ខាងមូលដ្ឋានហ្នឹងគាត់ត្រូវធ្វើយ៉ាងម៉េចចំពោះបងប្អូនដែលត្រូវជម្លៀសហ្នឹងចេញទៅទេ?

[១៤:២៦:១៣]

**ឆះ** ដូចខ្ញុំបានបញ្ជាក់ជាបន្តបន្ទាប់ហើយថា គេថាចំពោះប្រជាជនដែរថា ជម្លៀសពីទីក្រុងហ្នឹងចូលសហករណ៍ហ្នឹង គឺគេមានតើ គេមានទទួលតើ គេទទួលតើ កន្លងមកគេទទួលហូរហែអ៊ីចឹងដែរហើយធ្វើការងារជាមួយគ្នាហ្នឹង។ កន្លែងខ្លះឃើញចាត់ចែងបងប្អូនដែលមកពីទីក្រុងភ្នំពេញ កន្លែងខ្លះទៅចាត់ចែងល្អ សហករណ៍ខ្លះគេចាត់ចែងល្អ ប៉ុន្តែសហករណ៍ខ្លះចាត់ចែងមិនសូវបានល្អដែរ។ យើងមើលទៅដូចជា កន្លែងខ្លះយើងមើលទៅ មានខ្លះដូចជាគំនុំ ចារបៀបគំនុំបុគ្គល ឬមួយគំនុំហ្នឹង គឺថាខ្ញុំចង់និយាយហ្នឹង ព្រោះខ្ញុំជួបប្រទះខ្លះដែរ ដែលអ្នកទៅហ្នឹង។ ជីកប្រឡាយ លើកទំនប់ ហើយបបរលាយជាមួយត្រកួន។ អាហ្នឹងបានខ្ញុំដឹង។ ខ្ញុំចង់និយាយថា ខ្ញុំឃើញជាក់ស្តែងវាឃើញអ៊ីចឹង។ មូលដ្ឋានអ៊ីចឹងហ្នឹង អត់ល្អទេ។ ខ្ញុំផ្ទាល់ ខ្ញុំក៏បានទិតៀនខ្លះដែរ កាលខ្ញុំមកពីពាយ័ព្យហ្នឹង កាលហ្នឹង រស់ ញឹម គាត់ធ្វើមេភូមិភាគហ្នឹង។

កាលហ្នឹងខ្ញុំទៅ ខ្ញុំថាយី! បើតាមឯកសារ បើប្រជាជនហូបបបរ បើប្រជាជនហូបបបរជាមួយត្រកួន។ បានន័យថាកម្មាភិបាលហ្នឹងគ្មានកើតជាការទេ ខ្ញុំនិយាយអ៊ីចឹង ហើយ រស់ ញឹម សើចជាមួយខ្ញុំ ហេះហេៗ ខ្ញុំថាខ្ញុំមិនបានហេះហេជាមួយទេ។ ខ្ញុំថា មើល៍! យើងតស៊ូដើម្បីឲ្យស្មើភាពគ្នា ឥឡូវម៉េចក៏អ្នកខ្លះហូបបបរ ហើយលាយជាមួយត្រកួន។ ខ្ញុំប្រឆាំងភ្លាម។ ខ្ញុំប្រឆាំងតើ ជាបុគ្គលខ្ញុំប្រឆាំងតើ។ ខ្ញុំទៅរាយការណ៍ទៅខាងលើៗ ខ្ញុំថា ការងារគេ គេដឹង ការងារយើង យើងដឹង។ ថាអ៊ីចឹងៗ ខ្ញុំក៏បាត់មាត់ទៅ។ ប៉ុន្តែខ្ញុំមិនសូវខ្លាចទេ បើថាស្អីដែលខុសហ្នឹងបានខ្ញុំថា តែម្តងផ្ទូងៗអ៊ីចឹង។ កំពូលណាៗក៏ដោយ កាលនុ៎ង បើខុសខ្ញុំថាមែន ខ្ញុំអត់មានក្រែងរអែងទេ ព្រោះខ្ញុំឃើញថា យើងធ្វើបដិវត្តន៍ឲ្យនាំភាពស្មើៗគ្នា ដល់ឃើញអ្នកខ្លះដូចជាវេទនា ឃើញកោរសក់ត្រងិលត្រងោលអ៊ីចឹងទៅ។ហូបបបរអ៊ីចឹងមានទៅល្អមើលអីអាហ្នឹងនោះ វាអាក្រក់មើលណាស់ ហើយគ្មានមនុស្សដូចតែគ្នា។ ខ្ញុំបានតវ៉ាច្រើនណាស់ អ៊ីចឹងៗ ខ្ញុំដើរតាមភាគ ខ្ញុំឃើញ ខ្ញុំថាតើ។

[១៤:២៨:៥០]

**សះ** អរគុណលោកពូច្រើនមែនទែននូវចំណុចនេះ។ ខ្ញុំជម្រាបសួរថា តើនៅពេលដែលលោកពូចុះទៅហ្នឹង តើចុះនៅក្នុងអំឡុងឆ្នាំណាដែរ? ហើយពេលដែលចុះទៅឃើញសភាពការណ៍អ៊ីចឹងមានរាយការណ៍មកថ្នាក់លើឲ្យចាត់វិធានការយ៉ាងម៉េចទេបាទ?

**ឆ៖** ខ្ញុំចុះទៅញឹកញាប់ចាប់ពី -- និយាយរួមចាប់ពី៧៧ មក ហើយដល់៧៨ ខ្ញុំដើរច្រើន។ ខ្ញុំដើរច្រើន នៅតាមជនបទ សឹងតែគ្រប់ៗខេត្តឯណោះ ខ្ញុំដើរនោះ។ គ្រប់ខេត្ត។ ហើយឃើញ ដូចខ្ញុំថា អំមិញហ្នឹង ឃើញទៅ រាយការណ៍ទៅខាងលើទៅ តែខាងលើយកទៅពិចារណាក៏យកទៅ បើមិនយក ខ្ញុំថា ខ្ញុំៗបានឃើញ ព្រោះណែនាំខ្ញុំឲ្យខ្ញុំស្មោះត្រង់ បើឃើញអីរាយការណ៍។ ឥឡូវរាយការណ៍ បើវាខុស វាមិនដឹងធ្វើម៉េច។ ខ្ញុំថា បើខ្ញុំរាយការណ៍ បើខ្ញុំឃើញមែន ឃើញតែមនុស្សមិនល្អ កន្លែងដែលមិនល្អ។ ខ្ញុំថាឲ្យកម្មាភិបាលកន្លែងហ្នឹងផង ខ្ញុំថា ថ្នាក់តំបន់ក៏ដោយ ថ្នាក់ភូមិភាគក៏ដោយ ខ្ញុំថាឲ្យទៅ។ ខ្ញុំថា អ៊ីចឹង។ ថា រិះនឹងបាត់ខ្លួនឯងទៀត អាចុងក្រោយនេះ បើគិតទៅ ដោយសារតែខ្ញុំមាត់ឆៅ។ រិះនឹងបាត់ខ្លួនឯងទៀត ប៉ុន្តែនឹកឃើញទឹកដោះម្ដាយថ្លៃដែរ បានរស់រានមានជីវិតដល់ថ្ងៃនេះ។

[១៤:៣០:៤៤]

**ស៖** តើលោកពូ ពេលដែលចុះទៅជួបសភាពការណ៍អ៊ីចឹងហើយ មកខាងលើវិញ រាយការណ៍ជូនបងទី១ ប៉ុល ពត ឬមួយរាយការណ៍ជូនអ្នកណាដែរ?

**ឆ៖** ខ្ញុំភាគច្រើន ខ្ញុំឃើញហ្នឹង គឺថាព្រោះខ្ញុំជាអចិន្ត្រៃយ៍ អ្នកលើខ្ញុំនេះ នៅក្រសួងខ្ញុំនេះ មានតែ អ៊ំ អៀង សារី ទេ និយាយជាមួយគាត់។ ភាគច្រើនខ្ញុំនិយាយជាមួយគាត់ទេ។ អ៊ំ ប៉ុល ពត បើថាគាត់ហៅឲ្យខ្ញុំទៅជួបគាត់ បើគាត់សួរពីរឿងហ្នឹង ខ្ញុំប្រាប់គាត់ដែរ។ ប្រាប់គាត់ គាត់ថា គាត់ថាម៉េច គាត់ថា "ចាំស្វ័យទិតៀនទៅ ១!" គាត់ថាអ៊ីចឹង។ ស្វ័យទិតៀន គាត់ចង់និយាយថា ដូចខ្ញុំរាយការណ៍ឲ្យអ៊ំ អៀង សារី ៗគាត់ថា "កុំមើលគេ មើលការងារខ្លួនឯងហ្នឹងទៅ"។ គាត់ច្រើនតែប្រាប់ខ្ញុំអ៊ីចឹង។ ហើយបើខ្ញុំទៅជួបអ៊ំទី១ហ្នឹង ខ្ញុំនិយាយទៅ គាត់ថា "ចាំស្វ័យទិតៀន" គាត់ឆ្លើយអ៊ីចឹង។ មិនដឹងគាត់ឆ្លើយមែន ឬឆ្លើយលេង មិនដឹងគាត់មានវិធានការយ៉ាងម៉េច ខ្ញុំមិនដឹងដែរ។ ប៉ុន្តែទៅជួបគាត់ ឆ្លើយឆ្លងគេរបៀបអ៊ីចឹងទៅ។

**ស៖** អម្បាញ់មិញពូថា បានមករាយការណ៍ជូនលោក អៀង សារី។ ចុះពេលដែលរាយការណ៍ជូនលោក អៀង សារី ហើយ សួរថាតើមានវិធានការអីជាក់ស្ដែងនេះទៅខាងតំបន់ភូមិភាគរបស់យើងហ្នឹង ហើយតើពួកគាត់មានបានប្រជុំគ្នាដោះស្រាយពីបញ្ហាហ្នឹងទេ?

[១៤:៣៣:២៧]

**ឆ៖** គឺគាត់អត់បានដោះស្រាយក្នុងរឿងហ្នឹងទេ អត់ដោះស្រាយទេ។ មិនដឹងជាគាត់ប្រជុំក្នុងអចិន្ត្រៃយ៍របស់គាត់ មិនដឹងគាត់លើកឡើងយ៉ាងម៉េចៗ ខ្ញុំក៏មិនដឹងដែរ។ មិនដឹងវិធានការបែបម៉េច

ប៉ុន្តែខ្ញុំឃើញ ខ្ញុំរាយការណ៍ជូនគាត់។ ជូនគាត់អ៊ីចឹង។ គាត់ថា រយៈពេលដែលយើង -- គាត់ចេះតែមានមតិថា រយៈពេលដែលយើងត្រូវឆ្លងកាត់ ៗហ្នឹង។ ដល់គាត់ពន្យល់ថា រយៈពេលឆ្លងកាត់ហ្នឹង ខ្ញុំក៏ដូចជារំងាប់ចិត្តដែរ ដូចវាលែងឈឺចាប់ដែរ ឃើញអ៊ីចឹងៗ។

**សៈ** បាទ អរគុណ។ នៅថ្ងៃ២៦ កក្កដា កន្លងទៅនេះ គឺនៅម៉ោង១៤ និង ៣៣នាទី លោកពូបាននិយាយថា "មានការប្រជុំមួយនៅវិហារព្រះកែវមរកត លើកពីទិសដៅមួយនៅក្នុងចំណោមទិសដៅជាច្រើន គឺការកសាងសហករណ៍ឲ្យជឿនលឿន"។ ខ្ញុំចង់ជម្រាបសួរថា តើការកសាងសហករណ៍ឲ្យជឿនលឿនហ្នឹងវាយ៉ាងម៉េច? ព្រោះពេលដែលប្រជុំហ្នឹង គឺថាមានការលើកឡើងអ៊ីចឹង។ តើលោកពូអាចជម្រាបបានទេបាទ?

[១៤:៣៥:២០]

**ផះ** សហករណ៍ជឿនលឿននោះគឺថា ក្រោយពីយើងឈ្នះ ១៧ មេសា ៧៥ ហើយ ហើយក្នុងការប្រជុំហ្នឹងគឺលើកឡើងអំពីការនែ ព្រោះថា សហករណ៍ជឿនលឿននេះវាមាននៅមូលដ្ឋានស្ទើរតែគ្រប់មូលដ្ឋានទាំងអស់ គឺថាត្រូវពង្រឹង ហើយនិងពង្រីក។ ពង្រឹងសហករណ៍នោះឲ្យវាធ្វើម៉េច គឺថាគ្រប់គ្រងក្នុងកម្លាំងសហករណ៍នេះ យើងឃើញ គឺថា ដូចហៅថា យើងធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យវាចប់ហើយ។ ដល់យើងធ្វើបដិវត្តន៍សង្គមនិយម ដើម្បីឈានទៅកុម្មុយនីស្តនិយម គឺថាយកសហករណ៍ហ្នឹងជាៗគោលដៅមួយសម្រាប់ពង្រឹងតទៅទៀត ពង្រឹងទៀត។ ខ្ញុំយល់ន័យវាល្អិតល្អន់ ខ្ញុំយល់វាមិនអស់ទេ ប៉ុន្តែខ្ញុំ តាមឆ្លងកាត់មកគឺថា គឺតាមជនបទហ្នឹង គឺយកសហករណ៍ជឿនលឿនហើយដែលត្រូវពង្រឹងៗ បើពង្រឹងអាហ្នឹងល្អហើយ វាអ្វីៗវាល្អទាំងអស់ វារីកចម្រើនទាំងអស់ ទាំងផ្នែកការពារប្រទេស ទាំងផ្នែកកសាងប្រទេសហ្នឹង វានៅក្នុងសហករណ៍ហ្នឹងហើយ ដែលគោលដៅធំហ្នឹង គឺសហករណ៍ហ្នឹងហើយ។

[១៤:៣៦:៥២]

**សៈ** បាទ ប៉ុន្តែចំណុចសំខាន់ថា អ្វីដែលយើងថា សហករណ៍ជឿនលឿនហ្នឹង តើសហករណ៍ជឿនលឿនហ្នឹង គេធ្វើយ៉ាងម៉េច ដូចថា ធនធានមនុស្ស ឬមួយធ្វើឲ្យមនុស្សនៅក្នុងសហគមន៍ហ្នឹងចូលរួមគ្នាទាំងអស់ ឬមួយយ៉ាងម៉េចដែលធ្វើឲ្យសហករណ៍ហ្នឹងជឿនលឿនទៅកើត?

**ផះ** ដើម្បីឲ្យសហករណ៍នេះជឿនលឿនគឺថា មែនទែននិយាយទៅគឺថា ធ្វើបដិវត្តន៍សង្គមនិយមបើធ្វើបដិវត្តសង្គមនិយមនេះគឺថា បើថាហូបបាយសហករណ៍ហ្នឹង ហូបបាយរួមគឺថា ហូបបាយ

រួម បើម្ហូបពីរមុខគឺ ពីរមុខស្មើគ្នាទៅ បើថាបីមុខ បីមុខស្មើគ្នាអ៊ីចឹង ចង់ថាអ៊ីចឹង គឺថាគឺឆ្ងាញ់ ឆ្ងាញ់ទាំងអស់គ្នា បើមិនឆ្ងាយ់ មិនឆ្ងាញ់ទាំងអស់គ្នា។ គឺន័យមែនទែនគឺថា កសាងទស្សនៈគោលជំហរនែ៎ ព្រោះយើងបានឆ្លងកាត់ធ្វើបដិវត្តន៍រួចមួយសាមកហើយ ឥឡូវយើងឈានទៅធ្វើបដិវត្តន៍សង្គមនិយម ដើម្បីឈានទៅកុម្មុយនីស្តនិយម។ គឺន័យគឺថា ន័យថាប្រយុទ្ធផ្ទៃក្នុង ក្នុងសហករណ៍ហ្នឹងខ្លាំងដែរ រវាងដែលគេហៅថា រួមនិងបុគ្គលហ្នឹង វាប្រយុទ្ធគ្នាខ្លាំងដែរ មិនមែនធម្មតាទេ។ បើលះបង់ពីផ្ទះធំមកផ្ទះតូច បើផ្ទះតូច បើសង់ បើសង់ផ្ទះតូចស្មើគ្នាអ៊ីចឹងទៅ ដល់ហូបចុកក៏វាស្មើគ្នាអ៊ីចឹងទៅ ស្លៀកពាក់ឲ្យវាស្មើគ្នាអ៊ីចឹងទៅ។ ហ្នឹងទស្សនៈឲ្យវាទៅតាម ចង់បានអ៊ីចឹងដែលជឿនលឿននោះ បើថានៅតែទស្សនៈចាស់គម្រិលដដែលហ្នឹង ដូចសង្គមចាស់ហ្នឹងម៉េចកើត ពាក្យថា ធ្វើបដិវត្តន៍។ ឥឡូវពាក្យបដិវត្តន៍វាចប់ហើយ ឈានទៅធ្វើបដិវត្តន៍សង្គមនិយម វាកាន់តែ អប់រំផ្ទៃក្នុងវាកាន់តែស្ទិតស្វាញ យល់ដឹងកាន់តែជ្រៅជ្រះ យល់អំពីការកសាងប្រទេសផង យល់អំពីការការពារប្រទេសផង ហើយយល់ពីការឧបសគ្គ ដែលយើងត្រូវខ្លួនទីពឹងខ្លួន ខ្លួនឧបត្ថម្ភខ្លួនេះ ជុំវិញការងារហ្នឹងវាច្រើន ត្រូវឆ្លងកាត់វាច្រើនដំណាក់ដែរ ស្មុគស្មាញដែរ មិនមែនស្រួលទេ។ នេះគឺថា មានតែយកសហករណ៍ហ្នឹងហើយជាមូលដ្ឋាន ប៉ុន្តែជ្រៅជ្រះអីផ្សេងទៀត ខ្ញុំចាំវាមិនអស់ទេ។ ខ្ញុំសរុបដែលខ្ញុំឃើញជាក់ស្តែង ឃើញដើរតាមជនបទ និងដែលលើកឡើងក្នុងអង្គប្រជុំនោះ ឃើញថា វាចេះតែទិសដែលរីកចម្រើន។

[១៤:៣៩:៥១]

**ស៖** ពាក់ព័ន្ធនឹងសហករណ៍នេះដែរ ដោយសារថា កាលណាសហករណ៍លោកពូបានលើកឡើងអម្បាញ់មិញ បានន័យថា វាត្រូវតែហូបរួម។ តើគោលនយោបាយហូបរួមហ្នឹង វាកើតពីពេលណាមកបាទ? :

**ឆ៖** ហូបបាយរួមហ្នឹង មែនទែនវាកើតមុនរំដោះភ្នំពេញទៀត គិតទៅ គឺថា១៨ មីនា ៧០ រដ្ឋប្រហារ១។ ដល់ដើរដល់ពីកន្ទុយនាគមកដល់ក្រោមមក ក្នុងឆ្នាំ ឃើញក្នុងឆ្នាំ៧៣ ឃើញបណ្តើរ១ក្នុងតំបន់រំដោះ។ ហ្នឹងគឺឃើញចាប់ពី៧៣ ទៅ។ ដល់៧៤ កាន់តែឃើញពន្លឺ ឃើញពន្លឺ ឃើញកន្លែងខ្លះគេហូបបាយ គេថាស្រួល ហូបបាយរួមស្រួល។ ប៉ុន្តែមិនទាន់ទូទៅទេ ដោយកន្លែងទេ ឃើញអ៊ីចឹង។ ដល់រំដោះហើយបានចេញ ដូចខ្ញុំថាអំមិញ គឺថាចេញពីសហករណ៍ជឿនលឿន វាទៅជាអ៊ីចឹងទៅអ៊ីចឹង។ អានេះខ្ញុំឃើញជាក់ស្តែង ខ្ញុំឃើញឆ្លងកាត់វាឃើញបញ្ហាអ៊ីចឹង។

[១៤:៤១:៣៩]

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទ សូមជម្រាបសួរសាជាថ្មី ដោយសារពេលវេលាវាមានខ្លី ហើយសូមលោកពូឆ្លើយអ្វីដែលសង្ខេប ហើយច្បាស់បាទ។ ដោយសារអម្បាញ់មិញ ខ្ញុំបានលើកឡើងអំពីការពាក់ព័ន្ធនឹងសហករណ៍នេះ ថាតើនៅពេលដែលប្រជុំនៅវិហារព្រះកែវនោះ តើមានការពិភាក្សាអំពីការចល័តមនុស្សពីកន្លែងមួយទៅកន្លែងមួយ ហើយដើម្បីឲ្យចូលទៅក្នុងសហករណ៍ជឿនលឿនហ្នឹងដែរអត់បាទ?

**លោក វ៉ាចាម តុន៖**

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយថា ប្រជុំនៅវិហារព្រះកែវហ្នឹង គេ -- ខ្ញុំដឹងថា គឺថាលើកៗវិធានការ

គេថា ធ្វើបដិវត្តន៍សង្គមនិយម ដើម្បីឈានទៅកុម្មុយនីស្តនិយម។ ហើយបញ្ហាសហករណ៍ហ្នឹង ក៏នៅក្នុងរឿងនុំងដែរ ក្នុងនុំងដែរ ក៏មានការពិភាក្សាខ្លះដែរ។ ប្រធានបទហ្នឹង គឺថាយើងចប់ហើយ ដូច្នេះយើងត្រូវធ្វើការតទៅទៀត នៅជនបទហ្នឹង គឺយកសហករណ៍ហ្នឹងជាធំ ជានាំមុខជាងគេ ជាធំ គឺ ខ្ញុំមិនដឹងជាឆ្លើយថាម៉េចទៀតទេ បើតាមខ្ញុំដឹង គឺថាដូចថាមានតែពង្រឹងសហករណ៍ជឿនលឿននេះ ឲ្យបានហៅថាឲ្យបានទូទាំងប្រទេស។ ព្រោះកន្លងមក វាទើបតែមានៗ គេទើបមានដោយៗភូមិភាគ ដោយកន្លែងទេ វាមិនទាន់ទូទៅទេ។ ដូច្នេះវិធានការ គឺថាដល់នៅជនបទ គឺថាត្រូវពង្រឹងសហករណ៍នេះ ដើម្បីឲ្យកាន់តែកម្លាំងៗឯកភាពផ្ទៃក្នុងនេះ វាកាន់ខ្លាំងក្លា វាកាន់តែរីកចម្រើនថែមទៀតហ្នឹង។

[១៥:០៧:៤៩]

**ស៖** បាទ សូមអរគុណបាទ។ នៅបន្ទាប់ពីជ័យជម្នះ ១៧ មេសា ១៩៧៥ មក គឺថាតើបក្សហ្នឹង មានការបង្កើតឲ្យមានលុយ របស់កម្ពុជាប្រជាធិបតេយ្យសម្រាប់ចាយវាយហ្នឹងដែរអត់ទេបាទ?

**ឆ៖** បញ្ហាលុយ មែនទែនទៅ គឺថា រំដោះ ១៧ មេសា ៧៥ ហើយ វាត្រូវតែចាយលុយ ហើយលុយបានបោះ បោះតាំងពី លុយមកដល់ៗនេ៎ះ តំបន់រំដោះតាំងពីចុងឆ្នាំ៧៤ម៉្លេះ។ មានតើលុយហ្នឹង បោះហើយស្រេច។ ហើយលុយហ្នឹង គឺតម្កល់ទុកជិត គេហៅជិតវត្តភ្នំហ្នឹង កាលបីឆ្នាំ ទុកនៅនុំងឯង មួយឃ្លាំងប៊ឹបនៅហ្នឹង ពេញប៊ឹប។ តែមិនទាន់ចាយទេ អត់ចាយទេ បីឆ្នាំហ្នឹង អត់បានចាយទេ លុយហ្នឹង។ គឺបោះៗហើយ ត្រៀមចាយលុយ គឺត្រៀមហើយ ប៉ុន្តែមិនទាន់ដល់ពេលត្រូវចាយ។

**ស៖** បាទ អរគុណ។ តើមូលហេតុនៃការមិនចាយហ្នឹង តើមានការប្រជុំសម្រេច ចេញជាសេចក្តីសម្រេចណាមួយទេ ថាយើងអត់ចាយលុយទេ នៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹងបាទ?

**ឆ៖** ដូចខ្ញុំបញ្ជាក់អំមិញហ្នឹងហើយ គឺថាបោះហើយ មានហើយលុយហ្នឹង ប៉ុន្តែរយៈហ្នឹង គេអត់ទាន់ចាយ។ ត្រូវចាយដែរ លុយហ្នឹង ប៉ុន្តែវាមិនទាន់ដល់ពេលដែលត្រូវចាយ អ៊ីចឹង។

[១៥:០៩:៥៨]

**ស៖** វាពាក់ព័ន្ធនឹងរឿងហ្នឹងដែរ ប៉ុន្តែចង់លើឡើងថាមានសេចក្តីសម្រេច ពាក់ព័ន្ធថាមិនចាយលុយ មិនមានទីផ្សារ មិនមានកម្មសិទ្ធិឯកជន។ តើរឿងហ្នឹងមានដែរអត់?

**ឆ៖** មានគោលដៅ គេថាមិនទាន់ចាយទេ មិនទាន់មាន -- មិនទាន់បើកផ្សារ ក៏មិនទាន់ចាយលុយ វាមិនទាន់ដល់ពេលវាហ្នឹង។ គេអត់ទាន់ចាយទេ។ ខាងលើសម្រេចថាអត់ទាន់ចាយទេ។ ផ្សារក៏មិនទាន់បើក លុយក៏មិនទាន់ចាយ។ មានហើយលុយ តែអត់ទាន់ចាយអ៊ីចឹង។ ខ្ញុំមិនដឹងបញ្ជាក់ម៉េច

ទៀតទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង ខ្ចីប៉ុណ្ណឹងទេ អត់មានអីវែងឆ្ងាយទៀតទេ។

**ស៖** បាទ តើសេចក្ដីសម្រេចហ្នឹង មានសម្រេចហើយ ហើយគេមានផ្សព្វផ្សាយដែរអត់?

**ឆ៖** អត់ផ្សព្វផ្សាយទេ ប៉ុន្តែគ្រាន់តែដឹងក្របខ័ណ្ឌចង្អៀតថា លុយហ្នឹងបោះហើយ ក្របខ័ណ្ឌចង្អៀតទេ។ ហើយដែលថាមិនទាន់ចាយហ្នឹង ក៏មិនផ្សព្វផ្សាយទូលំទូលាយអីទេ គេថាមានណាទៅ ធឿងឆ្ងល់អារឿងចាយលុយ មិនចាយលុយផង។ ជំនាន់ហ្នឹង គេថាកម្ចាត់កម្មសិទ្ធិឯកជនហ្នឹង កម្ចាត់បុគ្គលនិយមអីហ្នឹង កម្ចាត់គេហៅថាសតិអារម្មណ៍ណាមិន -- គេហៅថាពុករលួយហ្នឹង វាកម្ចាត់អស់ហើយ។ ម៉េចនឹកឃើញអារឿងកម្មសិទ្ធិឯកជនទៀត ស្អីៗវារួមទាំងអស់ហើយ។ ដល់អីចឹងអត់នឹកឃើញទេ។ លុយក៏មិននឹកឃើញ មាសគរទាំងដីកៗ មិនទាំងរវល់ផង។ ចាក់ចោលឲ្យអស់ទៅ។

[១៥:១១:៥៧]

**ស៖** បាទ អរគុណ។ ចំណុចមួយទៀតដែលខ្ញុំសូមជម្រាបសួរ។ លោកបាននិយាយអំពីលោក ខៀវ សំផន ថាបានប្រាប់លោកអំពីទំនាក់ទំនងភូមិភាគរួចហើយ ហើយលោកអាចនាំភ្ញៀវទៅបាន។ នេះការរៀបចំហើយ និងដំណើរការទៅ។ សួរថាតើអ្វីដែលលោក ខៀវ សំផន បានប្រាប់មកលោកហ្នឹង ថាតើដឹងថាតួនាទីលោក ខៀវ សំផន ជំនាន់ហ្នឹង គឺតួនាទីគាត់ថ្នាក់ណាដែរ? ហើយការសម្រេចហ្នឹង យ៉ាងម៉េចដែរបាទ?

**ឆ៖** ខ្ញុំដឹងគាត់តាំងពីស -- ហៅថាឆ្នាំ៧១ ឯណោះ។ គាត់ជាបញ្ញាជនមួយដែលចេះដឹងច្បាស់ណាស់ ហើយគាត់ ក្រោយពីគាត់បាន -- អត់មាន ខឿន ណ៎ា។ មុន ខឿន, ប៉ង់។ អត់ឃើញ ប៉ង់ ចេញមក ខឿន។ អត់ឃើញ ខឿន ស្រាប់តែគាត់ហ្នឹង។ អាហ្នឹងគ្រាន់តែគេដឹងៗជាស្វ័យប្រវត្តិតែម្ដង អាហ្នឹង គឺថាបើថាបើខាងលើប្រាប់តែមួយម៉ាត់ថា បើអត់មាន ខឿន ទេ គាត់ គឺគាត់ហ្នឹងហើយទទួលខុសត្រូវកន្លែងមន្ទីរ៨៧០ ហ្នឹង។ ហើយនិងរៀបចំទៅទទួលភ្ញៀវហ្នឹង ឧបមាថាទស្សនកិច្ចនៅភូមិភាគបូព៌ា គាត់បានទំនាក់ទំនងគេខាងភូមិភាគបូព៌ាហ្នឹងហើយ គឺថាយើងទៅបានហើយ មានអី គឺទៅហើយ។ យើងអ្នកជូនភ្ញៀវចេះតែជូនទៅ។ គឺមានប៉ុណ្ណឹងទេ។ អត់មានអីទៀតទេ ខាងខ្ញុំគឺថា បើថាឆ្លងកាត់តាមរយៈហ្នឹងហើយ គឺបានន័យថាទាំងសន្តិសុខហ្នឹង គឺពិសេសគឺបារម្ភជាងគេអារឿងសន្តិសុខហ្នឹង ឯង រឿងធំជាងគេបង្អស់ ក្នុងការទទួលភ្ញៀវម្ដងៗហ្នឹង។

[១៥:១៤:១៤]

បើខ្លះៗរឿងផ្សេង វាមិនសូវមានស្អីទេ សំខាន់អារឿងសន្តិសុខហ្នឹង។ យកអាសន្តិសុខហ្នឹង

ជាទីមួយ។ សន្តិសុខពីក្រៅវាមិនមាន ខ្លាចតែសន្តិសុខក្នុងផ្ទៃក្នុងហ្នឹង ព្រោះក្រោយពីរំដោះទៅ គឺថាការដណ្តើមអំណាចគ្នា ការនេះ វាមានបញ្ហាណាស់ភូមិភាគមួយៗ។ ចង់ធ្វើស្តេចត្រាញ់ ដែរហ្នឹង។ ត្រង់ណោះ គឺថាធ្វើអីទាល់តែ៨៧០ ទទួលខុសត្រូវបានខាងៗក្រសួងការបរទេសបានប៉ាន់ទៅ។ បើថា៨៧០ ថាអេកុំទៅកន្លែងហ្នឹង ក៏មិនប៉ាន់ទៅដែរ អាហ្នឹងអីចឹង។ ជុំវិញការងារទទួលភ្ញៀវ គឺរឿងអីចឹងទេ។ មិនមានរឿងអីធំដុំទេ គឺរឿងទាក់ទងអីចឹង គឺថាបើខាងណោះគេទទួលស្គាល់ថា ទៅបានហើយ គាត់ប្រាប់ថាទៅមានអី ទាក់ទងតែប៉ុណ្ណឹង។

[១៥:១៥:១៣]

**ស៖** បាទ អរគុណ។ ចំណុច ខ្ញុំចង់ដឹងអីចេះថា តើលោក ខៀវ សំផន តួនាទីគាត់នៅ៨៧០ ហ្នឹង យ៉ាងម៉េចដែរតួនាទីគាត់បាទ?

**ឆ៖** ចុង៧៨ហ្នឹង គឺតាមខ្ញុំស្មានទេ ខ្ញុំស្មានប្រហែលជាត្រូវដែរ។ អ៊ំ អៀង សារី ប្រាប់ខ្ញុំថាក្នុងៗមជ្ឈិមឥឡូវក៏មានការស្មុគស្មាញច្រើនដែរ។ ឥឡូវនៅគ្នាប៉ុន្មាននាក់ទេនៅភ្នំពេញ មានតែសាមគ្គីឯកភាពគ្នា។ នេះតួគាត់ -- តួនាទីគាត់ពេលហ្នឹងគឺនៅក្នុងអចិន្ត្រៃយ៍របស់មជ្ឈិមដែរ។ គាត់នៅនុំងដូចគ្នាបានខាងលើប្រគល់ឲ្យគាត់ទទួលជំនួស ឌឿន ហ្នឹងគឺមានតែខ្ញុំយល់ថាគាត់នៅក្នុងសមាជិកអចិន្ត្រៃយ៍ហ្នឹងឯង ជាអចិន្ត្រៃយ៍នៅទទួលភ្ញៀវផង ហើយមើលការងាររដ្ឋបាល ហើយនិងទទួលភ្ញៀវផង គាត់គណៈប្រធានរដ្ឋ ទទួលភ្ញៀវផង ហើយគាត់ចាត់ចែងការងារជាក់ស្តែងអីចឹងផង ព្រោះវាមិនទាន់រកមនុស្សបាន វាអីចឹង។

[១៥:១៦:៤០]

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ដែលខ្ញុំសូមជម្រាបសួរដែរថា តើនៅប-១ នេះធ្លាប់មានទំនាក់ទំនងលើបញ្ហាអ្វីខ្លះ ដែលជាមួយលោក ខៀវ សំផន ដែរ?

**ឆ៖** ប-១ គឺថាទំនាក់ទំនងដែលថាទំនាក់ទំនងមន្ទីរ៨៧០ គឺទាក់ទងទាំងអស់ ព្រោះ៨៧០ គ្រប់គ្រងទូទាំងប្រទេស។ ដូច្នេះ ប-១ ថាក្រសួង ប-១ ហ្នឹង ហើយនិងៗបុគ្គលិកប៉ុន្មានហ្នឹងទេ ដូច្នេះគឺថាត្រូវការដឹងអីៗ បញ្ហារាក់ជ្រៅនេះ គឺចថាទៅ ៨៧០ ហ្នឹងហើយដែលដឹង ដឹងកិច្ចការរួមទាំងអស់មួយទូទាំងប្រទេសហ្នឹង។ មានទៅកន្លែងហ្នឹងហើយ។ កន្លែងហ្នឹងចាត់ចែងការងារជាក់ស្តែងផង គេហៅថាការងារនយោបាយផង តម្រែតម្រង់ ឬគោលនយោបាយផ្សេងៗហ្នឹង ក៏នៅក្នុងមន្ទីរ៨៧០ ទាំងអស់ហ្នឹង ហើយក្នុងគណៈអចិន្ត្រៃយ៍ហ្នឹង។

**ស៖** បាទ អរគុណ។ អម្បាញ់មិញ លោកពូបានលើកឡើងថា វាមានការលំបាកណាស់ ការគ្រប់គ្រងមាន -- នៅខេត្តមួយៗចួនកាលគេចង់ធ្វើជាស្តេចត្រាញ់អ៊ីចឹង។ អ៊ីចឹង ខ្ញុំចង់ជម្រាបថា លោកពូបានដឹងថាភូមិភាគមួយចំនួនដែលបានបាត់ខ្លួនដូចជាលោក សោ ភឹម បានបាត់ខ្លួនមូលហេតុអី? លោកពូដឹងដែរទេ?

[១៥:១៨:៣២]

**ឆ៖** ខ្ញុំមិនដឹងៗវាក់ជ្រៅម៉េចទេ ប៉ុន្តែការដែលវាឃើញបញ្ហាខាងសន្តិសុខនេះឃើញថាវាមិនស្រួល។ ៧៧ យ៉ាងម៉េច មុនហ្នឹង៧៧យ៉ាងម៉េច នៅបូព៌ាហ្នឹង? វាមានបញ្ហាអ៊ីចឹង។ ដល់ក្រោយទៀតវាបាត់ខ្លួនៗអ៊ីចឹង។ អ៊ីចឹង បានថា វាមាន -- ដូចខ្ញុំថាអំមិញ វាមានកន្លែងភូមិភាគខ្លះហ្នឹង វាមិនមែនតែឯកភាពជាមួយ ប៉ុល ពត ទាំងស្រុងទេ។ វាចង់បែកគំនិតទៅផ្សេងដែរបានវាទៅជាអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ ចុះលោក កុយ ធួន ម៉េចដែរបាទ?

**ឆ៖** លោក កុយ ធួន គឺថារំដោះភ្នំពេញហើយ គាត់ហ្នឹងទៅកាន់ក្រសួងពាណិជ្ជកម្មក្រៅប្រទេស ហើយក្រោយមកទៀតក៏បាត់ខ្លួនទៅ មិនដឹងម៉េចដែរអ៊ីចឹង។ បាត់ខ្លួនទៅ។

**លោក ឡៅ ជុនធី៖**

បាទ អរគុណច្រើន ហើយខ្ញុំអស់សំណួរប៉ុណ្ណេះ ហើយសូមផ្ទេរសំណួរនេះទៅខាងសហមេធាវីអន្តរជាតិ។ បាទ លោកប្រធានអរគុណ។

[១៥:២០:២០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងបញ្ចប់ថ្ងៃនេះ ដោយសួរសំណួរមួយចំនួន។ លោកបានឆ្លើយបញ្ជាក់ជាច្រើនរួចមកហើយ។ លោកបានឆ្លើយតបទៅនឹងសំណួរជាច្រើនទៅនឹងសហព្រះរាជអាជ្ញា ហើយនិងសហភាតារបស់ខ្ញុំ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំគ្រាន់តែចង់បានសេចក្តីលម្អិតមួយចំនួនបន្ថែមទៅនឹងចម្លើយរបស់លោក។ ជាពិសេសគឺចង់បានឲ្យលោកពន្យល់ ឲ្យខ្ញុំបានយល់ច្បាស់អំពីអ្វីដែលបានកើតឡើងពិតប្រាកដ។ សំណួររបស់ខ្ញុំនេះ គឺជាសំណួរដេញទេ គឺថាទៅតាមលំដាប់នៃកាលប្បវត្តិជាក់លាក់។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជាដំបូង ខ្ញុំសូមចាប់ផ្តើមអំពីកិច្ចប្រជុំដើមខែមេសា ឆ្នាំ៧៥។ ហើយនៅក្នុងកិច្ចប្រជុំនោះ

គឺមានការរៀបចំផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ លោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត ហើយនិងក្នុងសវនាការនេះ ថា “លោកបានឮអំពីការជជែកគ្នា អំពីការជម្លៀសប្រជាជននៅដើមខែមេសា ឆ្នាំ៧៥ នៅក្នុងកិច្ចប្រជុំនោះ។ គឺលោកបានស្តាប់ឮអំពីមូលហេតុក្នុងការជម្លៀសប្រជាជន គឺថាប្រសិនបើប្រជាជននៅតែបន្តនៅក្នុងទីក្រុងនោះ គឺថាមានការពិបាកក្នុងការគ្រប់គ្រងប្រជាជន”។ ហើយលោកក៏បានឆ្លើយថា “លោកបានស្តាប់ឮ គឺគេផ្តល់ឧទាហរណ៍អំពីក្រុងឧដុង្គ”។ ហើយលោកឆ្លើយថា “អ្នកប្រជុំនោះ គឺថាបានទះដៃអបអរសាទរចំពោះផែនការជម្លៀសនោះ”។ សំណួរខ្ញុំ គឺចង់ដឹងថា ដោយសារតែលោកបានស្តាប់ឮអំពីបញ្ហានេះ តើលោកមានស្តាប់ឮទេ ថាគេគ្រោងទុកយ៉ាងម៉េចពាក់ព័ន្ធទៅនឹងការរៀបចំការជម្លៀសនេះ គឺថាដោយសារថាមានប្រជាជនច្រើនណាស់ដែលត្រូវចាកចេញពីទីក្រុងភ្នំពេញនោះ។ អ៊ីចឹងគេមានការរៀបចំ ចាត់តាំងអីជាក់លាក់ ច្បាស់លាស់ដើម្បីឲ្យប្រជាជនចេញទៅតាមផ្លូវឲ្យបានស្រួលទេ?

[១៥:២២:៤១]

**លោក វ៉ាចាម តុន៖**

**ឆ៖** ចំណុចនេះ ខ្ញុំបានបញ្ជាក់នែ៎ ហើយសំណួរក៏ចុះឡើងៗ អាចំណុចហ្នឹង។ ខ្ញុំបញ្ជាក់ហើយថា ខ្ញុំឃាម ហើយមានមតិទី១ហ្នឹង ឧទ្ទេសនាមហ្នឹង អ៊ំ ប៉ុល ពត ហ្នឹងហើយ។ ដល់ទី២ អ៊ំ នួន ជា គាត់មានមតិ គាត់ឯកភាពដែរហ្នឹង អ៊ំ ខៀវ សំផន ក៏មានមតិឯកភាព។ ហើយក្រៅពីហ្នឹង គេឯកភាពលើចំណុចបីហ្នឹងហើយ បីនាក់ហ្នឹង នែ៎ ឯកភាពដូចគ្នាហ្នឹង គេក៏ឯកភាពគ្នាក៏ដែទះទៅអ៊ីចឹង។ គឺដឹងតែជម្លៀសចេញហ្នឹងហើយ។ ប៉ុន្តែដឹងតែប៉ុណ្ណឹង និយាយតែប៉ុណ្ណឹង អត់មានអីលម្អិតអីម៉េចទៀត អត់ទេ អត់ដឹងទេអាហ្នឹង។

[១៥:២៣:៣៨]

**ស៖** សូមអរគុណ ខ្ញុំនឹងសួរឲ្យបានច្បាស់ជាងនេះបន្តិច។ នៅពេលប្រជុំនោះ តើលោកបានដឹងឮអំពីរបៀបនៃការផ្តល់អាហារហូបចុក ដល់ប្រជាជនតាមផ្លូវទេ គេមានគ្រោងថា ផ្តល់ទឹក ផ្តល់អាហារ ហើយគេយកចិត្តទុកដាក់យ៉ាងម៉េចចំពោះមនុស្សចាស់ កុមារ មនុស្សឈឺ ឬក៏ស្ត្រីមានផ្ទៃពោះ តើលោកមានឮគេពិភាក្សាអំពីចំណុចទាំងអស់នេះទេនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** ដូចខ្ញុំបានបញ្ជាក់អំមិញហើយ គឺខ្ញុំថា ខ្ញុំមិនបានដឹងល្អិតទេ ហើយក្នុងអង្គប្រជុំនោះក៏អត់មានលើកល្អិតដែរ គាត់អត់មានទេ អត់មានលើកអ៊ីចឹងទេ។ គេដឹងតែចេញ ចេញជម្លៀសចេញតែ

ប៉ុណ្ណឹង អត់មានអីវែកញែកល្អិតល្អន់អី គាត់អត់ទេ។

**ស៖** សូមអរគុណ ដែលលោកបញ្ជាក់ថា មិនមានការជជែកលម្អិតនៅក្នុងកិច្ចប្រជុំនេះ។ ដូច្នេះ ខ្ញុំចូលទៅចំណុចផ្សេងទៀត។ លោកបានមកដល់ភ្នំពេញនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ៧៥ ហើយលោកបាន ពន្យល់ ថាលោកបានឃើញអ្វីខ្លះនៅពេលនោះ។ ហើយលោកក៏បានពន្យល់ជូនសហចៅក្រមស៊ើប អង្កេតផងដែរ ថាលោកបានឃើញសាកសពនៅតាមដងផ្លូវ។ ជាពិសេសលោកឃើញមានមនុស្សកាន់ -- រែកបាវលុយ ហើយ -- ដែលគាត់មិនចង់បោះចោលនោះ។ តើលោកមានឃើញមនុស្សឈឺ ឬក៏ មនុស្សពិបាកដើរ ហើយស្ត្រីពកូន ឬក៏អ្នកដែលថា មានការលំបាកធ្ងន់ធ្ងរក្នុងការធ្វើដំណើរដែរឬទេ?

**ឆ៖** បើនិយាយពីឃើញអ្នកជម្លៀសហ្នឹង វាលំបាកៗហើយ គឺថាគេនៅទីក្រុង គេធ្លាប់តែជិះ ឡាន ជិះម៉ូតូ គេនៅមានកង្ហារ មានម៉ាស៊ីនត្រជាក់ មានហូបចុកគ្រប់គ្រាន់ ដល់ចេញទៅអីចឹងវាលំបាក វាវេទនាហើយ។ មិនដឹងធ្វើម៉េចកាលៈទេសៈវាអីចឹងទៅហើយ ឃើញ ខ្ញុំឃើញៗ ដូចខ្ញុំបានបញ្ជាក់ហ្នឹង ខ្ញុំឃើញតែគេរែកលុយនោះហើយ ដែលបែកញើសរហែមរហាម ឃើញហ្នឹងហើយ ហ្នឹងអីចឹង។ ការ លំបាកវាឃើញមិនមែនស្រួលទេ ហើយយើងទៅ យើងចំណាយកម្លាំងយើង ទៅវៃរំដោះភ្នំពេញក៏មិន មែនស្រួលប៉ុន្មានដែរ អត់បាយអត់ទឹកដែរហ្នឹង ដើម្បីរំដោះភ្នំពេញហ្នឹង វេទនាណាស់ដែរ មិនទៅស្រួល ណានុះ បើខ្លួនឯងគ្រាន់តែចេញពីភ្នំពេញ វាលំបាកលំបិនប៉ុណ្ណឹង វាមានទៅស្អី។

[១៥:២៦:៣៥]

**ស៖** សូមអរគុណលោកសាក្សី។ បន្ទាប់មកលោកចូលទីក្រុងភ្នំពេញ ហើយលោកបានឆ្លើយនៅ ចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ គឺឯកសារ E3/24។ លោកបានឆ្លើយ ដូចតទៅនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមស្នើលោកប្រធានថា ខ្ញុំគ្រាន់តែអានទេ ដើម្បីបានឲ្យលឿន ហើយខ្ញុំអាចផ្តល់ ERN បាន ដោយមិនបាច់ចាំដាក់បញ្ចាំងទេលោកប្រធាន តើបានដែរឬទេ? សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** នៅក្នុងឯកសារ E3/24 ERN ជាភាសាបារាំង 00503921, ERN ជាភាសាអង់គ្លេស 00223582, ERN ជាភាសាខ្មែរ 00204069។ លោកបានឆ្លើយដូចតទៅនេះ៖ "ផ្ទុយទៅវិញ នៅពេល នោះគេប្រាប់យើងថា តើត្រូវខ្លាចសត្រូវ ឬក៏មានការប្រុងប្រយ័ត្នចំពោះកម្លាំង ដែលបង្កប់នៅតាមផ្ទះ

ទោះជាកម្លាំងធំ ត្រូវកម្ចាត់ហើយក៏ដោយ"។ លោកសាក្សី តើលោកអាចពន្យល់បានទេដែលពាក្យថា មានកម្លាំងបង្កប់នៅតាមផ្ទះនេះ តើមានន័យថាម៉េចដែរ?

**លោក វ៉ាចាម តុន៖**

**ឆ៖** កម្លាំងបង្កប់ យើងថា កម្លាំងបង្កប់នែក្រោយវា។ កម្លាំងធំវាចាញ់ហើយ គឺកម្លាំងបង្កប់វានៅតាមផ្ទះនេះ នៅតាមផ្ទះ វាត្រៀមគ្រាប់បែក វាត្រៀម វាត្រៀមគ្រាប់កាំភ្លើង វាត្រៀមអាវុធ នេះសព្វគ្រប់ទាំងអស់។ ពេលណាវាអាច ដែលវា -- បើថាកម្លាំងដែលនៅក្នុងអ្នំ ពេលណាវាអាច -- បើយើងទុកនៅហ្នឹងគឺកម្លាំងហ្នឹង វានឹងងើបឡើង។ ងើបឡើងពេលហ្នឹងហើយ យើងត្រូវវឹកវរមែនទែន។ នេះគឺរឿងនេះ គឺរឿងយើង គេហៅថា ធ្វើបដិវត្តន៍ហ្នឹងហើយ គឺថា ត្រូវម្ចាស់ការលើសភាពការណ៍ជាមុន កុំដើរតាមកន្ទុយសភាពការណ៍ បើទៅតាមកន្ទុយសភាពការណ៍ហ្នឹងគឺថា បរាជ័យហើយអាហ្នឹងអ៊ីចឹង។

[១៥:២៩:១២]

អ៊ីចឹងបានលើកថាទាល់តែជម្លៀសចេញអស់។ កម្លាំងបង្កប់ហ្នឹងវាមាន វាត្រៀមចាញ់ វាមាន -- វាចាញ់ជារូបភាព ប៉ុន្តែខ្លឹមសារ វាមិនទៅសុខចិត្តនែ៎ នេះវាឯណា អំណាចនេះ វាមិនមែនសុខចិត្តបោះបង់អំណាចវាចោលឯណា វាចង់ដណ្ដើមយកអំណាចវាតទៅទៀត វាចង់ធ្វើវិធីណាទៀត។ យើងមិនដឹងទេ ប៉ុន្តែវាត្រៀមអ៊ីចឹង។ អ៊ីចឹងបានថា កម្លាំងផ្ទៃក្នុង កម្លាំងក្នុងបង្កប់ហ្នឹងវាមាន បទពិសោធន៍ដូចមានជាហូរហែអស់ទៅហើយ ក្នុងតំបន់រំដោះម៉េច យើងហៅថា អាគិញ្ចង្រៃវាទៅហើយ។ វាបញ្ហាឲ្យកប៉ាល់ហោះហ្នឹងចុចទម្លាក់កន្លែងនេះ ទម្លាក់កន្លែងនោះក៏ដោយសារគិញ។ រឿងហ្នឹងហើយបានយើងរំដោះភ្នំពេញ យើងប្រយ័ត្ន។ វាមានហេតុផលរបស់វាអ៊ីចឹង បើមិនជម្លៀស អត់ម្ចាស់ការទេ ដល់ជម្លៀសចេញបានម្ចាស់ការបាន។ យើងៗឃើញហើយ គឺថាយើងគ្រាន់តែជម្លៀសចេញពីទីក្រុងភ្នំពេញ យើងនៅបានតែ៣ឆ្នាំ៨ខែ២០ថ្ងៃ អ៊ីចឹង។ បើថាយើងអត់ជម្លៀសហ្នឹង មិនដឹងជាចាញ់ពេលណាទេក៏មិនដឹង អាហ្នឹងវាអ៊ីចឹង។ ព្រោះយុទ្ធសាស្ត្ររបស់វា វាមិនទៅបោះបង់ចោលឯណា។ ដូចខ្ញុំបញ្ជាក់ពីមុនហើយថា កា.ហ្សេ.បេ ក៏មាន សេ.អ៊ី.អា ក៏មាន មួយកំភ្លូសមួយកំភ្លាយ។

[១៥:៣០:៥០]

**ស៖** សូមអរគុណលោកសាក្សី។ តើលោកខ្លួនលោកផ្ទាល់នោះ លោកមានបានឃើញខ្មាំងបង្កប់នៅក្នុងផ្ទះទេ? ហើយប្រសិនបើឃើញ តើលោកធ្វើអ្វីដែរចំពោះខ្មាំងទាំងអស់នោះ?

**ឆ៖** ដល់គេជម្លៀសអស់ហ្នឹង អត់ឃើញទេ។ អត់ឃើញខ្មាំងហ្នឹងហើយ បានខ្ញុំបានមកមានសិទ្ធិមកបើកសវនាការថ្ងៃនេះ បានខ្ញុំរស់ហ្នឹង។ បើខ្មាំងវានៅវាបាញ់ខ្ញុំងាប់បាត់ទៅហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី មានបញ្ហាអីទៅ? មេធាវីជាតិការពារក្ដីលោក អៀង សារី មានបញ្ហាអី?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ សហមេធាវីអំមិញគាត់សួរក្នុងករណី "បើគាត់ឃើញខ្មាំងនៅតាមផ្ទះ តើគាត់គួរធ្វើម៉េច?" នេះជាសំណួរឧបមានវិធី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តការតាំងសំណួរ!

[១៥:៣២:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

តាមពិតនេះជាចម្លើយរបស់សាក្សីទេ មិនមែនជាការសួរជាឧបមានវិធីនោះទេលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ឥឡូវនេះខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងទាហាន លន់ នល់ នៅពេលដែលលោកចូលមកទីក្រុងភ្នំពេញ។ តើមានការបញ្ជា ឬក៏ការណែនាំជាក់លាក់អ្វីឲ្យធ្វើបាបទាហាន លន់ នល់ ដែរឬទេ?

**លោក វ៉ាចាម តុន៖**

**ឆ៖** បើគេចាញ់ហើយ គេលើកទង់សហើយ យើងអត់មានអីនឹងប៉ះពាល់គេទេ។ អាហ្នឹងគេមានគោលនយោបាយច្បាស់តែម្ដង។ ក្នុងសមរភូមិផ្សេង បើគេចាញ់ហើយ បើគេលើកទង់សទៅហើយ យើងអត់មានប៉ះពាល់ទេ គឺដាច់ខាតតែម្ដង គឺណែនាំដាច់ខាតអត់មានឲ្យប៉ះពាល់ទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រើប្រាស់ឯកសារមួយ ដែលឯកសារនេះមានលេខ D22/2189។ ខ្ញុំសូមអានសម្រង់នៃឯកសារនេះ។ ERN ជាភាសាបារាំងនោះ 000827033 (ស៊ីក), ERN ជាភាសាខ្មែរ 00546765។ ខ្ញុំអត់ទាន់បានទទួលការបកប្រែជាភាសាអង់គ្លេសទេ សូមអភ័យទោសផង។ នេះគឺជាសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំប្រើឯកសារនេះទេ?

[១៥:៣៤:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានបញ្ជាក់ថា៖ "នៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ឪពុកម្តាយរបស់ប្តីខ្ញុំ គឺ ឡេង ផេង ជាទាហាន លន់ នល់ ហើយនិងប្រពន្ធគាត់ ហើយនិងបងប្អូនបួននាក់គាត់របស់គាត់--

**អ្នកបកប្រែ៖**

លោកប្រធាន ឈ្មោះ -- អ្នកបកប្រែមិនអាចស្តាប់ឈ្មោះបានទេ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** --ហើយគេសម្លាប់ចោលនៅផ្ទះជិតផ្សារអូឡាំពិក ដោយទាហានខ្មែរក្រហម។ នៅថ្ងៃដដែលនោះ ឡេង ជៀក ជាពូរបស់ប្តីខ្ញុំ ដែលគាត់ទាហាន លន់ នល់ ហើយប្រពន្ធគាត់ឈ្មោះ សំណុង (សំរាង) ហើយនិងកូនបីនាក់របស់គាត់ ក៏ត្រូវបានខ្មែរក្រហមបាញ់សម្លាប់ចោលនៅក្នុងផ្ទះជិតផ្សារអូឡាំពិកផងដែរ"។ លោកសាក្សី តើលោកមាននឹកឃើញអំពីហេតុការណ៍អ្វីជាក់លាក់ពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំបានលើកឡើងនេះទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណលោកសាក្សី។ នេះគឺជាសេចក្តីប្រកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំចូលមកនិយាយអំពីមន្ទីរ ប-១ វិញមកម្តង។ នៅក្នុងចម្លើយរបស់លោក ក្នុងឯកសារ E3/24 នៅទំព័រ៩ ជាភាសាបារាំង។ ជាភាសាអង់គ្លេស ERN 00223585, ជាភាសាខ្មែរ 00204071។ លោកនិយាយថា នៅពេលដែលមានការបាត់ខ្លួននោះ កាលពីព្រឹកមិញ ក៏លោកបាននិយាយដែរ ថាមិនមានអ្នកណានិយាយទេ។ តើលោកអាចប្រាប់ខ្ញុំបានទេ ថាគេឲ្យលោករក្សាការសម្ងាត់មែនទេ ដែលថាលោកមិននិយាយពីការបាត់ខ្លួននេះ? អានេះ ជាការសម្ងាត់ដែលលោកត្រូវតែរក្សាមែនទេ?

**ឆ៖** កន្លែងណាគេប្រាប់ថា ឲ្យសម្ងាត់ គឺសម្ងាត់។ ដឹងតែខ្លួនឯង អត់មានប្រាប់អ្នកណាទៀតទេ។

[១៥:៣៦:៤៦]

**សៈ** តើគេឲ្យលោករក្សាការសម្ងាត់ពាក់ព័ន្ធនឹងការបាត់ខ្លួនដែរឬទេ?

**ឆៈ** អ្នកបាត់ខ្លួន អត់មានអីសម្ងាត់អីផង។ បាត់ គឺបាត់ហើយ។ អត់មានអីទេ។

**សៈ** តើខ្ញុំអាចដឹងបានទេ ហេតុអីបានជាមិននិយាយអំពីការបាត់ខ្លួននេះ?

**ឆៈ** អាហ្នឹងជាលាក់ការណ៍របស់បដិវត្តន៍។

**សៈ** សូមអរគុណលោកសាក្សី។ តើចំពោះលោកផ្ទាល់នោះ តើលោកធ្លាប់មានការភ័យខ្លាចទេ នៅពេលដែលឃើញមានមនុស្សបាត់ខ្លួនជាបន្តបន្ទាប់បែបនេះ?

**ឆៈ** ខ្ញុំបានបញ្ជាក់ហើយអំមិញ នែ៎ៗ ចម្លើយរបស់ខ្ញុំនេះ គឺថាមានការព្រួយបារម្ភដែរ ព្រួយបារម្ភពិសេស គឺថាចុងឆ្នាំ៧៨នេះ។ បានយើង ព្រួយបារម្ភ គឺថាគេឲ្យយើងធ្វើប្រវត្តិរូបឡើងវិញ។ បើធ្វើប្រវត្តិរូបឡើងវិញ វាមានការព្រួយបារម្ភដែរ។ ព្រោះពេលហ្នឹងវាអ៊ីចេះ វាមានហេតុផលរបស់វា។ អ៊ំ អៀង សារី គាត់ថាគាត់ៗ នេះដែរ គេឲ្យធ្វើប្រវត្តិរូបខ្លួនគាត់ដែរ។ ដល់ទ៉ុងបង សួរ ហុង គេថាគេឲ្យធ្វើប្រវត្តិរូបខ្លួនគាត់ដែរ។ បើខ្ញុំបីនាក់ហ្នឹង គេឲ្យធ្វើទាំងអស់។ ថាបើអ៊ំ អៀង សារី បាត់ ខ្ញុំក៏បាត់ បងហុង ក៏បាត់ដែរ។ អាហ្នឹង អ៊ីចឹង បានខ្ញុំថា ខ្ញុំចាប់អារម្មណ៍ ខ្ញុំមានការព្រួយបារម្ភដែរ។ ប៉ុន្តែចិត្តមួយចំពោះខ្ញុំផ្ទាល់ ខ្ញុំតាំងចិត្តថា ខ្ញុំបានគោរពក្រោមទង់បក្ស។ គឺថាបានលះបង់អ្វីៗ ដើម្បីបដិវត្តន៍ ដើម្បីអ្នកស្នេហាជាតិ ដើម្បីអ្នកស្នេហាប្រជាជន ដើម្បីអ្នកស្នេហាបដិវត្តន៍។ បើវាត្រូវចប់ មិនដឹងធ្វើម៉េច។ អាហ្នឹង គឺថាគេបានប្តេជ្ញាចិត្តហើយអស់ ខ្ញុំបានធ្វើសច្ចាប្រណិធានហើយអស់ហើយ។ តាំងពីគោរពចូលយុវកក យើងគោរព ចូលបក្ខជន ក៏យើងគោរព។ មានស្អីដែលត្រូវខ្លាចទៀត។ សម្រេចចុងក្រោយគឺអ៊ីចឹង។

[១៥:៤០:០៥]

**សៈ** បើតាមអ្វីដែលលោកនិយាយអម្បាញ់មិញនេះ គឺខ្ញុំយល់ថា ការបាត់ខ្លួននោះ មានន័យថាស្លាប់មែនទេ?

**ឆៈ** មិនដឹងទេ មិនដឹងជាស្លាប់ មិនដឹងជារស់ទេ អត់ដឹងទេ។ មិនដឹងទេ។ បើបាត់ៗថ្នាក់កំពូលៗដែរ មានអី។ ដូចជា សោ ភឹម ក៏បាត់, កុយ ធួន ក៏បាត់, វន វ៉េត ក៏បាត់, ចេង អន ក៏បាត់។ បាត់ហូរហែតាប៉ែលតអ៊ីចឹង អាហ្នឹង មានទៅដឹងម៉េចទេ ឃើញអ៊ីចឹង។ ហើយក្នុងមន្ទីរ៨៧០នេះ ស្និទ្ធៗ ប៉ង់ ក៏បាត់ទៀត, ឌឿន ក៏បាត់ទៀត។ បាត់មែនទែន បាត់ស្លាប់ទៅវាបាត់ច្រើន មួយកម្ពុជាហ្នឹងវាបាត់ច្រើនណាស់ តាមភូមិភាគក៏បាត់ដែរ។ ឃើញបាត់ច្រើនអ៊ីចឹងដែរ។ ហើយគ្នាគាត់ហ្នឹង ហ៊ូ យន់, ហ៊ូ

នឹម ហ្នឹង បាត់ទៀត ធ្វើម៉េចវាបាត់អ៊ីចឹង។ អ៊ីចឹងបានថា វាចេះតែឃើញហេតុការណ៍អ៊ីចឹងបានចេះតែៗព្រួយបារម្ភដែរ ខ្ញុំខ្លួនឯងក៏ចេះតែព្រួយ។

[១៥:៤១:៣៧]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធនឹងការបាត់ខ្លួននេះ លោកបានឆ្លើយអម្បាញ់មិញនេះថាយោធាយ-១០ មករកមនុស្សនៅមន្ទីរប-១ ដើម្បីចាប់ខ្លួន។ តើលោកដឹងអំពីមុខងារពិតប្រាកដនៃមន្ទីរយ-១០ នេះដែរឬទេ?

**ឆ៖** អង្គភាពយ-១០ នេះជាអង្គភាពយោធាការពារមន្ទីរផ្ទាល់ហ្នឹងហើយ ការពារមន្ទីរផ្ទាល់របស់មជ្ឈិមហ្នឹងហើយ។

**ស៖** តើ យ-១០ នេះស្ថិតនៅក្រោមបង្គាប់របស់មន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** ក្រោមបង្គាប់របស់៨៧០ ដដែល។

**ស៖** សូមអរគុណ។ នៅក្នុងចម្លើយរបស់លោក គឺឯកសារ E3/63។ ERN ជាភាសាអង់គ្លេស 00231410, ខ្មែរ 00228843, ជាភាសាបារាំង សូមទោសខ្ញុំអាចអានផ្ដល់ជូនបានតែអង់គ្លេស និងខ្មែរទេ។ គេបានសួរលោកពាក់ព័ន្ធទៅនឹងចម្លើយរបស់ ឌុច។ ឌុច បានឆ្លើយថា លោកបាននាំមនុស្សទៅមន្ទីរស-២១។ លោកឆ្លើយថា អត់ទេ។ ហើយតើលោកស្គាល់អ្នកផ្សេងដែរ នៅមន្ទីរប-១ ហ្នឹង ដែលនាំមនុស្សយកទៅមន្ទីរស-២១ នោះ ឬក៏មនុស្សក្រៅប-១ ដូចជាមកពីខាងយ-១០ អីជាដើម តើលោកស្គាល់ទេ មានអ្នកណាដែលជាអ្នកនាំមនុស្សយកទៅមន្ទីរស-២១ នោះ?

[១៥:៤៤:១៩]

**ឆ៖** ព្រឹកមិញ ខ្ញុំបានបញ្ជាក់ថា គឺកម្លាំងយ-១០ នេះបាននាំកម្លាំងពីប-១ មិនដឹងគេនាំទៅឯណាទេ ខ្ញុំមិនដឹងទេ។ គេមាននាំចេញពីប-១។ ឯខ្ញុំក៏នាំមនុស្សទៅដែរ បាននាំមនុស្សហ្នឹង គឺនាំទៅឲ្យ -- ខ្ញុំពេលនោះ ខ្ញុំអត់ស្គាល់ទេ ស-២១ ហ្នឹង។ ខ្ញុំណែនាំទៅ ដូចកំណត់ផ្ទះ គេកំណត់ថាផ្ទះនេះ លោកឯងយកមនុស្សមកដាក់កន្លែងនេះ។ ខ្ញុំក៏នាំមនុស្សទៅដាក់កន្លែងនុ៎ង ហើយខ្ញុំឃើញតែពួក៨៧០ទេ។ ហើយ៨៧០ហ្នឹង ខ្ញុំមិនមែនក៏ -- ខ្ញុំ គោលដៅខ្ញុំៗឃើញតែអាហ្នឹង។ ឯក្រៅពី៨៧០ ហ្នឹង ដែល ឌុច ឆ្លើយថាៗខ្ញុំយកមកឲ្យខាង ឌុច ហ្នឹងដែរខ្ញុំមិនបានស្គាល់ទេមន្ទីរស-២១ ហ្នឹង។ ខ្ញុំថាខ្ញុំនាំខ្ញុំដឹង នាំទៅខាងមន្ទីរ៨៧០ ទេ ដែលគេអ្នកទទួលពីខ្ញុំទៅ។ វាអ៊ីចឹងចំណុចនេះ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់អ៊ីចឹង។

**សៈ** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីបឹងត្របែកវិញម្តង។ លោកបានផ្តល់នូវសេចក្តីពន្យល់មួយចំនួនហើយពាក់ព័ន្ធទៅនឹងមន្ទីរបឹងត្របែកនេះ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/24 នៅទំព័រ១២ ជាភាសាបារាំង ERN ជាភាសាខ្មែរ 00204074, ជាភាសាអង់គ្លេស 00223587 លោកបានឆ្លើយថានៅពេលប-១ គ្រប់គ្រងបឹងត្របែក គឺថាមានលក្ខណៈធូរស្រាលជាងមុន។ តើលោកអាចឆ្លើយបានទេថា លោកបានដឹងអ្វីខ្លះពីការកើតឡើងនៅមុនពេលក្រសួងការបរទេសគ្រប់គ្រងនោះ? នៅពេលដែលប-១ កាន់ ចូលមកកាន់វិញ ហើយលោកឆ្លើយថាមានលក្ខណៈធូរស្រាល តើលោកអាចជម្រាបបានទេថា ពីមុនយ៉ាងម៉េច? ហើយក្រោយមកយ៉ាងម៉េចដែរ?

[១៥:៤៦:៥៨]

**ឆៈ** ចំណុចនេះ ខ្ញុំចង់តាមដែលខ្ញុំបានជួបបងៗបញ្ញាជននៅក្នុងហ្នឹង គាត់ថាមុនប-១ ទៅគ្រប់គ្រងហ្នឹងហូបចុកហ្នឹងវាខ្វះខាត វាខ្វះទាំងអង្ករ វាខ្វះទាំងសព្វគ្រប់ទាំងម្ហូបអាហារ វាមិនមានទេ។ ១០ ថ្ងៃគេឱ្យម្តងក៏មានដែរ ឬមួយកន្លះខែគេឱ្យម្តងក៏មានដែរ ជួនណាគេមិនទាំងរវល់ផង ក៏មានដែរ។ ប៉ុន្តែខាងប-១ គេទទួលទៅ គឺថា អង្ករអត់មានឱ្យខ្វះទេហ្នឹង។ ហើយនំប៉័ងអត់មានឱ្យខ្វះទេ ហើយនិយាយពីម្ហូបអត់មានឱ្យខ្វះទេ។ ហ្នឹងជាអចិន្ត្រៃយ៍តែម្តង រឿងបន្លែបន្ទុកៗ គាត់ដាំខ្លួនគាត់ទេ រឿងបន្លែបន្ទុក។ សំខាន់គាត់ត្រូវការតែម្ហូបៗ ជាសាច់គោ ជាសាច់ជ្រូក ជាសាច់មាន់ ជាត្រី អាហ្នឹងវាចាំបាច់កន្លែងហ្នឹងវាមិនមាន។ អ៊ីចឹងបានខ្ញុំថាដែលវាធូរធារហ្នឹង គាត់និយាយខ្លួនគាត់ទេ។ គាត់ថា ពីមុនហើយនិងឥឡូវហ្នឹង វាខុសគ្នាឆ្ងាយណាស់ខាងជីវភាពហ្នឹង។ អ៊ីចឹងបានខ្ញុំបញ្ជាក់ថា ដែលប-១ គ្រប់គ្រងហ្នឹង គឺថាវាមានសភាពៗដូចថាវាធូរស្រាលក្នុងខួរក្បាលបន្តិចដែរ បើថា ក្រពះវាឆ្អែតហើយ ហើយដេកលក់ទៅហើយវាមិនមានការព្រួយបារម្ភទៅ បានថាវាធូរស្រាលហើយ។ ហើយខ្លីណាស់ ខាងខ្ញុំគ្រប់គ្រងក្បែរនឹងចុង៧៨ ហ្នឹង វាខ្លីណាស់។

[១៥:៤៨:៤៤]

**សៈ** តើបញ្ញាជននៅមន្ទីរបឹងត្របែកហ្នឹងគាត់ធ្វើសកម្មភាពអ្វីខ្លះដែរ?

**ឆៈ** បើចាប់ពី ប-១ ទៅគ្រប់គ្រង ខ្ញុំទៅគ្រប់គ្រងផ្ទាល់ ខ្ញុំណែនាំហើយ ខ្ញុំថា ទី១) ឱ្យដាំបន្លែ បើវាហាត់មិនបាច់ដាំក៏បានដែរ។ ខ្ញុំថាហ្នឹងពិចារណាខ្លួនឯងទៅ បើវាហាត់កុំទៅធ្វើពេកហាត់ហ្នឹង។ ហើយទី២) គឺថា គាត់នៅអង្គាល់ហ្នឹងចង់បានវិទ្យុស្តាប់ ខ្ញុំយកវិទ្យុឱ្យគាត់ស្តាប់ទៅ។ អង្គាល់ហ្នឹងវាបើវាមានវិទ្យុទៅវាស្តាប់ដំណឹងទាំងក្នុងប្រទេសក៏បាន ក្រៅប្រទេសក៏បានដែរ។ ខ្ញុំថាបើចង់ដេកស្តាប់

វិទ្យុហ្នឹងក៏បានដែរ វាមិនអីទេៗកាលហ្នឹង។ ការងារពួកគាត់នៅហ្នឹងមែនទែនគឺថា ឲ្យកសាងខ្លួន គឺកសាងក្នុងន័យថាលត់ដំហ្នឹង គឺថាបង្កបង្កើនផលខ្លួនគាត់ ប៉ុន្តែមិនមែនយកអាហ្នឹងទៅឲ្យគេទេ របស់គាត់ដាំបានហ្នឹង ចិញ្ចឹមបាន ហូបតែខ្លួនគាត់ហ្នឹង។ អាហ្នឹងអ៊ីចឹង។ ដល់តែនែ៎ ខ្ញុំគ្រប់គ្រងក្រោយខ្ញុំថាព្រោះវា សំខាន់ចង់ឲ្យកម្លាំងនេះ ឲ្យវានឹងនរ ក្រែងខ្ញុំបានមកប្រើប្រាស់មកធ្វើការងារនៅក្នុងក្រសួង។ បើបានកម្លាំង មកធ្វើការងារក្នុងក្រសួងទៅ វាធូរដែរ កម្លាំងជាតិយើង។ កម្លាំងដែលយើងមានហើយ យើងគ្រប់គ្រងល្អទៅ បើគេមានភ្ញាក់រឭកទៅ ឲ្យអារម្មណ៍គេល្អទៅ គេនឹងបំពេញភារកិច្ចខាងមុខហ្នឹងអាចបានល្អ ព្រោះសមត្ថភាពរបស់គេ គឺមានមួយរយភាគរយទៅហើយ។ ខាងភាសាក៏គេចេះ ខាងនែ៎ ពិសោធន៍ និងខាងផ្លូវទូតនោះ ក៏គេមានដែរ ហើយនែ៎ ការដែលគេរៀបចំកែលម្អខ្លួនឲ្យទាន់នឹងចលនា ឃើញថាវាមានពិបាកអីទេអ៊ីចឹង។ អ៊ីចឹងខ្ញុំបញ្ជាក់ជូនគាត់។ បើខ្ញុំ ខ្ញុំនិយាយត្រង់ៗអ៊ីចឹងហើយខ្ញុំប្រាប់អ៊ីចឹង។ បើតាមតែពិបាកមិនបាច់ធ្វើទេ។ ការងារចង់ហូបដេក ក៏ហូបទៅ។ វាមិនខ្វះទេអង្ករ វាមិនខ្វះទេបន្លែហ្នឹង។ បន្លែកាលហ្នឹងវាច្រើន ម្ហូបកាលហ្នឹងវាច្រើនហើយ។ ខ្ញុំថា ខ្ញុំប្រាប់ត្រង់ទៅអត់ខ្វះទេ។ ហើយកាហ្វេទៅខ្លះអី កាហ្វេហ្នឹង។ នៅឃ្លាំងខ្ញុំ ខ្ញុំខាងលើណែនាំ ថាត្រៀម២០ឆ្នាំ មិនបាច់ទិញម្តង។ កាហ្វេយកទៅណាអស់។ បើស្រាបារាំងវិញយកទៅណាអស់។ ខ្ញុំថា អត់ខ្វះទេអាហ្នឹងវាមាននៅក្នុងដៃ ចង់ហូបពេលណាក៏បានដែរ ខ្ញុំប្រាប់អ៊ីចឹង។

[១៥:៥១:៤១]

**ស៖** សូមអរគុណលោកសាក្សី។ សំណួរនៅមន្ទីរបឹងត្របែក តើមានការបាត់ខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំទៅគ្រប់គ្រង ដូចអត់មានបាត់ទេ មួយរយៈខ្លីនេះអត់មានបាត់ទេ។ បើគេមុន ខ្ញុំមិនដឹងយ៉ាងម៉េចទេ។ ពេលមុន ក៏ខ្ញុំមិនស្គាល់គេអស់ដែរ ប៉ុន្តែចាប់ខ្ញុំទៅទទួលហ្នឹង អត់មានបាត់ទេ គេនៅ។ ឥឡូវបងៗដែលនៅបឹងត្របែក គេថាដល់ថ្ងៃ០៦ មករា ហ្នឹងមិនដឹងគាត់រត់ទៅណាខ្លះទេ។ ប៉ុន្តែ បងហោ ណាំហុង តើខ្ញុំជួបគាត់។ គាត់រត់ទៅដល់កោះក្រឡ ទៅដល់ទាក់ផ្ទឹមនោះ គាត់រត់ទៅតាមប្រជាជនហ្នឹង។ ខ្ញុំឃើញគាត់ ជួបគាត់អ៊ីចឹង ហូរហែអ៊ីចឹងដែរ។ ហើយគាត់ថា គេភៀសពីហ្នឹងហើយបានគាត់ទៅដល់ស្រុកបារាំងវិញ។ ឥឡូវបានគាត់មកធ្វើធំមែនទែនដូចសព្វថ្ងៃនេះ។

[១៥:៥៣:១៣]

**ស៖** លោកៗបានឆ្លើយថា មិនឃើញមានការបាត់ខ្លួនទេ? អ៊ីចឹង តើលោកមានឮទេ មានឮគេនិយាយថា មានបាត់ខ្លួនអីទេ?

**ផ៖** ខ្ញុំអត់ឮទេ អត់ឮគេថាបាត់ខ្លួន អត់ឮសោះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមបញ្ចប់។ សូមអរគុណលោកប្រធាន។

[១៥:៥៣:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។

បាទ ឥឡូវ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ក៏ដល់ពេលសមល្មមសម្រាកហើយដែរ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក គឺថ្ងៃអង្គារ ទី៣១ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសូមជម្រាបផងដែរ ថាសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី រ៉ចាម តុន ដែលនឹងបន្តការតាំងសំណួរដេញដោលដោយភាគីមេធាវីការពារក្តី ដែលនឹងចាប់ផ្តើមពីក្រុមមេធាវីការពារក្តី នួន ជា មុនមេធាវីពីរក្រុមទៀត សូមភាគី និងសាធារណជនជ្រាប។

លោក រ៉ចាម តុន គឺការផ្តល់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ សវនាការនឹងបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយលោកមេធាវីប្រឹក្សាសាក្សីដូចគ្នា។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅនោះវិញ ហើយនិងឲ្យអញ្ជើញគាត់មក -- ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៦ នាទី)*